**សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច**

**Université Royale Droit et des sciences Economiques**

**Royal University of Law and Economics**

# សារណាបញ្ចប់ការសិក្សា

## អាពាហ៍ពិពាហ៍ និង ការលែងលះ

ស្រាវជ្រាវពី ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០២១ ដល់ ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០២១


តាក់តែងឡើងដោយ

និស្សិតឈ្មោះ **ហួត ចន្ទសុភ័ក្តិ**

**ថេង ស៊ីហ្គិច**

សាស្ត្រាចារ្យណែនាំ

**អ៊ឹង រដ្ឋា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្រ្ត**

ជំនាន់ទី ២២

ឆ្នាំចូលសិក្សា ២០១៨

ឆ្នាំសរសេរសារណា ២០២២

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **ហួត ចន្ទសុភ័ក្តិ** និង **ថេង ស៊ីហ្គិច** ជានិស្សិតឆ្នាំទី៤ ថ្នាក់នីតិសាស្ត្រ ជំនាន់ទី២២ ក្រុម L4A6 ឆ្នាំសិក្សា២០២១-២០២២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។

**សូមធ្វើការវេកិច្ច និងកត្តញ្ញូតាធម៌យ៉ាងជ្រាវជ្រៅជាទីបំផុតជូន**

លោកអ្នកមានគុណទាំងពីរ ដែលលោកបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សារូបកូនចាប់តាំងពីបាតជើងក្រហមរហូតដល់កូនធំដឹងក្តី និងប្រឹងប្រែងទាំងកម្លាំងកាយចិត្ត ធ្វើអ្វីៗសព្វបែបយ៉ាង ដើម្បីចិញ្ចឹមរូបកូនដោយមិនគិតពីការនឿយហត់ ទោះបីមានឧបសគ្គយ៉ាងណាក៏ដោយ ក៏នៅតែខិតខំពុះពារដោយមិនរារែកឲ្យតែកូនបានសិក្សារៀនសូត្របានខ្ពង់ខ្ពស់នឹងគេ ជាពិសេសថែមទាំងចំណាយពេលវេលាផ្តល់ដំបូន្មានប្រៀនប្រដៅប្រកបដោយព្រហ្មវិហារធម៌ និងពន្យល់ណែនាំរូបកូនឲ្យធ្វើអំពើល្អ ចេះគោរពចាស់ទុំ ខិតខំសិក្សារៀនសូត្ររហូតដល់កូនទទួលបានចំណេះដឹងយ៉ាងប្រពៃដូចជាពេលនេះ។

ឯកឧត្តម **បណ្ឌិត លុយ ចណ្ណា** សាកលវិទ្យាធិការ លោក/លោកស្រី សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង ព្រមទាំងសាស្ត្រាចារ្យ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់ដែលបានខិតខំប្រឹងប្រែងទាំងកម្លាំងកាយចិត្ត កម្លាំងបញ្ញា ពន្យល់អប់រំណែនាំដល់ខ្ញុំទាំងពីរនាក់ តាំងពីថ្នាក់មូលដ្ឋានរហូតដល់ពេលបច្ចុប្បន្ន ហើយអាចយកចំណេះដឹងដែលទទួលបាន ទាំងនេះទៅចូលរួមចំណែក ក្នុងការអភិវឌ្ឍន៍ប្រទេសជាតិឲ្យមានការរីកចម្រើន។

ជាពិសេសលោកគ្រូសាស្ត្រាចារ្យ **អ៊ឹម រដ្ឋា** ដែលបានចំណាយពេលវេលាដ៏មានតម្លៃ និងបានផ្តល់នូវឯកសារ ផ្តល់ដំបូន្មានល្អៗ ក្នុងការធ្វើសារណាបញ្ចប់ការសិក្សានេះរហូតទទួលបានជោគជ័យ។ ប្រសិនគ្មានវត្តមានលោកគ្រូសាស្ត្រាចារ្យ **អ៊ឹម រដ្ឋា** រូបខ្ញុំទាំងពីរនាក់ក៏មិនអាចសម្រេចបាននូវស្នាដៃមួយនេះដែរ។

យើងខ្ញុំទាំងពីរនាក់សូមគោរពជូនពរ និងសូមលើកហត្ថាទាំងទ្វេបួងសួងដល់ទេវតា ដែលតាមថែរក្សាព្រះរាជាណាចក្រកម្ពុជាទាំងឡាយ សូមជួយថែរក្សាលោកអ្នកមានគុណទាំងទ្វេ ឯកឧត្តមសាកលវិទ្យាធិការ ឯកឧត្តមសាស្ត្រាចារ្យ លោក លោកស្រីសាស្ត្រាចារ្យ និងអ្នកដែលបានជួយទំនុកបម្រុងក្នុងកិច្ចការស្រាវជ្រាវនេះឲ្យជួបប្រទះនូវពុទ្ធពរទាំងបួនប្រការ គឺ **អាយុ វណ្ណៈ សុខៈ** និង**ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ និងសូមទទួលជោគជ័យគ្រប់ភារកិច្ច។

# អារម្ភកថា

បន្ទាប់ពីបានសិក្សាយ៉ាងលំអិតអស់រយៈពេលបួនឆ្នាំលើផ្នែកនីតិសាស្ត្រ ក្រោមការបង្ហាត់បង្រៀនយ៉ាងយកចិត្តទុកដាក់បំផុតពីសំណាក់ លោក-លោកស្រី សាស្ត្រាចារ្យ បណ្ឌិត ទាំងអស់ដែលមានវត្តមាននៅក្នុងក្រុមរបស់យើងខ្ញុំនាពេលកន្លងមក ឆ្នាំនេះជាឆ្នាំចុងក្រោយ ហើយក៏ជាឆ្នាំដែលរូបខ្ញុំទាំងពីរនាក់ត្រូវឈានជើងចេញពីសាកលវិទ្យាល័យនាពេលដ៏ខ្លីខាងមុខនេះ។ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់សាកលវិទ្យាល័យ និងដើម្បីទុកជាស្នាដៃសម្រាប់ជំនួយដល់ការសិក្សារបស់និស្សិតជំនាន់ក្រោយ រូបខ្ញុំទាំងពីរនាក់បានសម្រេចចិត្តជ្រើសរើសយកប្រធានបទមួយដែលនិយាយអំពី **អាពាហ៍ពិពាហ៍ និង ការលែងលះ** យកមកធ្វើការសិក្សាស្រាវជ្រាវដើម្បីចងក្រងជាសារណាបញ្ចប់ការសិក្សា ដែលទាក់ទងនឹងការសិក្សាលើមុខវិជ្ជា នីតិមុខងារសាធារណៈ ព្រមទាំងបទប្បញ្ញត្តិច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា និងលិខិតបទដ្ឋានគតិយុត្តិមួយចំនួនទៀត ដែលបានសិក្សាកន្លងមក ដើម្បីយកទ្រឹស្តីនៃមុខវិជ្ជានេះ មកធ្វើការអនុវត្តជាក់ស្តែង។

យើងខ្ញុំបានធ្វើការបែងចែកមាតិកា ជាផ្នែកតូចៗ ដើម្បីមានភាពងាយស្រួល ក្នុងការស្រាវជ្រាវ និងស្វែងរកឯកសារបន្ថែម ក៏ដូចជាភាពងាយស្រួល ក្នុងការពន្យល់ និងលើកយកមកពិភាក្សាក្នុងគោលបំណង ចងក្រងឲ្យបាននូវស្នាដៃមួយដ៏ល្អ។ លើសពីនេះទៀតយើងខ្ញុំបានប្រមូលផ្តុំនូវឯកសារស្រាវជ្រាវជាច្រើន និងបានសុំគំនិតយោបល់ពីសាស្ត្រាចារ្យនានា ដើម្បីលើកមកធ្វើការពិភាក្សានៅក្នុងសៀវភៅមួយក្បាលនេះ។ ជាលទ្ធផលយើងខ្ញុំទទួលបាននូវស្នាដៃមួយនេះ ដើម្បីប្រគល់ជូនការិយាល័យស្រាវជ្រាវបានទាន់ពេលវេលា ដែលកំណត់ក្នុងការត្រួតពិនិត្យ និងវាយតម្លៃ ព្រមទាំងដាក់ពិន្ទុពីសំណាក់ លោក លោកស្រីសាស្ត្រាចារ្យដែលជាគណៈកម្មការ។

ទោះបីយើងខ្ញុំបានខិតខំប្រឹងប្រែង និងព្យាយាមពិនិត្យយ៉ាងណាក៏ដោយ ក៏កិច្ចការមួយនេះ ពិតជាអាចមាននូវកំហុសខុសឆ្គងខ្លះៗ ទាំងចេតនាក្តី ឬអចេតនាក្តី នៅត្រង់ចំណុចណាមួយជាមិនខាន។ អាស្រ័យហេតុនេះហើយ ក្នុងនាមយើងខ្ញុំជាអ្នកតាក់តែង សូមធ្វើការអភ័យទោសជាមុននូវរាល់កំហុសឆ្គង និងការខ្វះខាត ក៏ដូចជាទទួលនូវការរិះគន់ផ្សេងៗ ក្នុងគោលបំណងស្ថាបនាស្នាដៃមួយនេះ ឲ្យមានលក្ខណៈកាន់តែល្អប្រសើរឡើងបន្ថែមទៀត។

# មាតិកា


ទំព័រ

**សេចក្តីផ្តើម**..........១

**ជំពូកទី១**

**អាពាហ៍ពិពាហ៍**

**ផ្នែកទី១.សញ្ញាណទូទៅនៃអាពាហ៍ពិពាហ៍**..........៣

១.និយមន័យ..........៤

២.ទម្រង់ការរៀបអាពាហ៍ពិពាហ៍..........៤

២.១.ការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី..........៤

២.២.ការរៀបអាពាហ៍ពិពាហ៍តាមការសែនព្រេន..........៥

**ផ្នែកទី២.ការបង្កើតអាពាហ៍ពិពាហ៍**..........៥

**កថាខណ្ឌទី១.លក្ខខណ្ឌនៃអាពាហ៍ពិពាហ៍**..........៦

១.ភេទរបស់ភាគី..........៦

២.អាយុសម្រាប់រៀបអាពាហ៍ពិពាហ៍ ..........៦

៣.ការរៀបអាពាហ៍ពិពាហ៍របស់អនីតិជន..........៧

៤.ការរៀបអាពាហ៍ពិពាហ៍របស់ជននៅក្រោមអាណាព្យាបាលទូទៅ..........៧

៥.ការយល់ព្រមលើការរៀបអាពាហ៍ពិពាហ៍..........៨

៦.ការយល់ព្រមចំពោះការរៀបអាពាហ៍ពិពាហ៍នៅពេលសហព័ទ្ធអវត្តមានឬ ការបាត់ខ្លួន..........៨

៦.១.បុគ្គលអវត្តមានលើសពី៥ឆ្នាំ..........៩

៦.២.បុគលបាត់ខ្លួនក្រោយជួបឧបទ្ទវហេតុលើសពី១ឆ្នាំ..........៩

**កថាខណ្ឌទី២.លក្ខខណ្ឌទម្រង់នៃអាពាហ៍ពិពាហ៍**..........១០

១.ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ..........១០

២.ប័ណ្ណប្រកាសជាសាធារណៈ ..........១០

៣.រយៈពេលរង់ចាំ ..........១១

៤.ជនអាចប្តឹងជំទាស់អាពាហ៍ពិពាហ៍..........១១

៥.មូលហេតុជំទាស់នឹងគម្រោងអាពាហ៍ពិពាហ៍ ..........១១

៦.ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍.....១២
៧.ការចេញសំបុត្រអាពាហ៍ពិពាហ៍.....១៣
**កថាខណ្ឌទី៣.លក្ខខណ្ឌហាមឃាត់ការរៀបអាពាហ៍ពិពាហ៍**.....១៣
១.ការហាមមិនឱ្យមានទ្វេរពន្ធភាព.....១៣
២.អំឡុងពេលហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ថ្មី.....១៤
៣.ការហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ក្នុងញាតិលោហិត.....១៥
៣.១.ហាមការរៀបអាពាហ៍ពិពាហ៍រវាងញាតិលោហិតផ្ទាល់.....១៥
៣.២.ហាមការរៀបអាពាហ៍ពិពាហ៍រវាងសាខាញាតិលោហិត.....១៥
៣.៣.ហាមការរៀបអាពាហ៍ពិពាហ៍រវាងអតីតឪពុកឬម្តាយបង្កើតជាមួយអតីតកូនបង្កើត .....១៦
៣.៤.ហាមការរៀបអាពាហ៍ពិពាហ៍អតីតឪពុកចិញ្ចឹម ឬ ម្តាយចិញ្ចឹមជាមួយកូនសុំ.....១៦
៤.ការហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍រវាងញាតិពន្ធ.....១៦
៤.១.ការហាមមិនឱ្យរៀបអាពាហ៍ពិពាហ៍រវាងញាតិពន្ធក្នុងខ្សែផ្ទាល់.....១៧
៤.២.ការហាមមិនឱ្យរៀបអាពាហ៍ពិពាហ៍រវាងសាខាញាតិពន្ធ.....១៧
៤.៣.ការហាមមិនរៀបអាពាហ៍ពិពាហ៍រវាងឪពុកម្តាយចុងជាមួយកូនចុង.....១៨
៤.៤.ករណីលើកលែងអាចរៀបអាពាហ៍ពិពាហ៍រវាងសាខាញាតិពន្ធ.....១៨
**ផ្នែកទី៣.អានុភាពនៃអាពាហ៍ពិពាហ៍**.....១៨
**កថាខណ្ឌទី១.នាមត្រកូលរបស់ប្តីប្រពន្ធ**.....១៩
**កថាខណ្ឌទី២.ករណីយកិច្ចរួមរស់នឹងគ្នា សហការ និង សង្គ្រោះគ្នាទៅវិញទៅមក**...១៩
**កថាខណ្ឌទី៣.សេរីភាពក្នុងការជ្រើសរើសវិជ្ជាជីវៈ**.....១៩
**កថាខណ្ឌទី៤.សិទ្ធិស្មើគ្នាក្នុងការប្រើប្រាស់អាស្រ័យផលនិងចាត់ចែងលើទ្រព្យរួម**....២០
**ផ្នែកទី៤.មោឃភាព និង ការលុបចោលអាពាហ៍ពិពាហ៍** .....២១
**កថាខណ្ឌទី១.មោឃភាពនៃអាពាហ៍ពិពាហ៍**.....២១
១.មោឃភាពដាច់ខាត.....២២
១.១.ការភាន់ច្រឡំលើមនុស្ស .....២២
១.២.ការបង្ខិតបង្ខំ . .....២២
២.មោឃភាពមិនដាច់ខាត.....២៣

២.១.ភាគីមិនបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍......២៣
២.២.ភាគីមិនបានជូនដំណឹងជាសាធារណៈ......២៣
២.៣.ភាគីមិនបានចុះកិច្ចសន្យាអាពាហ៍ពិពាហ៍......២៤
២.៤.ភាគីមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍ ......២៤
**កថាខណ្ឌទី២.ការលុបចោលអាពាហ៍ពិពាហ៍**......២៤
១.អាពាហ៍ពិពាហ៍មិនគ្រប់អាយុ......២៤
២.ការមានទ្វេពន្ធភាព......២៥
៣.ការលុបចោលអាពាហ៍ពិពាហ៍ធ្វើក្នុងអំឡុងពេលហាមឃាត់មិនអោយរៀបអាពាហ៍ពិពាហ៍ថ្មីទៀត..២៥
៤.ការលុបចោលអាពាហ៍ពិពាហ៍រវាងញាតិលោហិត......២៦
៥.ការលុបចោលអាពាហ៍ពិពាហ៍រវាងញាតិពន្ធ......២៦
៦.ការលុបអាពាហ៍ពិពាហ៍ដោយការឆបោក......២៧
៧.ការលុបចោលអាពាហ៍ពិពាហ៍ដោយការគំរាម......២៧
៨.អានុភាពនៃការលុបចោលអាពាហ៍ពិពាហ៍......២៧

## ជំពូកទី២

## ការលែងលះ

**ផ្នែកទី១.សញ្ញាណនៃការលែងលះ**......២៩
**កថាខណ្ឌទី១.និយមន័យ** ......២៩
**កថាខណ្ឌទី២.ប្រភេទនៃការលែងលះ**......២៩
១.ការលែងលះគ្នាដោយមានកំហុស......២៩
២.ការលែងលះគ្នាដោយឥតកំហុស......៣០
៣.ការលែងលះគ្នាដោយការព្រមព្រៀង......៣១
**ផ្នែកទី២.នីតិវិធីនៃការប្តឹងលែងលះគ្នា**......៣១
១.ការផ្តើមនៃបណ្តឹង......៣១
១.១.ការសរសេរពាក្យបណ្តឹង......៣១
១.២.ទីកន្លែងដាក់ពាក្យបណ្តឹង......៣២
២.ការផ្សះផ្សា......៣៣

២.១.ការផ្សះផ្សានៅថ្នាក់ឃុំសង្កាត់......................................................................................................៣៣
២.២.ការផ្សះផ្សាដោយតុលាការ.........................................................................................................៣៣
៣.វិធានការចាត់ចែងរក្សាការពារ.......................................................................................................៣៤
៣.១.វិធានការឱ្យសហព័ទ្ធត្រូវតែរស់នៅបែកគ្នា.................................................................................៣៤
៣.២.វិធានការឲ្យមានការថែរក្សាកូនបណ្តោះអាសន្ន.........................................................................៣៥
៤.ការដោះស្រាយបណ្តឹងអាពាហ៍ពិពាហ៍មិនស្របច្បាប់.......................................................................៣៥
៤.១.ការលែងលះគ្នានៃអាពាហ៍ពិពាហ៍ដែលមិនស្របច្បាប់................................................................៣៦
**ផ្នែកទី៣.នីតិវិធីនៃការជម្រះក្តីនិងការស៊ើបអង្កេតរបស់ចៅក្រម**......................៣៧
១.ដំណើរការទាញហេតុផលផ្ទាល់មាត់.............................................................................................៣៧
២.ឯកសារត្រៀម...........................................................................................................................៣៨
៣.នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល.........................................................................................៣៨
៤.ការទាញហេតុផលផ្ទាល់មាត់.........................................................................................................៣៩
៥.ភស្តុតាង.....................................................................................................................................៣៩
៦.ការអះអាងអង្គហេតុដោយតំណាងអយ្យការ...................................................................................៤០
៧.ការស្រាវជ្រាវដោយធន្ទានុសិទ្ធិដោយតុលាការ.................................................................................៤០
៨.ការសម្រេចសេចក្តី.......................................................................................................................៤០
៩.ករណីមិនអាចប្តឹង និង សាលក្រមកំបាំងមុខ.................................................................................៤០
៩.១.ការហាមមិនអោយដាក់ពាក្យបណ្តឹងសាលក្រមស្ថាពរ...................................................................៤០
៩.២.ការបញ្ចប់បណ្តឹងដោយមរណភាពដើមចោទ................................................................................៤១
៩.៣.ការបញ្ចប់បណ្តឹងដោយមរណភាពចុងចោទ.................................................................................៤១
៩.៤.សាលក្រមកំបាំងមុខ..................................................................................................................៤១
៩.៥.ករណីមិនអាចចេញសាលក្រមកំបាំងមុខ.....................................................................................៤១
១០.ការបញ្ចាប់នីតិវិធីដោយមិនសម្រេចសេចក្តី....................................................................................៤២
១១.ការប្តឹងទាស់នឹងសាលក្រមកំបាំងមុខ..........................................................................................៤២
១២.សាលក្រមថ្មី និង សាលក្រមកំបាំងមុខលើកទី២............................................................................៤២
១២.១.សាលក្រមថ្មី...........................................................................................................................៤២
១២.២.សាលក្រមកំបាំងមុខលើកទី២...................................................................................................៤៣

**ផ្នែកទី៤.អានុភាពនៃការលែងលះ**..........................................................៤៣
១.ការរំលាយចំណងអាពាហ៍ពិពាហ៍..........................................................៤៣
២.ការបែងចែកទ្រព្យ..........................................................៤៣
២.១.ការបែងចែកទ្រព្យសម្បត្តិតាមការព្រមព្រៀង..........................................................៤៣
២.២.ការបែងចែកទ្រព្យសម្បត្តិដោយគ្មានការព្រមព្រៀង..........................................................៤៤
៣.ការបែងចែកកូន..........................................................៤៥
៣.១.ការបែងចែកកូនតាមការព្រមព្រៀងរបស់ភាគី..........................................................៤៥
៣.២.ការបែងចែកកូនតាមការមិនព្រមព្រៀងរបស់ភាគី..........................................................៤៥
៤.អាហារកិច្ចចំពោះកូន..........................................................៤៦
៤.១.អាហារកិច្ចដោយការព្រមព្រៀងរបស់ភាគី..........................................................៤៦
៤.២.អាហារកិច្ចដោយការមិនព្រមព្រៀងរបស់ភាគី..........................................................៤៦
៥.អាហារកិច្ចចំពោះសហព័ទ្ធ..........................................................៤៧
៥.១.អាហារកិច្ចដោយការព្រមព្រៀងរបស់ភាគី..........................................................៤៧
៥.២.អាហារកិច្ចដោយការមិនព្រមព្រៀងរបស់ភាគី..........................................................៤៨
**សេចក្តីសន្និដ្ឋាន**..........................................................៤៩
**អនុសាសន៍**..........................................................៥០
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

ការរៀបចំពិធីមង្គលការគឺ ពិធីរៀបអាពាហ៍ពិពាហ៍ រៀបចំការជួបជុំគ្នារវាងបុរស និងស្ត្រី ដែលឈានដល់ដំណាក់កាល ឬរៀបការពេញវ័យ បង្កើតឱ្យមានគម្រោងថ្មី គម្រោងផែនការណ៍បន្តពូជពង្ស បន្តបន្ទាប់ទៀតឡើងជាលក្ខណៈទំនៀមទំលាប់ទំនៀមទម្លាប់ពីបុរាណមក គេអាចកំណត់បាននូវសុខុមាលភាពសម្រាប់សង្គមខ្មែរ ដោយប្រកាសជាសាធារណៈថាបុរស និងស្ត្រីនោះជាប្តីប្រពន្ធនឹងគ្នាដោយដឹងឮដំណឹងពីជនសាធារណៈ និងបងប្អូនប្រុស តាមគោលការណ៍ច្បាប់នៃរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា និងបុរសនារីហួតដល់អាយុក្រោម១៨ឆ្នាំ) មិនអាចរៀបចំអាពាហ៍ពិពាហ៍បានទេ លុះត្រាតែបុរស ឬនារីម្ខាងដល់នីតិភាព និង បុគ្គលម្ខាងទៀតមានអាយុមិនក្រោម ១៦ ឆ្នាំ ហើយមានការយល់ព្រម ពីអ្នកមានអំណាចមេបា ឬអាណាព្យាបាលរបស់អនីតិជននោះ ។ដើម្បីទទួលបានអាពាហ៍ពិពាហ៍ស្របច្បាប់បុរស និងនារីត្រូវបំពេញនីតិវិធីដូចខាងក្រោម ៖ ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ សមីខ្លួនត្រូវដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ទៅកាន់មន្ត្រីអត្រានុកូលដ្ឋានឃុំ/សង្កាត់នៃលំនៅដ្ឋានខាងនារី។ ការប្រកាសជាសាធារណៈ បន្ទាប់ពីដាក់ពាក្យរួចហើយ មន្ត្រីឃុំ/សង្កាត់នឹងចេញប័ណ្ណប្រកាសបិទផ្សាយអាពាហ៍ពិពាហ៍ ដើម្បីយកទៅបិទផ្សាយនៅលំនៅដ្ឋាន និង សាលាឃុំ/សង្កាត់នៃលំនៅស្ថានសមីខ្លួនទាំងសងខាងក្នុងរយៈពេល ១០ថ្ងៃ ដើម្បីឱ្យតតិយជនដែលពាក់ព័ន្ធនៅក្នុងរឿងនេះអាចតវ៉ាបាន។ បន្ទាប់ពីរយៈពេល ១០ ថ្ងៃ ប្រសិនបើពុំមានពាក្យប្តឹងទាស់អ្វីទៅលើអាពាហ៍ពិពាហ៍នេះទេ សមីខ្លួនអាចរៀបអាពាហ៍ពិពាហ៍បាន។ និងចុះសំបុត្រអាពាហ៍ពិពាហ៍សមីខ្លួនទាំងសងខាងត្រូវទៅចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាននៃលំនៅដ្ឋានខាងនារី បន្ទាប់ពីរៀបចំពិធីរួចរាល់ ដោយត្រូវមានបុគ្គលគ្រប់អាយុការចំនួនពីររូបធ្វើជាសាក្សីដើម្បីបញ្ជាក់ពីការដឹងឮលើការចុះកិច្ចសន្យានេះ។

បន្ទាប់មកមន្ត្រីអត្រានុកូលដ្ឋាន ធ្វើការសាកសួរ ស្រង់ព័ត៌មានផ្ទាល់ខ្លួនរបស់ភាគីទាំងសងខាង និងចុះសៀវភៅអាពាហ៍ពិពាហ៍ជូនភាគីទាំងពីរ បន្ទាប់ពីនេះមន្ត្រីអត្រានុកូល ដ្ឋាននឹងប្រគល់ជូនសមីខ្លួនប្តី-ប្រពន្ធនូវសំបុត្រអាពាហ៍ពិពាហ៍ (អេតាស៊ីវិល) ច្បាប់ដើម និងធ្វើសេចក្តីចម្លងតាមការស្នើសុំរបស់សមីខ្លួន សម្រាប់ទុកក្នុងការប្រើប្រាស់។ទន្ទឹមនឹងនោះ ការរស់នៅជាសហព័ន្ធ ហើយបង្កើតជាគ្រួសារ តែងកើតមានជម្លោះ វិវាទកើតមានឡើង ដោយវិវាទខ្លះអាចកើតមានឡើងដែរ តែគូសហព័ន្ធអាចសម្រួលបាន ឬ សម្រុះសម្រួលគ្នាដោយសន្តិវិធីបាន ប៉ុន្តែរាល់ទំនាក់ទំនងទាំងអស់នោះមិនប្រាកដថាអាចនឹងមានវិធីសម្រួលបាន ក្រៅពីការផ្តាច់ទំនាក់ទំនងជាសហព័ន្ធជាគ្នា វិធីលែងលះគ្នាជាទូទៅ គឺការលែងលះគ្នាដោយការ ព្រមព្រៀងគ្នាទៅវិញទៅមក។ តាមវិធីនេះការលែងលះគ្នាត្រូវបាន អនុញ្ញាត នៅពេលដែលភាគីទាំងពីរព្រមព្រៀងលែងលះគ្នាដោយ ស្ម័គ្រចិត្ត។ នៅក្នុងករណីខ្លះ ភាគីទាំងពីររស់នៅជាមួយគ្នាយូរទៅ អស់និស្ស័យជាមួយគ្នា ឬហៅថា លែងមានចិត្តស្រឡាញ់គ្នារៀងៗ ភាគីទាំងពីរ អាចសម្រេចចិត្តលែងលះគ្នាដោយស្ម័គ្រចិត្តដោយគ្មានកំហុសរបស់ភាគីណាមួយ។

ច្បាប់ត្រូវបង្កើតឡើងដោយ ឈរលើទស្សនៈគោរពសិទ្ធិ និងការសម្រេចចិត្តរបស់បុគ្គលជារឿង សំខាន់ ដូច្នេះ បើភាគីទាំងពីរអស់និស្ស័យនឹងគ្នា ឬមិនអាចរស់នៅ ជាមួយគ្នាតទៅទៀតបាន គេមិនអាចបង្ខំមនុស្ស ដែលមិនចង់រស់ នៅជាមួយគ្នាឱ្យបន្តរស់នៅជាមួយគ្នាតទៅទៀតបានទេ ច្បាប់បាន គោរពសេចក្តីសម្រេចចិត្ត របស់ភាគីទាំងពីរ ក្នុងការព្រមព្រៀង លែងលះគ្នា ប៉ុន្តែការព្រមព្រៀងនេះ មិនត្រូវមានការគំរាមកំហែង ការបង្ខិត បង្ខំពីភាគី ឬពីតតិយជនឡើយ។

# ជំពូកទី១
# អាពាហ៍ពិពាហ៍

## ផ្នែកទី១.សញ្ញាណទូទៅនៃអាពាហ៍ពិពាហ៍

អាពាហ៍ពិពាហ៍អាចកើតមានឡើងបានគឺដោយសារតែបុរស និង ស្ត្រីមានសេចក្តីស្រលាញ់ ចំពោះគ្នាទៅវិញទៅមក ហើយមានឆន្ទៈចង់បង្កើតគ្រួសារមួយជាមួយគ្នា និងបានព្រមព្រៀងគ្នាថា នឹងរៀបការហើយបានចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ស្របច្បាប់ជាមួយគ្នា។វាគឺជាច្បាប់ធម្មជាតិ ដែលតំរូវអោយបុរស និងស្ត្រី មានមនោសញ្ចេតនា និងការស្រលាញ់ ដើម្បីមើលថែរក្សាគ្នា ជួយទុក្ខធុរៈ គ្នាទៅវិញទៅមក ព្រមទាំងបង្កើតកូនចៅជំនាន់ក្រោយជាមួយគ្នា។ ដើម្បីអោយរស់នៅជាមួយគ្នាបាន បុរស និង ស្ត្រី ត្រូវចេះជួយបំពេញបន្ថែម និង ពឹងពាក់គ្នា ហើយត្រូវចេះយោគយល់ អធ្យាស្រ័យ អត់អោនអោយគ្នាទៅវិញទៅមក មានន័យថាបុរសត្រូវការស្ត្រី ហើយស្ត្រីក៏ត្រូវការបុរសដែរ។

អាពាហ៍ពិពាហ៍ គឺចំណងផ្លូវច្បាប់ដែលបញ្ជាក់ពីការពឹងពាក់គ្នាទៅវិញទៅមកនៃបុរស និង ស្ត្រី។ អាពាហ៍ពិពាហ៍ គឺជាការរួមចូលគ្នា ខាងសេដ្ឋកិច្ច សង្គម និង មនោសញ្ចេតនាស្នេហា ដ៏ជ្រាលជ្រៅបំផុតដែលនៅក្នុងឧត្តមគតិអនុញ្ញាតអោយបុរស និងស្ត្រីបានចម្រើនលូតលាស់ ជាមួយគ្នា។ អាពាហ៍ពិពាហ៍ គឺជាការរួមគ្នាដើម្បីចិញ្ចឹមបុត្រធីតាអោយក្លាយជាពលរដ្ឋល្អ។

ដោយហេតុថាបុរស និងស្ត្រីពឹងពាក់គ្នាទៅវិញទៅមក និង ដោយហេតុថា កូនពឹងពាក់លើ ឪពុកម្តាយ ជាការសំខាន់ដែលច្បាប់ត្រូវតែបញ្ជាក់អោយបានច្បាស់នូវសិទ្ធិ និង កាតព្វកិច្ចរៀងៗ ខ្លួនរបស់សមាជិកគ្រួសារ។ ដូច្នេះ ទោះបីជានៅក្នុងទិដ្ឋភាពខ្លះ អាពាហ៍ពិពាហ៍ គឺជារឿងដែលមាន ការយកចិត្តទុកដាក់ជាសាធារណៈដែលរដ្ឋាភិបាលត្រូវដាក់កម្រិតជាបញ្ញត្តិតាមរយៈច្បាប់។ ក្រមរដ្ឋប្បវេណីថ្មី ឆ្នាំ២០០៧ ត្រូវបានប្រកាសអោយប្រើប្រាស់ជាផ្លូវការដោយច្បាប់ស្តីពីការអនុវត្ត ក្រមរដ្ឋប្បវេណីកាលពីខែធ្នូ ឆ្នាំ២០១១ បានចូលមកជំនួសច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ចាស់ ដែលត្រូវបានដាក់អោយនិរាករណ៍ដោយច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី។

អាពាហ៍ពិពាហ៍ ជាកិច្ចសន្យាមួយនិង ជាកិច្ចព្រមព្រៀងដែលធ្វើឡើងដោយសេរីរវាង មនុស្សពីរនាក់ដែលមានអានុភាពដល់សិទ្ធិ និង កាតព្វកិច្ចរបស់គេ ហើយដែលរដ្ឋនឹងទទួលស្គាល់ និងបង្គាប់អោយអនុវត្តតាមរយៈប្រព័ន្ធច្បាប់។ ទោះបីជាអាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាមួយបែប ដែលមិនដូចកិច្ចសន្យាដទៃទៀតក៏ដោយក៏ភាគីមិនអាចរំលាយអាពាហ៍ពិពាហ៍តាមទំនើងចិត្តបាន ទេ។ ផ្ទុយទៅវិញ ភាគីអាចត្រឹមតែបញ្ចប់អាពាហ៍ពិពាហ៍របស់គេបានដោយស្របទៅតាមវិធាន និង នីតិវិធីជាក់លាក់ដែលមានចែងនៅក្នុងច្បាប់

ប៉ុណ្ណោះ។ ដូច្នេះ បន្ថែមលើភាពជាកិច្ចសន្យា មួយអាពាហ៍ពិពាហ៍ជាទំនាក់ទំនងយូរអង្វែងតទៅ ដែលស្ថិតនៅរហូតទាល់តែត្រូវបានបញ្ចប់ដោយ ច្បាប់ ឬ ដោយមរណភាពរបស់សហព័ទ្ធណាមួយ។

ដោយហេតុថា អាពាហ៍ពិពាហ៍ជាការប្ដេជ្ញាដ៏មុឹងម៉ាត់ ដែលនឹងកំណត់នូវសិទ្ធិ និង កាតព្វកិច្ចអនាគតរបស់ប្ដី និង ប្រពន្ធ ជាការសំខាន់ដែលភាគីទាំង២ ត្រូវមានសមត្ថភាពនៅពេល ចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ដើម្បីយល់ និងផ្ដល់ការយល់ព្រមចំពោះការប្ដេជ្ញាដែលគេបានធ្វើ។ ដូច្នេះ រដ្ឋាភិបាលបានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការដាក់លក្ខខណ្ឌកម្រិតសម្រាប់ការរៀប អាពាហ៍ពិពាហ៍។

## **១.និយមន័យ**

- អាពាហ៍ពិពាហ៍ អាចសរសេរម៉្យាងទៀតថា អាវាហៈវិវាហៈ អាវាហៈ មានន័យថា ការនាំកូនស្រីមកខាងលំនៅកូនប្រុស វិវាហៈ មានន័យថា ការនាំកូនប្រុសត្រឡប់ទៅខាងលំនៅកូនស្រីវិញ អាវាហៈវិវាហៈ មានន័យថា មង្គលការគូរបុរសស្ត្រីបាននាំមកហើយនាំត្រឡប់ទៅវិញ។ចំណែងអាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាដ៏ឱឡារិកមួយធ្វើឡើងដោយបុរសម្នាក់ និង ស្ត្រីម្នាក់ ដែលប្ដេជ្ញាថាខ្លួននឹងរួមសមគ្គសង្វាសជាមួយគ្នាតាមបញ្ញត្តិច្បាប់ ហើយមិនអាចរំលាយទៅវិញ បានតាមទំនើងចិត្តរបស់ខ្លួនបានឡើយ។
- កំជាប់ពាក្យ សំដៅដល់ពិធីតាមទំនៀមទំលាប់ប្រពៃណីដែលច្បាប់ទទួលស្គាល់ដែល តាមរយៈពិធីនេះ បុរស និង នារី សន្យាថានឹងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានាពេលអនាគត។កំជាប់ពាក្យ ត្រូវបង្កើតឡើងតាមការសន្យារវាងបុរស នារី ថានឹងរៀបអាពាហ៍ពិពាហ៍រវាង គ្នានឹងគ្នា នាពេលអនាគត និង ដោយធ្វើពិធីកំជាប់ពាក្យ ។ ដោយហេតុថា ការសន្យានេះហើយ ទើបធ្វើឲ្យបុរស និង នារីត្រូវធ្វើពិធីកំជាប់ពាក្យ ដើម្បីបញ្ជាក់ថាអ្នកទាំងពីរជាគូនឹងគ្នា ហើយដើម្បីប្រកាសប្រាប់មនុស្សទាំងអស់គ្នាថាបុរស និង នារីនោះមានម្ចាស់រួចហើយ ។កំជាប់ពាក្យ ជាការសន្យារបស់បុរស និងនារី ប៉ុន្តែការសន្យានេះមានលក្ខណៈខុសពីកិច្ច សន្យា មានន័យថាជាគោលការណ៍ បើកិច្ចសន្យាគ្មានវិការៈក្នុងការបង្ហាញឆន្ទៈ ឬ គ្មានកំហុសនោះ ទេ ភាគីត្រូវតែអនុវត្តកិច្ចសន្យា ។

## **២.ទម្រង់ការរៀបអាពាហ៍ពិពាហ៍**

### **២.១.ការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី**

ចំពោះជនជាតិខ្មែរ ពិធីរៀបអាពាហ៍ពិពាហ៍ជាព្រឹត្តិការណ៍សំខាន់បំផុតសម្រាប់ជីវិត។ ពីមុនឪពុកម្ដាយជាអ្នកទុកដាក់កូន ចៅឲ្យមាន គូស្រករ ប៉ុន្តែបច្ចុប្បន្ននេះយុវជន យុវតីខ្មែរភាគច្រើនមានសេរីភាពក្នុងការជ្រើសរើសគូស្រកររបស់ខ្លួន និងធ្វើ ការស្វែងយល់ចិត្តគ្នា មុននឹងឈានដល់ការរៀបអាពាហ៍ពិពាហ៍។ពិធីរៀប

អាពាហ៍ពិពាហ៍ខ្មែរជាពិធីប្រពៃណីមួយដែលតម្រូវឲ្យមានកម្មវិធីជាច្រើនដូចជា សូត្រមន្ត កាត់សក់ ចងដៃ ជាដើម។ ពិធីនេះបានបង្ហាញ ពីវប្បធម៌ដ៏ស្រស់ស្អាតរបស់ជនជាតិខ្មែរ។

**២.២.ការរៀបអាពាហ៍ពិពាហ៍តាមការសែនព្រេន**

ឆ្លងតាមសម័យកាលនីមួយៗទំនៀមទម្លាប់ប្រពៃណីរៀប អាពាហ៍ពិពាហ៍ខ្មែរ ឬ ការរៀបការដោយការសែនព្រេនខ្មែរក៏បានវិវត្តន៍និងសម្របខ្លួនទៅតាមសម័យកាលផង ដែរ។ ដោយសារតែភាពរីកចំរើននៃសង្គមបានផ្លាស់ប្តូរជីវភាពក៏ដូចជា កំរិតចំណេះដឹងប្រជាជនខ្មែរបានផ្លាស់ប្តូរផ្នត់គំនិត និងទម្រង់រៀបការ តាមបែបដូនតាមកសម្រួលឲ្យវាមានលក្ខណៈងាយស្រួល ឆាប់រហ័សជាងមុន។ជាពិសេសខ្មែរបានទទួលឥទ្ធិពលបរទេស មួយចំនួនតាមរយៈកិច្ចការទូត និងតាមរយៈមុខរបររកស៊ីក្នុងពិធី រៀបមង្គលការរបស់ខ្មែរ។ ទោះបីជាវិទ្យាសាស្ត្រមានការរីកចំរើន យ៉ាងណាក៏ដោយ ក៏ប្រជាជនខ្មែរនៅតែរក្សាប្រពៃណីសំខាន់ៗរបស់ ដូនតាខ្មែរដែលបានបន្សល់ទុកឲ្យកូនខ្មែរអនុវត្តន៍ដើម្បីទុកជា ក្បួនច្បាប់។

បច្ចុប្បន្នយើងឃើញថាក្នុងពិធីរៀបមង្គលការរបស់ប្រជាជន ខ្មែរមានការលាយចំរុះនិងវប្បធម៌បរទេសដែលខ្មែរបានទទួលឥទ្ធិពល ពីប្រទេសជិតខាង ហើយខ្មែរក៏បានលុបចោលនូវពិធីមួយចំនួនដែល នាំឲ្យខាតពេលវេលាក្នុងការរកស៊ី និងខាតបង់ប្រាក់ផងដែរ។ដោសារ តែមូលហេតុនេះហើយបានជាប្រពៃណីរៀបមង្គលការខ្មែរយើងមាន លក្ខណៈខុសប្លែកគ្នាជាច្រើនបើធៀបទៅនឹងពិធីរៀបមង្គលការនា សម័យបច្ចុប្បន្ន។ តែមិនមែនខ្មែរលុបចោលនូវពិធីមង្គលការពីដូនតា នោះទេ តែខ្មែរគ្រាន់តែច្នៃវាឲ្យមានភាពងាយស្រួល និងឆាប់រហ័សជាងមុនតែប៉ុណ្ណោះ។

ដូច្នេះហើយការរៀបការដោយការសែនព្រេន ក៏ជាពិធីមួយដែលមានការទទួលស្គាល់ពីសំណាក់ប្រជាជនខ្មែរ ដែលមានការយល់ស្របពីសំណាក់មេបាទាំងសងខាង បងប្អូនសាច់ញាតិ ជាពិសេស គូស្វាមីភរិយាផងដែរ ។

## ផ្នែកទី២.ការបង្កើតអាពាហ៍ពិពាហ៍

ដើម្បីអោយអាពាហ៍ពិពាហ៍ អាចប្រព្រឹត្តទៅបាន ភាគីទាំងពីរ ត្រូវតែអនុវត្ត និង គោរពតាម លក្ខខណ្ឌដែលក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ និងវិធានដទៃទៀតរបស់ព្រះរាជាណាចក្រកម្ពុជា តម្រូវ អោយមានមុននឹងអនុញ្ញាតអោយបុគ្គលទាំងពីរ រៀបអាពាហ៍ពិពាហ៍បាន។ ម្យ៉ាងទៀតដើម្បីអោយ អាពាហ៍ពិពាហ៍មានសុពលភាពកិច្ចអាពាហ៍ពិពាហ៍រវាងបុរស និងស្ត្រីនោះត្រូវតែគោរពតាម លក្ខខណ្ឌគ្រឹះ និង លក្ខខណ្ឌទម្រង់ផងដែរ។

តើអ្វីទៅជាលក្ខខណ្ឌគ្រឹះ និងអ្វីទៅជាលក្ខខណ្ឌទម្រង់? ហើយតើលក្ខខណ្ឌទាំងពីរនេះ មាននីតិវិធីយ៉ាងណាខ្លះចំពោះការបង្កើតអាពាហ៍ពិពាហ៍?

ចំពោះអត្ថន័យ និង ខ្លឹមសារ ក៏ដូចជានីតិវិធីដែលទាក់ទងទៅនឹងលក្ខខណ្ឌទាំងពីរនេះ និង ត្រូវបានបកស្រាយ និង ធ្វើការរៀបរាប់យ៉ាងលម្អិតនៅខាងក្រោមនេះដូចតទៅះ

**កថាខណ្ឌទី១.លក្ខខណ្ឌគ្រឹះនៃអាពាហ៍ពិពាហ៍**

លក្ខខណ្ឌគ្រឹះនៃអាពាហ៍ពិពាហ៍ គឺជាលក្ខខណ្ឌដែលមានមុនពេលរៀបអាពាហ៍ពិពាហ៍ ហើយបានចែងទាក់ទងទៅនឹងលក្ខណៈធម្មជាតិ រួមទាំងលក្ខណៈពាក់ព័ន្ធនឹងសីលធម៌របស់គូភាគី ទាំង២។ ហើយលក្ខខណ្ឌទាំងអស់នោះមានដូចជាះ

**១.ភេទរបស់ភាគី**

ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ បានកំណត់អំពីភេទរបស់ភាគីដែលត្រូវរៀបអាពាហ៍ពិពាហ៍ ត្រូវ តែមានភេទផ្ទុយគ្នា គឺត្រូវតែជាបុរស និង ស្ត្រី។ មាត្រា ៩៤៨ ចែងថា "បុរស និង នារី ដែលមិនទាន់ ដល់នីតិភាព មិនអាចរៀបអាពាហ៍ពិពាហ៍បានឡើយ"។

រដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលរបស់ប្រទេសកម្ពុជា និង ច្បាប់ស្តីពីឯកពន្ធភាព ក៏បាន កំណត់អំពីភេទរបស់ភាគីដែលអាចរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាត្រូវតែជា បុរស និង ស្ត្រី។

ក្រមរដ្ឋប្បវេណី មិនទទួលស្គាល់អ្នកដែលរៀបអាពាហ៍ពិពាហ៍ត្រូវមានភេទដូចគ្នា ឬ ហៅ ថា "ភេទទី៣" នោះទេ។ ប៉ុន្តែបណ្តាប្រទេសជាច្រើនទៀតនៅលើពិភពលោក បានចាប់ផ្តើមទទួល ស្គាល់ និង ផ្តល់សិទ្ធិដល់អ្នកមានភេទដូចគ្នា អាចរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ឬ រស់នៅជាមួយ គ្នាស្របច្បាប់បាន។

នៅក្នុងករណីជាក់ស្តែងខ្លះ នៅក្នុងប្រទេសកម្ពុជាសព្វថ្ងៃ ហើយរហូតដល់មានការចុះផ្សាយ នៅតាមបណ្តាញសារពត៌មានទៀតផងដែរ។មានមនុស្សដែលភេទដូចគ្នាបានរួមរស់ជាមួយគ្នា ដោយខ្លះបានរៀបអាពាហ៍ពិពាហ៍ជាផ្លូវការ និង អ្នកខ្លះមិនមានការរៀបអាពាហ៍ពិពាហ៍ជាមួយ គ្នា ទោះបីជាអាជ្ញាធរមិនទទួលស្គាល់ ឬ មិនបានចុះសំបុត្រអាពាហ៍ពិពាហ៍អោយក៏ដោយ។ ពួកគេ ទាំងអស់នោះស្រលាញ់គ្នា ឬ រស់នៅជាមួយគ្នាតាមរបៀបអនីតិសង្វាស។

ដូចនេះ ការរៀបអាពាហ៍ពិពាហ៍ គឺចាំបាច់ត្រូវធ្វើឡើងជាមួយបុរសម្នាក់ និង នារីម្នាក់ដែល មានភេទផ្ទុយគ្នា ទើបស្របទៅតាមផ្លូវច្បាប់។ ក្នុងករណីដែលមានការរៀបអាពាហ៍ពិពាហ៍ជាមួយ ភេទដូចគ្នានោះ គេចាត់ទុកថាជាអំពើខុសច្បាប់ ហើយវាអាចធ្វើអោយប៉ះពាល់ដល់ទំនៀមទំលាប់ ប្រពៃណីដ៏ល្អរបស់ខ្មែរផងដែរ។

**២.អាយុសំរាប់រៀបអាពាហ៍ពិពាហ៍**

បុរស និងស្ត្រីដែលចង់រៀបអាពាហ៍ពិពាហ៍ ត្រូវតែមានអាយុពេញលេញតាមការកំណត់ របស់ច្បាប់ ប៉ុន្តែមានករណីលើកលែងមួយចំនួនតាមបញ្ញាត្តិច្បាប់។ នៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ បានចែងតម្រូវអោ

យបុរស និង ស្ត្រីមានសិទ្ធិរៀបអាពាហ៍ពិពាហ៍ ត្រូវមានអាយុចាប់ពី ១៨ ឆ្នាំឡើងទៅដូចគ្នា ដោយមិនបែងចែករវាងបុរស និង ស្ត្រីឡើយ ដោយហេតុថាបុរស និង ស្ត្រីមាន សិទ្ធិស្មើគ្នា[1]។

ការដែលក្រមរដ្ឋប្បវេណីថ្មី ដែលបានកំណត់អាយុសម្រាប់អ្នកដែលមានសិទ្ធិរៀប អាពាហ៍ពិពាហ៍ត្រឹម ១៨ឆ្នាំនេះ គឺដោយសារទំនោររបស់ប្រទេសជាច្រើន និង ដោយផ្អែកលើស្មារតី នៃអនុសញ្ញាអន្តរជាតិ ស្តីពីការលុបបំបាត់ចោលនូវរាល់ទម្រង់នៃការរើសអើងស្ត្រី និង ខ្លឹមសាររដ្ឋ ធម្មនុញ្ញរបស់ប្រទេសកម្ពុជា។ ជាពិសេស ការរីកចម្រើននៃវ័យរបស់មនុស្ស ការផ្លាស់ប្តូរនូវវ័យ របស់មនុស្ស ដែលមនុស្សកាន់តែមានអាយុតិចឡើង មានការទទួលខុសត្រូវ និង ការរួមភេទ ជាមួយគ្នា។

**៣.ការរៀបអាពាហ៍ពិពាហ៍របស់អនីតិជន**

ភាគីដែលជាអនីតិជនដែលមិនទាន់គ្រប់អាយុ១៨ឆ្នាំ តែត្រូវមានអាយុយ៉ាងតិច១៦ឆ្នាំ ឡើងទៅ ទើបច្បាប់អនុញ្ញាតអោយរៀបអាពាហ៍ពិពាហ៍បាន និង មានលក្ខខណ្ឌមួយចំនួនដូចខាង ក្រោម៖

- អនីតិជនអាចរៀបអាពាហ៍ពិពាហ៍ជាមួយនីតិជនបាន។

នៅក្នុងករណីដែលភាគីម្ខាងបានឈានដល់នីតិភាព (មានអាយុ១៨ឆ្នាំយ៉ាងតិច) ហើយភាគី ម្ខាងទៀតជាអនីតិជនដែលមានអាយុមិនតិចជាង១៦ឆ្នាំ អាចរៀបអាពាហ៍ពិពាហ៍បាន បើមាន ការយល់ព្រមពីអ្នកដែលមានអំណាចមេបា (ឪពុកម្តាយ) ឬ អ្នកអាណាព្យាបាលរបស់អនីតិ ជន។

- អនីតិជនអាចរៀបអាពាហ៍ពិពាហ៍ជាមួយអនីតិជនដែលទទួលបានអគ្គាធីនភាព។

នៅក្នុងករណីដែលភាគីម្ខាងបានឈានដល់នីតិភាពដោយការទទួលបានអគ្គាធីនភាពតាម មាត្រា២១ នៃក្រមរដ្ឋប្បវេណី (មានអាយុពី១៦ឆ្នាំដល់ក្រោម១៨ឆ្នាំ) ហើយភាគីម្ខាងទៀតជា អនីតិជន ដែលមានអាយុមិនតិចជាង១៦ឆ្នាំ អាចរៀបអាពាហ៍ពិពាហ៍បាន បើមានការយល់ ព្រមពីអ្នកដែលមានអំណាចមេបា (ឪពុកម្តាយ) ឬ អ្នកអាណាព្យាបាលរបស់អនីតិជន។

**៤.ការរៀបអាពាហ៍ពិពាហ៍របស់ជននៅក្រោមអាណាព្យាបាលទូទៅ**

ជននៅក្រោមអាណាព្យាបាល (ជនវិកលចរិត) ហើយដែលជានីតិជន ច្បាប់អនុញ្ញាតអោយ ជនប្រភេទនេះ ក៏អាចរៀបអាពាហ៍ពិពាហ៍បានដែរ ប្រសិនបើជននេះមានសមត្ថភាពក្នុងការបង្ហាញ ឆន្ទៈចង់រៀបអាពាហ៍ពិពាហ៍ ក្នុងកម្រិតអប្បបរមាដែលគេអាចទទួលយកបាន។ជនវិកលចរិត ដែលចង់រៀបអាពាហ៍ពិពាហ៍អាចសម្រេចចិត្តដោយខ្លួនឯងផ្ទាល់បាន គេត្រូវគោរពសេចក្តីសម្រេចចិត្តនោះ ហើយអាពាហ៍ពិពាហ៍អាចប្រព្រឹត្តទៅបាន ដោយមិនចាំបាច់ មានការយល់ព្រមពីអ្នកអាណាព្យាបាលទូទៅដែលគ្រប់គ្រងជនវិកលចរិតនោះទេ[2]។

---

[1] មាត្រា ៩៤៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[2] មាត្រា ៩៥៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

**៥.ការយល់ព្រមលើការរៀបអាពាហ៍ពិពាហ៍**

បុគ្គលដែលមានបំណងរៀបអាពាហ៍ពិពាហ៍ ទោះបីជានីតិជន ឬ អនីតិជន ត្រូវមាន ការយល់ព្រមរវាង ក្រុមគ្រួសារ និង សាមីខ្លួន ដែលត្រូវគោរពនូវគោលការណ៍ដូចខាង ក្រោមនេះ៖

- បុគ្គលដែលជានីតិជន មានបំណងរៀបអាពាហ៍ពិពាហ៍ ច្បាប់មិនតម្រូវអោយមានការយល់ព្រមពីអ្នកដែលមានអំណាចមេបា (ឪពុកម្ដាយ) ឬ អ្នកអាណាព្យាបាលរបស់ខ្លួនឡើយ។
- បុគ្គលដែលជាអនីតិជន មានបំណងរៀបអាពាហ៍ពិពាហ៍ទាមទារអោយមានការយល់ព្រមពីអ្នកដែលមានអំណាចមេបាទាំងពីរ ប៉ុន្តែបើអ្នកដែលមានអំណាចមេបាម្ខាងមិនយល់ព្រមទេ គឺច្បាប់អនុញ្ញាតអោយអ្នកដែលមានអំណាចមេបាតែម្ខាងយល់ព្រម ឬ អ្នកអាណាព្យាបាល របស់អនីតិជនយល់ព្រមក៏បានដែរ។
- ក្នុងករណីអនីតិជន មានបំណងរៀបអាពាហ៍ពិពាហ៍ ហើយអ្នកដែលមានអំណាចមេបា ឬ អ្នកអាណាព្យាបាលរបស់អនីតិជនមិនយល់ព្រមដោយគ្មានមូលហេតុសមរម្យ ហើយអនីតិជន នៅតែមានបំណងរៀបអាពាហ៍ពិពាហ៍អនីតិជនអាចស្នើសុំទៅតុលាការ ដើម្បីសម្រេច ជំនួសអ្នកដែលមានអំណាចមេបា ឬ អ្នកអាណាព្យាបាលរបស់អនីតិជនបាន។

អត្តាធិនភាព សំដៅដល់ស្ថានភាពមួយដែលផ្ដល់អោយអនីតិជនបានរួចផុតពីអាណា ព្យាបាលសម្រាប់អនីតិជន ឬ រួចផុតពីអំណាចមេបា ហើយមានសមត្ថភាពដូចនីតិជនដែរ។

**៦.ការយល់ព្រមចំពោះការរៀបអាពាហ៍ពិពាហ៍នៅពេលសហព័ទ្ធអវត្តមានឬការបាត់ខ្លួន**

ករណីសហព័ទ្ធណាម្នាក់អវត្តមាន ឬ បាត់ខ្លួនធ្វើអោយសហព័ទ្ធម្ខាងទៀតដែលនៅរស់ មានការលំបាកក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិ ក៏ដូចជាកូននៅក្នុងបន្ទុក ជាពិសេសការសម្រេចចិត្ត ដើម្បីរៀបអាពាហ៍ពិពាហ៍ថ្មីទៀត។

អវត្តមាន សំដៅដល់បុគ្គលណាម្នាក់ដែលបានចេញពីលំនៅឋាន ដែលគ្មានបំណងនឹងត្រឡប់មកវិញឡើយ ។

ការបាត់ខ្លួន គឺជាព្រឹត្តិការណ៍ទាំងឡាយដែលអាចឱ្យគេសន្និដ្ឋានថា ជននោះបានបាត់បង់ ជីវិតពិតប្រាកដ។ ព្រឹត្តិការណ៍ទាំងនោះជាស្ថានភាពដែលបង្កឱ្យមានលក្ខណៈធ្ងន់ធ្ងរដល់អាយុជីវិត ដូចជាការលិចលង់នាវាក្នុងសមុទ្រ សង្គ្រាម ធ្លាក់យន្តហោះរញ្ជួយដី អគ្គីភ័យ។ល។ ទោះបីជា សាកសពរកមិនឃើញក៏ដោយ តែតាមពត៌មានដែលទទួលបានគេអាចសន្និដ្ឋានបានថា ជននោះ ពិតជាស្លាប់។

ក្នុងករណីដែលបុគ្គលបានអវត្តមាន ឬ បាត់ខ្លួន ដែលគេគ្មានសង្ឃឹមថា នឹងត្រលប់មកវិញ សហព័ទ្ធម្ខាងទៀតអាចនឹងរៀបអាពាហ៍ពិពាហ៍ថ្មីទៀតបានដូចតទៅ:

**៦.១.បុគ្គលអវត្តមានលើសពី៥ឆ្នាំ**

ក្នុងករណីអ្នកដែលអវត្តមាននោះ មានរយៈពេលលើសពី ៥ឆ្នាំទៅ ហើយគេពុំមានដំណឹង ច្បាស់លាស់ថា អ្នកដែលអវត្តមាននោះនៅរស់ ឬ ទទួលមរណភាពទេ សហព័ទ្ធដែលនៅរស់ ឬ ឪពុកម្តាយ ឬ អ្នកអាណាព្យាបាល ឬ អ្នកមានផលប្រយោជន៍ផ្សេងទៀត អាចស្នើសុំទៅតុលាការ ដើម្បីប្រកាសអំពីការបាត់ខ្លួនរបស់អ្នកដែលអវត្តមានយូរនេះបាន ហើយសហព័ទ្ធដែលនៅរស់អាច នឹងរៀបអាពាហ៍ពិពាហ៍ជាមួយប្តី ឬ ប្រពន្ធថ្មីបានក្រោយពេលតុលាការប្រកាសសាលក្រមអំពីការ បាត់ខ្លួននេះ។

**៦.២.បុគ្គលបាត់ខ្លួនក្រោយជួបឧបទ្ទវហេតុលើសពី១ឆ្នាំ**

ក្នុងករណីបុគ្គលដែលបានជួបនឹងឧបទ្ទវហេតុដូចជា ចូលទៅក្នុងតំបន់សង្គ្រាម លិចនាវា ការរញ្ជួយផែនដី អគ្គិភ័យ ស៊ូណាមី ជាដើម ហើយពុំមានដំណឹងច្បាស់លាស់ថា បុគ្គលនោះនៅ រស់ ឬ ទទួលមរណភាពដែលមានរយៈពេលលើសពី១ឆ្នាំទៅ ក្រោយពីជួបឧបទ្ទវហេតុនោះ។ តុលាការអាចប្រកាសអំពីការបាត់ខ្លួនរបស់បុគ្គលនោះ តាមពាក្យសុំរបស់សហព័ទ្ធដែលនៅរស់ ឬ ឪពុកម្តាយ ឬ អ្នកអាណាព្យាបាល ឬ បុគ្គលមានផលប្រយោជន៍ផ្សេងទៀត ហើយសហព័ទ្ធដែល នៅរស់ អាចនឹងរៀបអាពាហ៍ពិពាហ៍ជាមួយប្តី ឬ ប្រពន្ធថ្មីបានក្រោយពេលតុលាការប្រកាសសាល ក្រមអំពីការបាត់ខ្លួននេះ។ ទោះបីបុគ្គលដែលត្រូវបានតុលាការប្រកាសអំពីការបាត់ខ្លួននោះ នៅរស់ ហើយត្រឡប់មកវិញក៏ដោយក្នុងករណីដែលភាគីម្ខាងទៀត បានរៀបអាពាហ៍ពិពាហ៍ជាមួយប្តី ឬ ប្រពន្ធថ្មីហើយ បុគ្គលដែលនៅរស់នោះ មិនអាចប្តឹងលុបអាពាហ៍ពិពាហ៍ថ្មីនោះបានទេ ហើយអាពាហ៍ពិពាហ៍ថ្មីនោះ មានអានុភាពលុបអាពាហ៍ពិពាហ៍មុន[3]។

ក្រមរដ្ឋប្បវេណី បានអនុញ្ញាតឱ្យការបាត់ខ្លួនរបស់សហព័ទ្ធណាមួយបញ្ចប់អាពាហ៍ពិពាហ៍ ពីមុនដោយមានហេតុផលយ៉ាងតិច ២ យ៉ាង។ ទី១ ច្បាប់បានផ្តល់ដល់សហព័ទ្ធដែលមិនបាត់ខ្លួន និង កូនណាមួយមានឱកាសចាប់ផ្តើមជីវិតថ្មីបាន។ ទី ២ ច្បាប់ផ្តល់ដល់គូភាគីដែលបានរៀប អាពាហ៍ពិពាហ៍ជាលើកទី ២ ថាការរៀបអាពាហ៍ពិពាហ៍របស់គេពិតជាមានលក្ខណៈត្រឹមត្រូវ តាមច្បាប់។ ជាការពិត នៅក្នុងក្រមរដ្ឋប្បវេណីរបស់ប្រទេសកម្ពុជា ការវិនិច្ឆ័យថាសហព័ទ្ធមុនបាន "បាត់ខ្លួនពិតមែន" មិនអាចធ្វើការកែប្រែបានទេ។ ទោះបីបានសហព័ទ្ធដែលបាត់ខ្លួននោះ នៅពេល ក្រោយមក បានវិលត្រលប់មកវិញក៏ដោយ ក៏គេមិនអាចប្តឹងជំទាស់សេចក្តីសម្រេចរបស់តុលាការពី មុនបានទេ។

**កថាខណ្ឌទី២.លក្ខខណ្ឌទម្រង់នៃអាពាហ៍ពិពាហ៍**

[3] មាត្រា ៩៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

លក្ខខណ្ឌទម្រង់នៃអាពាហ៍ពិពាហ៍ គឺជាលក្ខខណ្ឌដែលច្បាប់បានកំណត់នឹងតម្រូវអោយគូ ភាគីទាំងពីរ អនុវត្តតាមនីតិវិធីនោះអោយត្រឹមត្រូវ ដើម្បីអោយអាពាហ៍ពិពាហ៍មានសុពលភាព និង អាចប្រព្រឹត្តទៅបានត្រឹមត្រូវតាមច្បាប់។ នៅក្នុងលក្ខខណ្ឌទម្រង់នេះផងដែរ មានលក្ខខណ្ឌតូចៗ ជាច្រើនទៀត ដូចជា៖

**១.ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍**

មុនពិធីរៀបអាពាហ៍ពិពាហ៍ បុរស និង ស្ត្រី ដែលមានបំណងរៀបអាពាហ៍ពិពាហ៍នឹងគ្នា ត្រូវ ធ្វើលិខិតបញ្ជាក់ពីឃុំ សង្កាត់ ខាងលំនៅរបស់ភាគីរៀងៗខ្លួនអំពីភាពនៅលីវ ឬមេម៉ាយ ឬ ពោះម៉ាយ ដោយមិនមានការជាប់ជំពាក់ជាមួយបុគ្គលណាផ្សេងទៀយ។

ក្រោយពីទទួលបានលិខិតបញ្ជាក់នេះហើយ ដោយមានទាំងឪពុកម្ដាយនៅរស់ ឬ អាណា ព្យាបាលរួមជាមួយផង ត្រូវដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍នៅខាងឃុំ ឬ សង្កាត់នៃលំនៅដ្ឋាន ភា គីខាងស្រីរស់នៅ។ ក្រោយពីមេឃុំ ឬ ចៅសង្កាត់ទទួលពាក្យស្នើសុំនោះហើយ ក្នុងឋានៈលោកជា មន្ត្រីអត្រានុកូលដ្ឋាន ត្រូវចេញលិខិតអនុញ្ញាតអោយរៀបអាពាហ៍ពិពាហ៍ និងចេញប័ណ្ណប្រកាស សម្រាប់ការរៀបអាពាហ៍ពិពាហ៍អោយទៅភាគីទាំងពីរយកទៅបិទផ្សាយជាសាធារណៈទៀតផង[4]។

**២.ប័ណ្ណប្រកាសជាសាធារណៈ**

ការបិទប្រកាសនេះ មានគោលដៅបង្កលទ្ធភាពដល់ជនដែលមានប្រយោជន៍នៅក្នុងរឿង នេះដឹងឮ ហើយអាចប្ដឹងទាស់នឹងអាពាហ៍ពិពាហ៍នេះបាន ប្រសិនបើមានការមិនយល់ព្រម ឬ ក៏ការ រៀបអាពាហ៍ពិពាហ៍នោះប៉ះពាល់ដល់សិទ្ធិ និង ផលប្រយោជន៍ស្របច្បាប់របស់ខ្លួន ហើយត្រូវបាន ច្បាប់ការពារសិទ្ធិ និង ផលប្រយោជន៍ទាំងនោះ។

មេឃុំ ចៅសង្កាត់ដែលមានមុខងារជាមន្ត្រីអត្រានុកូលដ្ឋាននៅក្នុងឃុំសង្កាត់ខាងស្រី រស់នៅ ជាអ្នកចេញសេចក្ដីសម្រេចអនុញ្ញាតឱ្យរៀបអាពាហ៍ពិពាហ៍ និង ជាអ្នកចេញប័ណ្ណប្រកាស ការរៀបអាពាហ៍ពិពាហ៍។ ប័ណ្ណប្រកាសជាសាធារណៈនៃអាពាហ៍ពិពាហ៍ដែលមានគម្រោងនឹង រៀបអាពាហ៍ពិពាហ៍ ត្រូវតែបិទផ្សាយក្នុងរយៈពេល ១០ ថ្ងៃ នៅលំនៅឋានខាងស្រី និង នៅសាលាឃុំសង្កាត់ខាងស្រី ហើយប័ណ្ណប្រកាសពីរទៀត ត្រូវផ្ញើទៅមន្ត្រីអត្រានុកូលដ្ឋានឃុំ ឬ សង្កាត់ខាង បុរស ដើម្បីយកទៅបិទនៅលំនៅបុរស និង សាលាឃុំ ឬ សង្កាត់របស់ខ្លួន[5]។

ប័ណ្ណប្រកាសត្រូវតែមានចុះពត៌មានដូចខាងក្រោម៖

- នាមត្រកូល នាមខ្លួន អាយុ មុខរបរ និង ទីលំនៅដ្ឋានរបស់អនាគតប្ដី និង ប្រពន្ធ

[4] មាត្រា ៩៥៥ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[5] មាត្រា ១៣ នៃច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និង គ្រួសារ

❖ នាមត្រកូល នាមខ្លួន អាយុ មុខរបរ និង ទីលំនៅដ្ឋានរបស់ឪពុកម្តាយនៃអនាគតប្តីប្រពន្ធ។

បើឪពុកម្តាយណាមួយស្លាប់ ត្រូវដាក់ថា "ស្លាប់"។ ដាក់រយៈពេលកំនត់ អោយភាគីដែលពាក់ព័ន្ធអាចប្តឹងជំទាស់នឹងអាពាហ៍ពិពាហ៍បានរយៈពេល១០ថ្ងៃគិតចាប់ពីថ្ងៃបិទប័ណ្ណប្រកាសផ្សាយជាសាធារណៈ ។

**៣.រយៈពេលរង់ចាំ**

ភាគីទាំងពីរដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ត្រូវរង់ចាំរយៈពេល១០ថ្ងៃ បន្ទាប់ពីថ្ងៃបិទ ផ្សាយប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ជាសាធារណៈ ហើយបើក្នុងរយៈពេល១០ថ្ងៃនេះ គ្មាននរណា ប្តឹងជំទាស់នឹងអាពាហ៍ពិពាហ៍របស់ពួកគេទេ នោះពិធីរៀបអាពាហ៍ពិពាហ៍អាចប្រព្រឹត្តទៅបាន។ ប៉ុន្តែបើមានបណ្តឹងទាស់ ការរៀបអាពាហ៍ពិពាហ៍នោះមិនអាចប្រព្រឹត្តទៅបានទេ ប្រសិនបើបណ្តឹង ទាស់នោះមិនត្រូវបានដោះស្រាយចប់។

**៤.ជនអាចប្តឹងជំទាស់អាពាហ៍ពិពាហ៍**

បើសិនមានជនណាម្នាក់ដាក់ពាក្យប្តឹងជំទាស់ទៅនឹងគម្រោងរៀបអាពាហ៍ពិពាហ៍ មន្ត្រីនៃ ស្ថាប័នពាក់ព័ន្ធត្រូវដោះស្រាយបណ្តឹងនោះអោយចប់សព្វគ្រប់សិន ទើបអាចរៀបអាពាហ៍ពិពាហ៍ បាន។ ជនដែលមានប្រយោជន៍ អាចជាសាច់ញាតិ ឪពុកម្តាយ ឬ អ្នកអាណាព្យាបាល ឬ តតិយ ជនណាម្នាក់ដែលអាចមានការពាក់ព័ន្ធជាមួយអាពាហ៍ពិពាហ៍ដោយផ្ទាល់ ដូចជាភាគីដែលគ្រោង រៀបអាពាហ៍ពិពាហ៍ធ្លាប់ជាប្តីប្រពន្ធរបស់ខ្លួន ហើយមកលួចរៀបអាពាហ៍ពិពាហ៍ជាថ្មី ឬ ធ្លាប់រស់ នៅជាមួយគ្នាពីមុន ដោយមិន បានរៀបអាពាហ៍ពិពាហ៍ជាដើម អាចប្តឹងជំទាស់គម្រោង អាពាហ៍ពិពាហ៍ក្នុងចន្លោះ១០ថ្ងៃ ចាប់ពីការបិទប័ណ្ណប្រកាសអំពីអាពាហ៍ពិពាហ៍ដែលគ្រោងនឹង រៀបចំនេះ។

**៥.មូលហេតុជំទាស់នឹងគម្រោងអាពាហ៍ពិពាហ៍**

អត្រានុកូលដ្ឋាន មានសិទ្ធិបដិសេធមិនទទួលយកសំណើសុំរៀបអាពាហ៍ពិពាហ៍បាន ក្នុងករណីមានមូលហេតុណាមួយដូចខាងក្រោមនេះ ៖

- អនាគតប្តី ឬ ប្រពន្ធមិនទាន់ដល់នីតិភាព (អាយុក្រោម១៨ឆ្នាំ) ឬ ក្នុងករណីដែលភាគីម្ខាងបានដល់នីតិភាព ហើយភាគីម្ខាងទៀតមានអាយុក្រោម ១៦ឆ្នាំ។
- ករណីភាគីមានសហព័ទ្ធហើយ (មានប្តី ឬ ប្រពន្ធ)។
- អំឡុងពេលហាមឃាត់មិនអោយរៀបអាពាហ៍ពិពាហ៍ថ្មីទៀត ក្នុងករណីដែលនារីត្រូវបានរំលាយ ឬ លុបចោលអាពាហ៍ពិពាហ៍មុន ហើយនៅមិនទាន់គ្រប់រយៈ១២០ថ្ងៃ។

ករណីដែលអាពាហ៍ពិពាហ៍បានធ្វើឡើងរវាងញាតិលោហិតផ្ទាល់ ឬ សាខាញាតិលោហិត។ ករណីដែលអាពាហ៍ពិពាហ៍គ្រោងធ្វើឡើងរវាងញាតិពន្ធនៃខ្សែផ្ទាល់ ឬ អាពាហ៍ពិពាហ៍គ្រោងធ្វើឡើងរវាងសាខាញាតិពន្ធ។

- អាពាហ៍ពិពាហ៍របស់អនីតិជនដែលមិនមានការយល់ព្រមពីអ្នកដែលមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន។ អាពាហ៍ពិពាហ៍របស់ជនវិកលចរិត (ជននៅក្រោមអាណាព្យាបាលទូទៅ) ដែលមិនមាន សមត្ថភាពក្នុងការបង្ហាញឆន្ទៈក្នុងកម្រិតអប្បបរមាបាន។

នៅក្នុងករណីទាំងអស់ខាងលើនេះ មន្ត្រីអត្រានុកូលដ្ឋានមានសិទ្ធិមិនអនុញ្ញាតអោយរៀប អាពាហ៍ពិពាហ៍ ឬ មានសិទ្ធិប្តឹងជំទាស់មិនអោយរៀបអាពាហ៍ពិពាហ៍បាន[6]។

## ៦.ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍

ក្រោយពេលរៀបអាពាហ៍ពិពាហ៍ ហើយ ដំណាក់កាលចុងក្រោយក្នុងការបង្កើតអោយមានអាពាហ៍ពិពាហ៍ស្របច្បាប់មួយដែលទទួលស្គាល់ដោយច្បាប់ គឺ "ការចុះបញ្ជីអាពាហ៍ពិពាហ៍នៅ ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន" ខាងលំនៅឋានរបស់នារី។ នីតិវិធីបែបនេះអ្នកខ្លះហៅថា "ការចុះ អេតាស៊ីវិល"។ អនុក្រឹត្យលេខ ១០៣ អនក្រប.ក ស្តីពីអត្រានុកូលដ្ឋានចែងថា អនាគតប្តីប្រពន្ធ រួម ទាំងសាក្សី ២នាក់ ដែលមានអាយុឈានដល់នីតិភាព ត្រូវចុះកិច្ចសន្យាអាពាហ៍ពិពាហ៍នៅចំពោះ មុខមន្ត្រីអត្រានុកូលដ្ឋាន ១រូប ហើយមន្ត្រីអត្រានុកូលដ្ឋានត្រូវចុះកិច្ចសន្យានោះ ក្នុងសៀវភៅ អាពាហ៍ពិពាហ៍របស់ឃុំសង្កាត់ ហើយភាគីត្រូវផ្តិតមេដៃ។ មន្ត្រីអត្រានុកូលដ្ឋានត្រូវចុះហត្ថលេខា និងបោះត្រាលើសៀវភៅនោះផងដែរ។

ទោះជាយ៉ាងណា អនាគតប្តី ឬប្រពន្ធត្រូវបញ្ជាក់ប្រាប់មន្ត្រីអត្រានុកូលដ្ឋានថា "អាពាហ៍ពិពាហ៍របស់គេធ្វើឡើងដោយស្ម័គ្រចិត្ត"។ ពិធីខាងសាសនាពុំមានលក្ខណចាំបាច់ ដែលតម្រូវអោយធ្វើដូចជាបណ្តាប្រជាជនដែលកាន់សាសនាគ្រិស្តនោះឡើយ ហើយដែលពិធីខាង សាសនា ត្រូវបានគេរៀបចំធ្វើក្នុងពិធីរៀបអាពាហ៍ពិពាហ៍រួចហើយ។ ការនេះពុំមែនមានន័យថា ពិធី ទាំងខាងសាសនានោះ គ្មានសារៈសំខាន់ត្រូវបានគេបំភ្លេចចោល ឬ មើលរំលងនោះទេ ការពិតវា មានសារៈសំខាន់យ៉ាងខ្លាំង ហើយដែលគេបានរៀបចំក្នុងពិធីរៀបអាពាហ៍ពិពាហ៍រួចហើយ។

## ៧.ការចេញសំបុត្រអាពាហ៍ពិពាហ៍

នៅក្រោយពេលសាមីខ្លួន អនាគតប្តីនិងប្រពន្ធបានមករាយការណ៍សុំចុះសៀវភៅ អាពាហ៍ពិពាហ៍ ហើយមន្ត្រីអត្រានុកូលដ្ឋានត្រូវចុះសៀវភៅអាពាហ៍ពិពាហ៍ បន្ទាប់មកត្រូវប្រគល់ អោយសាមីខ្លួនប្តីប្រពន្ធនូវសំបុត្រមួយហៅថា "សំបុត្រអាពាហ៍ពិពាហ៍" ជាច្បាប់ដើមមួយច្បាប់និង "សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍" មួយចំនួនទៀតតាមការស្នើសុំរបស់ភាគី។

[6] មាត្រា ៩៥៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

នៅក្នុង "សំបុត្រអាពាហ៍ពិពាហ៍" មានចុះឈ្មោះរបស់សហព័ទ្ធ ថ្ងៃខែឆ្នាំកំណើត ទីកន្លែង កំណើត ថ្ងៃខែឆ្នាំចុះសំបុត្រអាពាហ៍ពិពាហ៍ជាដើម។ "សំបុត្រអាពាហ៍ពិពាហ៍" នេះមានសារៈសំខាន់ ខ្លាំង ដើម្បីបញ្ជាក់ធម្មានុរូបនៃប្តីប្រពន្ធដែលកើតចេញពីអាពាហ៍ពិពាហ៍ដែលត្រឹមត្រូវតាមច្បាប់។

## កថាខណ្ឌទី៣.លក្ខខណ្ឌហាមឃាត់ការរៀបអាពាហ៍ពិពាហ៍

ក្រមរដ្ឋប្បវេណីថ្មី បានហាមឃាត់មិនអោយរៀបអាពាហ៍ពិពាហ៍សម្រាប់លក្ខខណ្ឌមួយ ចំនួនដូចខាងក្រោមៈ

### ១.ការហាមមិនឱ្យមានទ្វេពន្ធភាព

បុគ្គលដែលមានប្តី ឬប្រពន្ធហើយចំណងអាពាហ៍ពិពាហ៍នោះនៅមានសុពលភាពនៅ ឡើយ ឬ មិនទាន់លែងលះគ្នាដាច់ស្រឡះ។ ហើយចង់រៀបអាពាហ៍ពិពាហ៍ប្តី ឬ ប្រពន្ធថ្មីមួយទៀត ក្រមរដ្ឋប្បវេណី មិនអនុញ្ញាតឱ្យរៀបអាពាហ៍ពិពាហ៍បានឡើយ[7]។

ការចែងរបៀបនេះ គឺស្របជាមួយរដ្ឋធម្មនុញ្ញសព្វថ្ងៃ ដែលច្បាប់កំពូលរបស់ព្រះរាជាណា ចក្រកម្ពុជាត្រង់មាត្រា ៤៥ ដែលមានគោលបំណងសំខាន់ក្នុងការលុបបំបាត់ការរើសអើងប្រឆាំង នឹងស្ត្រីភេទ។ មាត្រានេះចែងថា "បុរស និងស្ត្រីមានសិទ្ធិស្មើគ្នាលើគ្រប់វិស័យ ជាពិសេសក្នុងអាពាហ៍ពិពាហ៍ និង គ្រួសារ។ អាពាហ៍ពិពាហ៍ ត្រូវធ្វើឡើងតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ និង តាមគោលការណ៍ស្ម័គ្រចិត្ត ប្តីមួយប្រពន្ធមួយៗ។

ទោះបីជារដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូល និង ក្រមរដ្ឋប្បវេណីបច្ចុប្បន្ន បានហាមឃាត់មិន ឱ្យបុរស ឬ ស្ត្រី មានប្តី ឬ ប្រពន្ធ ២ ឬ ៣ យ៉ាងដូច្នេះក៏ដោយ ប៉ុន្តែការរស់នៅក្នុងសង្គមជាក់ស្តែងរៀបអាពាហ៍ពិពាហ៍ តែអ្នកខ្លះទៀតមិនបានរៀបអាពាហ៍ពិពាហ៍ត្រឹមត្រូវ ហើយភាគីខាងស្ត្រីព្រម ព្រៀងរស់នៅជាមួយគ្នា ដោយមិនប្តឹងផ្តល់។

បញ្ចប់ដោយមរណភាព លែងលះ ឬ មោឃអាពាហ៍ពិពាហ៍រវាងប្តីមួយប្រពន្ធច្រើននាក់ ឬ ប្តីច្រើន នាក់ប្រពន្ធមួយនេះគឺហាមចំពោះអាជ្ញាធរមិនត្រូវចេញលិខិតអនុញ្ញាតឱ្យរៀបអាពាហ៍ពិពាហ៍របៀបជាមួយគ្នាបាន តែច្បាប់មិនមានចែងថា ការមានប្តី ឬ ប្រពន្ធច្រើនជាការខុសច្បាប់ ហើយមិនត្រូវ មានទោសឡើយ លើកលែងតែមានការប្តឹងផ្តល់ពីភរិយាដើម។

[7] មាត្រា ៩៤៩ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

## ២.អំឡុងពេលហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ថ្មី

ភាពនៃអាពាហ៍ពិពាហ៍នោះ បុរសម្នាក់អាចរៀបអាពាហ៍ពិពាហ៍ជាថ្មីម្តងទៀត នៅពេលណា ក៏បាន ក្រោយការបញ្ចប់អាពាហ៍ពិពាហ៍មុន។ ទោះជាយ៉ាងណាក៏ដោយស្ត្រីដែលមានបំណង ចង់រៀបអាពាហ៍ពិពាហ៍ម្តងទៀត ត្រូវរង់ចាំ ១២០ថ្ងៃ បន្ទាប់ពីការបញ្ចប់អាពាហ៍ពិពាហ៍លើកមុន[8]។

បើសិនជាតុលាការបានសម្រេចឱ្យប្តីប្រពន្ធលែងលះតាមផ្លូវច្បាប់ មុនពេលសម្រេចឱ្យលែង លះគ្នា រយៈពេលរង់ចាំត្រូវរាប់ចាប់តាំងពីថ្ងៃមានសាលក្រម ឬ សាលដីកាឱ្យនៅបែកគ្នា។ ច្បាប់ តម្រូវឱ្យស្ត្រីរង់ចាំ ១២០ថ្ងៃ ដើម្បីកំណត់បិតុភាពនៃកូនដែលលកើតនៅក្នុងឆ្នាំបន្ទាប់ពីការបញ្ចប់ អាពាហ៍ពិពាហ៍លើកមុន។ ប្រសិនបើស្ត្រីម្នាក់បានរៀបអាពាហ៍ពិពាហ៍ឆាប់រហ័សពេក ក្រោយការ បញ្ចប់អាពាហ៍ពិពាហ៍លើកមុនរបស់ខ្លួន ហើយកូនដែលកើតមកក្រោយពេលរៀបអាពាហ៍ពិពាហ៍ថ្មី ហើយ ធ្វើឱ្យកើតមានបញ្ហាស្តីពីការកំណត់បិតុភាពរបស់កូននោះថា ជាកូនរបស់ប្តីមុន ឬ ជាកូន របស់ប្តីក្រោយ។

អំឡុងពេលដែលត្រូវរង់ចាំ ដើម្បីរៀបអាពាហ៍ពិពាហ៍ថ្មីនេះត្រូវលើកលែងផងដែរ ក្នុងករណីពីរយ៉ាងដូចខាងក្រោមៈ

ករណីទី១ : ស្ត្រីនោះមានផ្ទៃពោះនៅមុនពេលដែលអាពាហ៍ពិពាហ៍ចាស់ត្រូវបានរំលាយ ឬ លុបចោល ឬ ប្តីស្លាប់ ហើយបានសម្រាលកូន គឺស្ត្រីអាចរៀបអាពាហ៍ពិពាហ៍ថ្មីបានដោយមិនបាច់ រង់ចាំរយៈពេល១២០ថ្ងៃទេ ពីព្រោះកូននោះត្រូវសន្មតថា ជាកូនរបស់ប្តីមុនហើយ។

ករណីទី២ : ស្ត្រីដែលបានលែងលះគ្នា ឬ ប្តីស្លាប់ចោលនោះមានលិខិតបញ្ជាក់ពីវេជ្ជបណ្ឌិត ថា គ្មានផ្ទៃពោះ ស្ត្រីរូបនោះក៏អាចរៀបអាពាហ៍ពិពាហ៍ថ្មីបាន ដោយមិនបាច់រង់ចាំរយៈពេល ១២០ ថ្ងៃដែរ[9]។

## ៣.ការហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ក្នុងញាតិលោហិត

ញាតិលោហិត សំដៅដល់ញាតិដែលមានឈាមជ័រជាមួយគ្នាដូចជា ឪពុក និង កូន ឬ ម្តាយ និងកូន ជាដើម។សាខាញាតិ សំដៅដល់ញាតិដែលចែកជាមែកធាងពីអ្នកបង្កើតរួម ដូចជា បងប្អូនបង្កើត មីង មា កុយ បងប្អូនជីដូនមួយ...។

នៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានហាមមិនឱ្យរៀបអាពាហ៍ពិពាហ៍រវាងញាតិថ្នាក់ ជិតគ្នាដោយសារមូលហេតុនៃសីលធម៌សង្គម។បុរស និង ស្ត្រីដែលស្នើសុំរៀបអាពាហ៍ពិពាហ៍នឹងគ្នាមិនត្រូវមានជាប់ចំនងញាតិលោហិតផ្ទាល់ ឬ សាខាញាតិលោហិតរហូតដល់ថ្នាក់ទី៣។ ទោះបីក្នុងករណីដែលមានការបញ្ចប់នូវទំនាក់ទំនងរវាង ឪពុកម្តាយនឹងកូនបង្កើត ឬ ការកាត់កាល់រវាងឪពុកម្តាយចិញ្ចឹមនឹងកូនសុំហើយក៏ដោយ។

---

[8] មាត្រា ៩៥០ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[9] មាត្រា ៩៥០ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

មាត្រា៩៥ ១ នៃក្រមរដ្ឋប្បវេណីបានហាមមិនឱ្យរៀបអាពាហ៍ពិពាហ៍រវាងញាតិដែល មានទំនាក់ទំនងគ្នាចំពោះករណីមួយចំនួនដូចខាងក្រោម៖

**៣.១.ហាមការរៀបអាពាហ៍ពិពាហ៍រវាងញាតិលោហិតផ្ទាល់**

មាត្រា៩៥១ នៃក្រមរដ្ឋប្បវេណីបានចែងថា "ហាមមិនឱ្យរៀបអាពាហ៍ពិពាហ៍រវាង ញាតិលោហិតខ្សែផ្ទាល់គ្រប់ថ្នាក់ទាំងអស់" ដែលមានដូចជា៖

- រវាង ជីលាជាមួយចៅលា (ញាតិលោហិតខ្សែផ្ទាល់ថ្នាក់ទី ៥)
- រវាងជីលួតជាមួយចៅលួត (ញាតិលោហិតខ្សែផ្ទាល់ថ្នាក់ទី៤)
- រវាង ជីទួតជាមួយចៅទួត (ញាតិលោហិតខ្សែផ្ទាល់ថ្នាក់ទី ៣)
- រវាងជីតា ឬជីដូនជាមួយចៅ (ញាតិលោហិតខ្សែផ្ទាល់ថ្នាក់ទី២)
- រវាងឳពុកម្តាយជាមួយកូន (ញាតិលោហិតខ្សែផ្ទាល់ថ្នាក់ទី១)

**៣.២.ហាមការរៀបអាពាហ៍ពិពាហ៍រវាងសាខាញាតិលោហិត**

ក្រមរដ្ឋប្បវេណីបានហាមមិនឱ្យរៀបអាពាហ៍ពិពាហ៍រវាងសាខាញាតិលោហិតក្នុង ៣ ថ្នាក់ រាប់ទាំង ថ្នាក់ទី ៣១ នេះផង មានដូចជា៖

- រវាងបងប្អូនបង្កើត (សាខាញាតិថ្នាក់ទី ២)
- រវាងពូ ឬ មីងជាមួយកុយ (សាខាញាតិថ្នាក់ទី ៣)

ប៉ុន្តែសម្រាប់សាខាញាតិលោហិតចាប់ពីថ្នាក់ទី ៤ទៅអាចរៀបអាពាហ៍ពិពាហ៍ជាមួយ គ្នាបានដូចជា បងប្អូនជីដូនមួយ ឬ ជីទួតមួយជាដើម។

**៣.៣.ហាមការរៀបអាពាហ៍ពិពាហ៍រវាងអតីតឪពុក ឬម្តាយបង្កើត**

ជាមួយអតីតកូនបង្កើតច្បាប់ហាមមិនអោយរៀបអាពាហ៍ពិពាហ៍រវាងអតីតឪពុក ឬ ម្តាយបង្កើតជាមួយអតីត កូនបង្កើត ដែលបានបញ្ចប់នូវញាតិភាពជាមួយនឹងឪពុកម្តាយបង្កើតដោយសារការបង្កើតសុំ កូនពេញលេញ[10]។ មានន័យថា ក្នុងករណីដែលអតីតឪពុកបង្កើត ឬ អតីតម្តាយបង្កើត ត្រូវ បានបញ្ចប់នូវភាពជាឪពុក ឬ ម្តាយបង្កើតដោយសារមូលហេតុណាក៏ដោយ ក៏អតីតឪពុក បង្កើត ឬ អតីតម្តាយបង្កើត មិនអាចរៀបអាពាហ៍ពិពាហ៍ជាមួយអតីតកូនបង្កើតរបស់ខ្លួនបានដែរ។

**៣.៤.ហាមការរៀបអាពាហ៍ពិពាហ៍អតីតឪពុកចិញ្ចឹម ឬ ម្តាយចិញ្ចឹមជាមួយកូនសុំ**

[10] មាត្រា ៩៥១ កថាខណ្ឌទី២ និង មាត្រា ១០១៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ច្បាប់ហាមមិនអោយរៀបអាពាហ៍ពិពាហ៍រវាងឪពុកចិញ្ចឹម ឬម្តាយចិញ្ចឹមជាមួយកូនសុំ។ ទោះបីជាទំនាក់ទំនងញាតិត្រូវបានកាត់ផ្តាច់ហើយដោយសារមូលហេតុណាក៏ដោយក៏អតីតឪពុកចិញ្ចឹម ឬ អតីតម្តាយចិញ្ចឹម មិនអាចរៀបអាពាហ៍ពិពាហ៍ជាមួយអតីតកូនចិញ្ចឹមបានដែរ[11] ។

### ៤.ការហាមឃាត់មិនអោយរៀបអាពាហ៍ពិពាហ៍រវាងញាតិពន្ធ

ញាតិពន្ធ សំដៅដល់ ចំណងគតិយុត្តរវាងសហព័ទ្ធម្ខាង និង ញាតិលោហិតរបស់សហព័ទ្ធ ម្ខាងទៀត ឬហៅថា "សាច់ថ្លៃ"។

ឧទាហរណ៍ : ឪពុកម្តាយក្មេក និង កូនប្រសា បងថ្លៃប្អូនថ្លៃ (ខាងប្តី ឬ ខាងប្រពន្ធ)។

ញាតិពន្ធខ្សែផ្ទាល់ សំដៅដល់ ញាតិលោហិតផ្ទាល់ខាងសាច់ថ្លៃដែលកើតតពីមួយទៅមួយ តាមលំដាប់ដូចជា ជីដូនជីតាក្មេក ឪពុកម្តាយក្មេក កូនបង្កើតរបស់សហព័ទ្ធម្ខាងទៀត។

បុរស និង ស្រ្តីដែលស្នើសុំរៀបអាពាហ៍ពិពាហ៍នឹងគ្នា មិនត្រូវមានជាប់ចំណងញាតិពន្ធក្នុង ខ្សែផ្ទាល់គ្រប់ថ្នាក់ ទោះបីជានៅថ្នាក់ណាក៏ដោយ ដែលក្រមរដ្ឋប្បវេណីបានហាមឃាត់មិនអនុញ្ញាត ឱ្យរៀបអាពាហ៍ពិពាហ៍ទេ។ ទោះបីជាញាតិពន្ធខ្សែផ្ទាល់បានបញ្ចប់ទំនាក់ទំនងញាតិពន្ធហើយក៏ ដោយច្បាប់មិនអនុញ្ញាតឱ្យញាតិពន្ធខ្សែផ្ទាល់នោះ អាចរៀបអាពាហ៍ពិពាហ៍នឹងគ្នាបានដែរ។ អាពាហ៍ពិពាហ៍ ពុំអាចធ្វើបានឡើយ រវាងញាតិពន្ធនៃខ្សែផ្ទាល់និងរវាងសាខាញាតិពន្ធនៅក្នុង ៣ថ្នាក់ រាប់ទាំងថ្នាក់ទី៣ ផង[12]។

ការរៀបអាពាហ៍ពិពាហ៍ រវាងញាតិពន្ធ គឺជាអាពាហ៍ពិពាហ៍មួយដែលច្បាប់ហាមឃាត់។ ប្រសិនមានភាគីណាបានរៀបអាពាហ៍ពិពាហ៍ជាមួយញាតិពន្ធនោះគឺជាអំពើល្មើសច្បាប់ ហើយ ច្បាប់ក៏មិនទទួលស្គាល់ផងដែរ។

### ៤.១.ការហាមមិនឱ្យរៀបអាពាហ៍ពិពាហ៍រវាងញាតិពន្ធក្នុងខ្សែផ្ទាល់

ច្បាប់បានហាមមិនឱ្យរៀបអាពាហ៍ពិពាហ៍រវាងញាតិពន្ធក្នុងខ្សែផ្ទាល់គ្រប់ថ្នាក់ទាំងអស់ ហើយទោះបីទំនាក់ទំនងញាតិពន្ធខ្សែផ្ទាល់ត្រូវបានបញ្ចប់ហើយក៏ដោយ មានដូចជា៖

- រវាងឪពុកម្តាយក្មេក និង កូនប្រសា
- រវាងជីដូនជីតាក្មេក និង ចៅប្រសា
- រវាងជីដូនជីតាទួតក្មេក និង ចៅទួតប្រសា
- រវាងជីលួតក្មេក និង ចៅលួតប្រសា
- រវាងជីលាក្មេក និង ចៅលាប្រសា

[11] មាត្រា ៩៥១ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[12] មាត្រា ៩៥២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

- រវាងអតីតឪពុកម្ដាយក្មេក និង អតីតកូនប្រសា
- រវាងអតីតជីដូនជីតាក្មេក និង អតីតចៅប្រសា
- រវាងអតីតជីដូនជីតាទួតក្មេក និង អតីតចៅទួតប្រសា
- រវាងអតីតជីលួតក្មេក និង អតីតចៅលួតប្រសា
- រវាងអតីតជីលាក្មេក និង អតីតចៅលាប្រសា

### ៤.២.ការហាមមិនឱ្យរៀបអាពាហ៍ពិពាហ៍រវាងសាខាញាតិពន្ធ

ក្រមរដ្ឋប្បវេណី បានហាមមិនឱ្យរៀបអាពាហ៍ពិពាហ៍រវាងសាខាញាតិពន្ធនៅក្នុង៣ថ្នាក់ រាប់ ទាំងថ្នាក់ទី៣នេះផង[13] ហើយទោះបីទំនាក់ទំនងញាតិពន្ធត្រូវបានបញ្ចប់ហើយក៏ដោយ ក៏មិនអាច រៀបអាពាហ៍ពិពាហ៍បានដែរ មានដូចជា៖

- រវាងបងថ្លៃប្អូនថ្លៃ (សាខាញាតិពន្ធថ្នាក់ទី២)
- រវាងអតីតបងថ្លៃ និង អតីតប្អូនថ្លៃ
- រវាងពូ ឬ មីងក្មេក ជាមួយក្មួយប្រសា (សាខាញាតិថ្នាក់ទី៣)
- រវាងអតីតពូមីងក្មេកជាមួយអតីតក្មួយប្រសា
- រវាងបងប្អូនបង្កើតរបស់ប្ដីជាមួយបងប្អូនបង្កើតរបស់ប្រពន្ធ
- រវាងអតីតបងប្អូនបង្កើតរបស់ប្ដីជាមួយអតីតបងប្អូនបង្កើតរបស់ប្រពន្ធ

ដោយសាខាញាតិពន្ធនេះ មាននិន្នាការបង្កើតទំនាក់ទំនងញាតិជារួមដែលមានលក្ខណៈជិត ស្និតស្រដៀងគ្នាទៅនឹងញាតិលោហិតខ្សែផ្ទាល់ និង សាខាញាតិលោហិតដែរ។ ប៉ុន្តែដោយសារនៅ ក្នុងប្រទេសកម្ពុជា មានករណីការរៀបអាពាហ៍ពិពាហ៍ជាមួយបងថ្លៃ ឬ ប្អូនថ្លៃ ដូចជាករណីប្ដី បានទទួលមរណភាពទៅ ហើយប្រពន្ធបានទៅរៀបអាពាហ៍ពិពាហ៍ជាមួយបង ឬ ប្អូនប្រុសដែល នៅលីវរបស់សពប្ដី ឬ ករណីដែលប្រពន្ធបានទទួលមរណភាពទៅ បងស្រី ឬ ប្អូនស្រីរបស់សព ប្រពន្ធទៅរៀបអាពាហ៍ពិពាហ៍ជាមួយបងថ្លៃ ឬ ប្អូនថ្លៃប្រុស នោះដើម្បីមើលថែទាំកូនរបស់បុគ្គលដែលទទួលមរណភាពជាដើម។ ម្យ៉ាងទៀត មានការរៀបអាពាហ៍ពិពាហ៍រវាងបងប្អូនបង្កើតរបស់ប្ដី ជាមួយបងប្អូនបង្កើតរបស់ប្រពន្ធ ក៏កើតមានផងដែរ ទើបក្រមរដ្ឋប្បវេណីថ្មីបានបញ្ញត្តិហាមឃាត់ មិនឱ្យរៀបអាពាហ៍ពិពាហ៍ករណីទាំងនោះ។

### ៤.៣.ការហាមមិនរៀបអាពាហ៍ពិពាហ៍រវាងឪពុកម្តាយចុងជាមួយកូនចុង

[13] មាត្រា ៩៥២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ចំពោះករណីឪពុកចុង ឬ ម្តាយចុង ឬ ជាមួយកូនចុង ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានហាម ឃាត់មិនអនុញ្ញាតឱ្យរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាបានទេ។ ករណីនេះទាក់ទងនឹងបញ្ញត្តិហាម ឃាត់ញាតិពន្ធខ្សែផ្ទាល់ដែលរួមមានទាំងរវាងឪពុកចុង ឬ ម្តាយចុងជាមួយកូនចុង។

### ៤.៤.ករណីលើកលែងអាចរៀបអាពាហ៍ពិពាហ៍រវាងសាខាញាតិពន្ធ

ក្នុងករណីដែលសហព័ទ្ធណាម្នាក់ (ប្តីឬប្រពន្ធ) បានទទួលមរណភាព ហើយសហព័ទ្ធម្ខាង ទៀតនៅរស់អាចរៀបអាពាហ៍ពិពាហ៍ជាមួយសាខាញាតិរបស់សហព័ទ្ធម្ខាងទៀតបាន ត្រឹមថ្នាក់ទី ៣ ពោលគឺអាចរៀបអាពាហ៍ពិពាហ៍រវាងអតីតពូមីងក្មេកជាមួយអតីតក្មួយប្រសាបាន។ ប៉ុន្តែ មិនអាចរៀបអាពាហ៍ពិពាហ៍ រវាងអតីតបងថ្លៃ និង អតីតប្អូនថ្លៃបានទេ[14]។

## ផ្នែកទី៣.អានុភាពនៃអាពាហ៍ពិពាហ៍

ក្រោយពីរៀបអាពាហ៍ពិពាហ៍បុរស និងស្ត្រីនោះនឹងក្លាយជាប្តីប្រពន្ធស្របតាមប្រពៃណី ប៉ុន្តែករណីដែលពិសេសជាងនេះទៅទៀតនោះ គឺការចុះសំបុត្រអាពាហ៍ពិពាហ៍នឹងធ្វើឱ្យជីវិត ប្តីប្រពន្ធរបស់ពួកគេកាន់តែមានអានុភាពចំពោះមុខច្បាប់ថែមទៀត។ អានុភាពទាំងនោះ គឺបាន កំណត់នូវសិទ្ធិ និងករណីកិច្ចរបស់សហព័ទ្ធនៅក្នុងគ្រួសារ ដើម្បីឱ្យប្តីប្រពន្ធនៅក្នុងគ្រួសារមាន សិទ្ធិ និង កាតព្វកិច្ចដូចគ្នា។

### កថាខណ្ឌទី១.នាមត្រកូលរបស់ប្តីប្រពន្ធ

ដោយផ្អែកតាមការកំណត់នៅពេលរៀបអាពាហ៍ពិពាហ៍ ប្តីប្រពន្ធ អាចប្រើនាមត្រកូល របស់ប្តី ឬ ប្រពន្ធ ឬ អាចប្រើនាមត្រកូលដើមរៀងៗខ្លួន ដែលមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍បាន។ មាត្រានេះគោរពសិទ្ធិស្វ័យសម្រេចចំពោះនាមត្រកូល និង សិទ្ធិបុគ្គល និង ធានារបប ដែលប្តីប្រពន្ធអាចជ្រើសរើសប្រើនាមត្រកូលខុសគ្នា។ ជាគោលការណ៍ ប្តីប្រពន្ធនៅប្រទេសកម្ពុជា ប្រើនាមត្រកូលខុសគ្នា ដោយសារតែនាមត្រកូលបង្ហាញឱ្យតំណខ្សែលោហិត និងឬសគល់នៃ ឪពុកម្តាយ និង ដូនតា ហើយដោយសារតែវាមានតួនាទីសម្គាល់អត្តសញ្ញាណរបស់ជនគ្រប់រូប ជាមួយនឹងនាមខ្លួន ទើបយើងសម្រេចយកយន្តការដែលជនគ្រប់រូបអាចជ្រើសរើសដោយសេរី នូវនាមត្រកូល បន្ទាប់ពីរៀបអាពាហ៍ពិពាហ៍រួច។ នៅប្រទេសកម្ពុជា កូនកើតមក តាមទំនៀមទំ លាប់គឺដាក់ឈ្មោះតាមឪពុក ជីតា ឬ បុព្វជនដែលចាស់ជាងនេះទៀត ក៏ប៉ុន្តែការអនុវត្តយកនាម ត្រកូលគ្រួសារពុំច្បាស់លាស់ទេ។ ទោះជាដូច្នេះក្តី ផ្នែកដំបូងនៃឈ្មោះហាក់ដូចជាត្រូវចាត់ទុកថាជា នាមត្រកូល ឬ ត្រកូល ហើយនៅពេលចុះបញ្ជី ក៏ចាំបាច់ត្រូវធ្វើការបែងចែកនាមត្រកូល និង នាមខ្លួន ហើយដោយផ្អែកលើលទ្ធផលនៃការសួរ

[14] មាត្រា ៩៥២ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

មតិយោបល់ដែលថាការទទួលស្គាល់ការជ្រើសរើសឈ្មោះរបស់ ប្តីប្រពន្ធជាការសមរម្យ ទើបយើងសម្រេចថា ការប្រើនាមត្រកូលរួម ឬ នាមត្រកូលដោយឡែកក៏មិន មានបញ្ហាអ្វីដែរ។

**កថាខណ្ឌទី២.ករណីយកិច្ចរួមរស់នឹងគ្នា សហការ និងសង្គ្រោះគ្នាទៅវិញទៅមក**

ប្តីប្រពន្ធត្រូវរួមរស់ជីវភាពជាមួយគ្នា ហើយត្រូវសហការសង្គ្រោះគ្នាទៅវិញទៅមក។មាន ន័យថា អាពាហ៍ពិពាហ៍ គឺជាសម្ព័ន្ធភាពផ្លូវចិត្ត រាងកាយ សេដ្ឋកិច្ច នៃប្តីប្រពន្ធ។ ប្តីប្រពន្ធត្រូវមានភាពស្មើភាពគ្នាលើគ្រប់ ទស្សនៈហើយប្តីប្រពន្ធមានករណីយកិច្ចស្រឡាញ់គ្នាទៅ វិញទៅមក គោរពគ្នាទៅវិញទៅមក ថែរក្សាគ្នា និង ជួយ គ្នាទៅវិញទៅមក ដើម្បីឈានទៅកាន់វឌ្ឍន ភាព ព្រមទាំងកសាងគ្រួសារមួយ មានសាមគ្គីភាព និង ប្រកបដោយ សុភមង្គល។ សហព័ទ្ធទាំង សងខាង ត្រូវជួយសង្គ្រោះគ្នា ទាំងផ្នែកសំភារៈ និង ថវិការ ឬ ចែកការងារគ្នាដោយ ម្ខាងជាអ្នករក ប្រាក់ ហើយម្ខាងទៀត ធ្វើការងារផ្ទះ មើលថែរក្សាកូន និង ធ្វើម្ហូបអាហារជាដើម[15]។

**កថាខណ្ឌទី៣.សេរីភាពក្នុងការជ្រើសរើសវិជ្ជាជីវៈ**

ប្តីប្រពន្ធមានសេរីភាពក្នុងការជ្រើសរើសវិជ្ជាជីវៈ ហើយអាចចូលរួមក្នុងសកម្មភាព នយោបាយ វប្បធម៌ សង្គម រៀងៗខ្លួនបាន។ ដើម្បីសម្រេចឱ្យបានជាក់ស្តែងនូវភាពស្មើគ្នា ច្បាប់បានទទួលស្គាល់ឱ្យប្តីប្រពន្ធមានសេរី ភាពក្នុងការជ្រើសរើសវិជ្ជាជីវៈនិងសិទ្ធិចូលរួមប្រាស្រ័យដោយសេរីក្នុងសកម្មភាពនយោបាយវប្បធម៌និងសង្គម[16] ។ សេរីភាពសហព័ទ្ធ មាន៣ធំៗ គឺ ៖

សេរីភាពជ្រើសរើសវិជ្ជាជីវៈ ៖ ក្នុងឆ្នាំ ១៩២០ ស្ត្រីដែលចង់ប្រកបវិជ្ជាជីវៈ ត្រូវសុំការអនុញ្ញាត ពីប្តី។ប៉ុន្តែ ចាប់ពីឆ្នាំ ១៩៨១ រហូតមកដល់បច្ចុប្បន្ន ស្ត្រីអាចប្រកបវិជ្ជាជីវៈ ដោយសេរីមិន ចាំបាច់សុំការអនុញ្ញាតពីប្តីឡើយ។ នៅអឺរ៉ុប ស្ត្រីដែលប្រកបរបររកស៊ីផ្លូវភេទ គឺមិនត្រូវបាន អនុញ្ញាតអោយរៀបការទេ លុះត្រាតែស្ត្រីនោះ លះបង់វិជ្ជាជីវៈនោះ ហើយមកប្រកបវិជ្ជាជីវៈថ្មី ផ្សេងទៀត ក្រៅពីមុខរបរនោះ។

សេរីភាពជ្រើសរើសនយោបាយ ៖ ប្តី និង ប្រពន្ធ មានសិទ្ធិជ្រើសរើសបក្សនយោបាយ ដែល ខ្លួនពេញ ចិត្ត ដោយមិនមានការបង្ខិតបង្ខំពីសហព័ទ្ធ ឬ ពីជនណាម្នាក់ឡើយ។ មានន័យថា នៅពេលដែលសហព័ទ្ធណា ម្នាក់ធ្វើការជ្រើសរើសបក្សនយោបាយណាមួយដែលខ្លួន ស្រលាញ់ពេញចិត្ត ភាគីដែលជាសហព័ទ្ធម្ខាងទៀត មិនអាចមានសិទ្ធិជំទាស់ រារាំង នឹងការ សម្រេចចិត្តនេះបានឡើយ ឬ មិនអាចធ្វើការបង្ខិតបង្ខំអោយប្តី ឬប្រពន្ធ ផ្លាស់ប្តូរការ សម្រេចចិត្តផ្ទាល់ខ្លួនហើយងាកមកស្របតាមការជ្រើសរើសរបស់ខ្លួនបានឡើយ។ ត្រង់នេះ ចង់ បង្ហាញថា ប្តីគ្មានសិទ្ធិបង្ខំប្រពន្ធហើយប្រពន្ធក៏គ្មានសិទ្ធិបង្ខំប្តីដែរ។ ព្រោះថាបុគ្គល ម្នាក់ៗមានសិទ្ធិសេរីភាព

[15] មាត្រា ៩៦៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[16] មាត្រា ៩៦៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ពេញលេញក្នុងការជ្រើសរើសបក្សនយោបាយដែលខ្លួនពេញចិត្ត និង អាចមានសិទ្ធិចូលរួមសកម្មភាពនយោបាយតាមរយៈការបង្កើតគណបក្សនយោបាយ ជាដើម។

សេរីភាពសាសនា ៖ សាសនា គឺផ្ទេរតាមខ្សែលោហិត និង ធ្វើការផ្សព្វផ្សាយសាសនានោះ ឡើង ដើម្បីកុំអោយសាសនានោះសាបរលាប។ សាសនាព្រះពុទ្ធផ្ទេរពីញាតិ ទៅ ញាតិ មានន័យថាឪពុកម្តាយកាន់សាសនាអ្វីកូនក៏ត្រូវកាន់សាសនានោះដែរ។ ប្តីប្រពន្ធ មានសិទ្ធិ ពេញលេញជ្រើសរើសសាសនាតាមខ្លួនពេញចិត្ត។

**កថាខណ្ឌទី៤.សិទ្ធិស្មើគ្នាក្នុងការប្រើប្រាស់ អាស្រ័យផល និងចាត់ចែងលើទ្រព្យរួម**

ក្នុងពេលមានចំណងអាពាហ៍ពិពាហ៍នឹងគ្នា ទោះប្រពន្ធ ឬ ប្តីរកបានទ្រព្យសម្បត្តិប្រាក់ កាសជាចំណូលក្នុងគ្រួសារច្រើន ឬ តិចជាងប្តី ឬ ប្រពន្ធក៏ដោយ ទ្រព្យសម្បត្តិ និង ប្រាក់កាស ជា ចំណូលទាំងនោះចាត់ទុកថាជាទ្រព្យសម្បត្តិរួមរបស់សហព័ទ្ធទាំងពីរ។ ក្នុងករណីដែលប្រពន្ធពុំ បានចេញទៅរកស៊ី ប៉ុន្តែប្រពន្ធនោះមានតួនាទីជាមេផ្ទះថែរក្សាអប់រំកូន ការងារគេហកិច្ចទាំងនេះ ត្រូវចាត់ទុកស្មើនឹងការងារផលិតកម្មរបស់ប្តី។

សិទ្ធិស្មើគ្នានេះមានន័យថា សហព័ទ្ធទាំងពីរនាក់ត្រូវគ្រប់គ្រងទ្រព្យសម្បត្តិជាមួយគ្នា។ សហព័ទ្ធម្នាក់ៗអាចប្រើប្រាស់សំភារៈដែលទ្រព្យសម្បត្តិរួម និង អាចលក់ដូរ ឬ ធ្វើអំណោយបាន លុះត្រាតែមានការព្រមព្រៀងពីសហព័ទ្ធម្នាក់អាចទាមទារឱ្យសហព័ទ្ធម្នាក់ទៀតយល់ព្រមពីវិធាន ការណ៍ចាំបាច់ ដើម្បីថែរក្សាទ្រព្យសម្បត្តិរួម ឬ រក្សាទុកតំលៃរបស់ទ្រព្យសម្បត្តិនោះ។

ប្តីប្រពន្ធ មានសិទ្ធិស្មើគ្នាក្នុងការប្រើប្រាស់ ទទួលផលប្រយោជន៍ និង គ្រប់គ្រងទ្រព្យសម្បត្តិ រួម។ សហព័ទ្ធនីមួយៗ មានសិទ្ធិប្រើប្រាស់ ទទួលផលប្រយោជន៍ និង គ្រប់គ្រងទ្រព្យសម្បត្តិរបស់ ខ្លួនរៀងៗខ្លួនបាន។ សហព័ទ្ធ មានសិទ្ធិប្រើប្រាស់ទ្រព្យសម្បត្តិរួម នៅក្នុងទំហំដែលចាំបាច់ ដោយ ផ្អែកលើការចាំបាច់នៅក្នុងជីវភាព។ សហព័ទ្ធត្រូវគ្រប់គ្រងទ្រព្យសម្បត្តិរួម ដោយសហការគ្នា[17]។ សហព័ទ្ធម្ខាងអាចទាមទារចំពោះភាគីម្ខាងទៀត ឱ្យធ្វើចំណាត់ការដែលចាំបាច់ដើម្បីគ្រប់គ្រង និង រក្សាទុកនូវទ្រព្យសម្បត្តិរួមបាន។ បើការពិភាក្សាអំពីការគ្រប់គ្រង ឬ ប្រើប្រាស់ទ្រព្យសម្បត្តិរួមរបស់ ប្តីប្រពន្ធមិនបានសម្រេច ឬ បើពុំអាចពិភាក្សាបានទេ ភាគីម្ខាងទៀតអាចទាមទារទៅតុលាការឱ្យធ្វើ ការចាត់ចែងចំពោះការគ្រប់គ្រង និង ប្រើប្រាស់ទ្រព្យសម្បត្តិរួមបាន។

ទ្រព្យសម្បត្តិរួមរបស់សហព័ទ្ធ មានបន្ទុកដោះស្រាយបញ្ហាដូចខាងក្រោម:

- ការផ្គត់ផ្គង់គ្រួសារ និង ចំណាយដើម្បីអប់រំ និង បណ្តុះបណ្តាលកូន

[17] មាត្រា ៩៧៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

- បំណុល និង កាតព្វកិច្ចទាំងឡាយណា ដែលសហព័ទ្ធទាំងពីរបានព្រមព្រៀងគ្នាសំរេច ក្នុងពេលមានចំណងអាពាហ៍ពិពាហ៍។
- ការថែទាំ និង ការគ្រប់គ្រងទ្រព្យសម្បត្តិរួម។

## ផ្នែកទី៤.មោឃភាព និង ការលុបចោលអាពាហ៍ពិពាហ៍

ទោះបីជាមនុស្សពីរនាក់បានរៀបអាពាហ៍ពិពាហ៍នឹងគ្នារួចហើយ និងចុះលិខិត អាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ឃុំឬសង្កាត់ ក៏ដោយ ប្រសិនបើអាពាហ៍ពិពាហ៍ នោះមិនបានបំពេញតាមលក្ខខណ្ឌតម្រូវនានា ធ្វើឱ្យអាពាហ៍ពិពាហ៍កើតឡើងដោយមិនបំពេញ លក្ខណច្បាប់ដែលនាំអោយមានផលវិបាកមួយចំនួនចំពោះអាពាហ៍ពិពាហ៍ពោលគឺ "អាពាហ៍ពិពាហ៍ទុកជាមោឃៈ" ឬ "ការលុបចោលអាពាហ៍ពិពាហ៍។

### កថាខណ្ឌទី១.មោឃភាពនៃអាពាហ៍ពិពាហ៍

មោឃភាព គឺជាភាពពុំមានអានុភាពតាមផ្លូវច្បាប់នៃសកម្មភាពគតិយុត្តដែលផ្ទុយនឹង បញ្ញត្តិអំពីនីតិវិធីនៃបណ្តឹង។ហើយជាទណ្ឌកម្មដែលប្រកាសដោយចៅក្រមលុបបំបាត់ចោល ជាប្រតិសកម្ម នូវលិខិតគតិយុត្តិមិនបានបំពេញលក្ខខណ្ឌដែលច្បាប់កំណត់ ឬ សកម្មភាពណាមួយ ដែលផ្ទុយនីតិវិធីនៃច្បាប់[18]។ បើនិយាយអោយខ្លីមក"មោឃភាព" គឺជាការរំលាយចោលកិច្ចសន្យា តាមរយៈសាលក្រមតុលាការ។

មោឃភាពនៃអាពាហ៍ពិពាហ៍ មានន័យថា អាពាហ៍ពិពាហ៍នឹងត្រូវចាត់ទុកជាមោឃៈ ប្រសិនបើគូភាគីគ្មានឆន្ទៈរៀបអាពាហ៍ពិពាហ៍ ដោយសារការភាន់ច្រឡំលើមនុស្ស ការបង្ខំ និង មូលហេតុផ្សេងៗទៀត។ ហើយប្រសិនបើភាគីមិនបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូន ដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ ឬ មិនបានចុះបញ្ជីអាពាហ៍ពិពាហ៍។ ប៉ុន្តែ ប្រសិនបើគ្រាន់តែមានវិការៈតែបន្តិចបន្តួចលើនីតិវិធីប៉ុណ្ណោះទេ អានុភាពនៃអាពាហ៍ពិពាហ៍ នេះ មិនត្រូវបានរារាំងដោយសារហេតុនោះឡើយ។

បើពិនិត្យក្នុងអត្ថន័យនៃក្រមរដ្ឋប្បវេណី ចំពោះមោឃភាពនៃអាពាហ៍ពិពាហ៍ មានពីរយ៉ាង ទៀត គឺ "មោឃភាពដាច់ខាត" និង "មោឃភាពមិនដាច់ខាត"។

#### ១.មោឃភាពដាច់ខាត

មោឃភាពដាច់ខាត គឺសំដៅដល់រាល់អាពាហ៍ពិពាហ៍ទាំងឡាយណាដែលច្បាប់ហាមឃាត់ តែម្តង។ កំហុសធ្ងន់ធ្ងរក្នុងការរៀបអាពាហ៍ពិពាហ៍ ដែលអាចស្ថិតក្នុងចំនុចនៃមោឃភាពដាច់ខាត នោះមានដូចតទៅៈ

[18] សន្ទានុក្រមពាក្យច្បាប់ ឆ្នាំ២០១២

**១.១.ការភាន់ច្រឡំលើមនុស្ស**

ក្នុងករណីដែលភាគីមានបំណងនឹងរៀបអាពាហ៍ពិពាហ៍ជាមួយបុគ្គលម្នាក់ ដោយសារការ ភាន់ច្រឡំទៅលើមនុស្សដែលខ្លួនត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយនោះ តែបែរជាខ្លួនត្រូវរៀប អាពាហ៍ពិពាហ៍ជាមួយ ដូចជាកូនភ្លោះដែលមានមុខមាត់ដូចគ្នា ឬ ភាន់ច្រឡំលើមនុស្សដែលមានឈ្មោះដូចគ្នាជាដើម។

ការភាន់ច្រឡំលើមនុស្សដែលជាកម្មវត្ថុសំខាន់នៃអាពាហ៍ពិពាហ៍បែបនេះ ភាគីអាចស្នើសុំរំលាយកិច្ចសន្យាអាពាហ៍ពិពាហ៍នោះបាន។

ប៉ុន្តែការភាន់ច្រឡំលើមនុស្សដែរ តែភាន់ច្រឡំលើអត្តចរិក ឬ អាកប្បកិរិយាមនុស្សនោះ ដោយគិតថាមនុស្សនោះចិត្តល្អ តែក្រោយពេលរៀបអាពាហ៍ពិពាហ៍ហើយបែរជាចិត្តមិនល្អវិញ ភាគីដែលភាន់ច្រឡំបែបនេះមិនអាចសុំមោឃភាពនៃអាពាហ៍ពិពាហ៍បានទេ[19]។

**១.២.ការបង្ខិតបង្ខំ**

ភាគីដែលបានរៀបអាពាហ៍ពិពាហ៍ដោយការបង្ខិតបង្ខំពីភាគីម្ខាងទៀតពីឪពុកម្តាយ ពីអាណាព្យាបាល ឬ ពីតតិយជនណាមួយឱ្យរៀបអាពាហ៍ពិពាហ៍ជាមួយមនុស្ស ដែលខ្លួនមិនមានបំ នងនឹងរៀបអាពាហ៍ពិពាហ៍ជាមួយ ឬ គ្មានឆន្ទៈនឹងរៀបអាពាហ៍ពិពាហ៍ជាមួយ គឺជាការផ្ទុយពីស្មារតី នៃរដ្ឋធម្មនុញ្ញដែលចែងថា "អាពាហ៍ពិពាហ៍ត្រូវធ្វើឡើងតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ និង តាមគោលការណ៍ស្ម័គ្រចិត្តប្តីមួយប្រពន្ធមួយ[20]។ អាពាហ៍ពិពាហ៍ដែលបានធ្វើឡើងដោយភាគី គ្មានសេរីភាពក្នុងការជ្រើសរើសទាល់តែសោះបែបនេះបង្ហាញនូវករណីកម្រិតខ្ពស់និងកំហុសខ្លាំងនៃ សកម្មភាពរំលោភរដ្ឋធម្មនុញ្ញធ្ងន់ធ្ងរដែលភាគីស្នើសុំមោឃភាពនៃអាពាហ៍ពិពាហ៍នោះបាន។

**២.មោឃភាពមិនដាច់ខាត**

មោឃភាពមិនដាច់ខាតគឺសំដៅដល់រាល់អាពាហ៍ពិពាហ៍ទាំងឡាយណាដែលច្បាប់ហាម ឃាត់ តែអាចកើតមានឡើងវិញពេលបានបំពេញគ្រប់លក្ខខណ្ឌ។

នៅក្នុងករណីភាគីដែលបានរៀបអាពាហ៍ពិពាហ៍ មិនបានបំពេញតាមទម្រង់ច្បាប់នូវនីតិវិធី មួយចំនួននាំឱ្យអាពាហ៍ពិពាហ៍ អាចទុកជាមោឃៈបាន ឬ អាចបន្តអនុវត្តក៏បាន ហៅថា មោឃភាព មិនដាច់ខាតនៃអាពាហ៍ពិពាហ៍ ដោយសារតែកំហុសមិនមានលក្ខណធ្ងន់ធ្ងរ។ ប៉ុន្តែ ប្រការដែល ក្រមរដ្ឋប្បវេណីថ្មីបានកំណត់លក្ខខណ្ឌខាងផ្លូវច្បាប់បន្តិចបន្តួចដូចជា ភាគីមិនបានដាក់ពាក្យ សុំរៀបអាពាហ៍ពិពាហ៍ ភាគីមិនបានជូន

[19] មាត្រា ៩៥៨ ចំណុច ក នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[20] មាត្រា ៤៥ នៃរដ្ឋធម្មនុញ្ញ

ដំណឹងជាសាធារណៈ ភាគីមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍ ជាដើម។ ហើយនាំឱ្យភាគីអាចស្នើសុំរំលាយអាពាហ៍ពិពាហ៍នោះចោលទាំងអស់ហាក់ដូចជាមិន សមហេតុឡើយសម្រាប់ការអនុវត្តនៅប្រទេសកម្ពុជា[21]។

**២.១.ភាគីមិនបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍**

ភាគីដែលបានរៀបអាពាហ៍ពិពាហ៍ហើយ ដោយមិនបានសុំច្បាប់ដើម្បីរៀបអាពាហ៍ពិពាហ៍ ពីមេឃុំ ចៅសង្កាត់ គេអាចស្នើសុំលុបអាពាហ៍ពិពាហ៍ចោលបាន ឬ មិនស្នើសុំរំលាយចោល ក៏បាន។ ប៉ុន្តែច្បាប់មិនបានកំណត់ច្បាស់ថា អ្នកណាជាអ្នកមានសិទ្ធិប្តឹងលុបចោលអាពាហ៍ពិពាហ៍ ដែលមិនបានដាក់ពាក្យសុំច្បាប់រៀបអាពាហ៍ពិពាហ៍នោះទេ។

**២.២.ភាគីមិនបានជូនដំណឹងជាសាធារណៈ**

ជនដែលសុំការអនុញ្ញាត ដើម្បីរៀបអាពាហ៍ពិពាហ៍ហើយ ប៉ុន្តែមិនជូនដំណឹងជា សាធារណៈនូវអាពាហ៍ពិពាហ៍ដូចការកំណត់របស់ច្បាប់ គឺរយៈពេល១០ថ្ងៃ នៅមុនពេលរៀប អាពាហ៍ពិពាហ៍ការខកខានប្រកាសដំណឹងអាពាហ៍ពិពាហ៍នេះ អាពាហ៍ពិពាហ៍នោះអាចលុប ចោលបាន ឬ មិនស្នើសុំរំលាយចោលក៏បានដោយសារកំហុសបន្តិចបន្តួចដែលភាគីអាចស្នើ សុំមោឃភាព ហើយមិនមែនជាមោឃភាពដាច់ខាតដែលត្រូវតែលុបចោលនោះទេ។

បើសិនជាការរំលោភលើនីតិវិធីនោះតិចតួច ប្រហែលជាមិនប៉ះពាល់ដល់ភាពពេញ លក្ខណច្បាប់របស់អាពាហ៍ពិពាហ៍ដែលមានចែងក្នុងក្រមរដ្ឋប្បវេណីទេ។ ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារចាស់ បានតម្រូវឱ្យមានរយៈពេលរង់ចាំ ១០ថ្ងៃ ពីថ្ងៃបិទប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ដែលបានស្នើសុំរហូតដល់ថ្ងៃរៀបចំពិធីមង្គលការ ហើយប្រសិនបើមន្ត្រីអត្រានុកូលដ្ឋាន បាន អនុញ្ញាតឱ្យរៀបអាពាហ៍ពិពាហ៍មុនរយៈពេលរង់ចាំ១០ថ្ងៃដែលច្បាប់បានកំណត់នោះ។ ក្រមរដ្ឋប្បវេណី មិនបានលើកច្បាស់លាស់ នូវផលប៉ះពាល់នៃការខកខានមិនបានបំពេញតាម លក្ខខណ្ឌតម្រូវនៃនីតិវិធី ដែលបានកើតឡើងខាងលើនេះទេ។ ប៉ុន្តែហាក់ដូចជាទំនងណាស់ថាអាពាហ៍ពិពាហ៍នោះនឹងត្រូវចាត់ទុកថាមានលក្ខណត្រឹមត្រូវតាមច្បាប់។ ដើម្បីជួយជំរុញដល់ អាពាហ៍ពិពាហ៍ និងការធ្វើឱ្យមានការសង្ឃឹមទុករបស់សហព័ទ្ធ ឱ្យនៅមានតម្លៃតាមផ្លូវច្បាប់ការ បំពេញជាដុំកំភួននូវលក្ខខណ្ឌតម្រូវនៃនីតិវិធីច្បាប់ជាទូទៅគឺជាការគ្រប់គ្រាន់នឹងធ្វើឱ្យអាពាហ៍ពិពាហ៍ មួយមានលក្ខណត្រឹមត្រូវតាមច្បាប់។

**២.៣.ភាគីមិនបានចុះកិច្ចសន្យាអាពាហ៍ពិពាហ៍**

ភាគីដែលបានរៀបអាពាហ៍ពិពាហ៍ហើយ នឹងចាត់ទុកជាការត្រឹមត្រូវតាមលក្ខណច្បាប់បាន លុះត្រាតែបុរស និងនារី បានចុះកិច្ចសន្យាអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ខាង លំនៅឋានរបស់នារី

[21] មាត្រា ៩៥៨ ចំណុច ខ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ដោយមានសាក្សីពេញនីតិភាព២នាក់ផង។ ក្នុងករណីភាគីមិនបានចុះកិច្ច សន្យាអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានទេគេអាចស្នើសុំលុបអាពាហ៍ពិពាហ៍ នោះបាន។

**២.៤.ភាគីមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍**

នៅក្រោយពេលភាគីបានចុះកិច្ចសន្យាអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ខាងលំនៅឋានរបស់នារី ហើយច្បាប់តម្រូវឱ្យភាគីត្រូវយកកិច្ចសន្យានេះត្រូវចុះបញ្ជីអាពាហ៍ពិពាហ៍ របស់មន្ត្រីអត្រានុកូលដ្ឋាន ហើយត្រូវចុះហត្ថលេខាដោយសាក្សីគ្រប់អាយុ២នាក់ផង។ ក្នុងករណី ដែលភាគីមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍នេះទេ គេអាចស្នើសុំលុបអាពាហ៍ពិពាហ៍ចោលបាន។

**កថាខណ្ឌទី២.ការលុបចោលអាពាហ៍ពិពាហ៍**

ការរៀបអាពាហ៍ពិពាហ៍ត្រូវធ្វើឡើងតាមនីតិវិធីច្បាប់ឬស្របតាមបទបញ្ញត្តិផ្សេងៗទៀត ដែលទាក់ទងទៅនឹងអាពាហ៍ពិពាហ៍នោះ។ ការរៀបអាពាហ៍ពិពាហ៍មិនត្រូវផ្ទុយទៅនឹងបទបញ្ញត្តិក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ឡើយ។ម្យ៉ាងវិញទៀត ក៏មិនត្រូវផ្ទុយនឹងបទបញ្ញត្តិផ្សេងៗទៀតដែល ទាក់ទងនឹងអាពាហ៍ពិពាហ៍ផងដែរ។ មិនដូច្នោះទេ អាពាហ៍ពិពាហ៍នោះនឹងត្រូវលុបចោល ឬ ក៏មោឃភាពចោល។

រីឯមូលហេតុនៃការលុបចោលអាពាហ៍ពិពាហ៍វិញ ចែកចេញជាពីរប្រភេទ។ ប្រភេទទី១ គឺ មូលហេតុនៃការលុបចោលដែលមានលក្ខណៈជាផលប្រយោជន៍សាធារណៈ ដូចជាការលុបចោល អាពាហ៍ពិពាហ៍នៃជនដែលមិនទាន់គ្រប់អាយុរៀបអាពាហ៍ពិពាហ៍ ទ្វេពន្ធភាព អាពាហ៍ពិពាហ៍ដែល បានធ្វើឡើងក្នុងអំឡុងពេលហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ថ្មីទៀត និង អាពាហ៍ពិពាហ៍រវាង ញាតិថ្នាក់ជិត។ រីឯប្រភេទទី២ គឺជាមូលហេតុដែលមានលក្ខណៈជាផលប្រយោជន៍ឯកជន ដូចជា ការឆបោក និង គំរាម។

**១.អាពាហ៍ពិពាហ៍មិនគ្រប់អាយុ**

អាពាហ៍ពិពាហ៍រវាងបុរសក្រោម១៨ឆ្នាំ និង នារីក្រោមអាយុ១៨ឆ្នាំអាចលុបចោលបាន ដោយសារមានភាពផ្ទុយនឹងផលប្រយោជន៍សាធារណៈ។ ក៏ប៉ុន្តែក្នុងករណីដែលជនមិនគ្រប់អាយុ រៀបអាពាហ៍ពិពាហ៍ បានដល់នីតិភាពរៀបអាពាហ៍ពិពាហ៍ សិទ្ធិទាមទារលុបចោលនោះត្រូវរលត់។ទោះបីជាជនដែលមិនទាន់គ្រប់អាយុរៀបអាពាហ៍ពិពាហ៍ បានដល់អាយុរៀបអាពាហ៍ពិពាហ៍ ហើយក៏ដោយ ជននោះក៏នៅតែអាចទាមទារឱ្យលុបចោលអាពាហ៍ពិពាហ៍នោះបានដែរ នៅក្នុង អំឡុងពេល ៣ខែ ចាប់ពីពេលជននោះបានគ្រប់អាយុ លើកលែងតែក្នុងអំឡុងពេលនេះ ជននោះ បានធ្វើសច្ចានុម័ត (ការសុខចិត្តយល់ព្រមទទួលស្គាល់ដែលមានអានុភាពប្រតិសកម្ម) លើ អាពាហ៍ពិពាហ៍នោះ ។

ក៏ប៉ុន្តែ អាពាហ៍ពិពាហ៍ដែលអាចលុបចោលបាន អាចទៅជាមានលក្ខណត្រឹមត្រូវតាមច្បាប់ ឬ បុរស និង ស្ត្រីនោះទទួលបានអត្តាធិនភាព។អ្នកដែលមានសិទ្ធិទាមទារឱ្យលុបចោលមានដូចជា ភា គីនីមួយៗ ញាតិសន្តានរបស់ជននោះ តំណាងអយ្យការ អាចប្តឹងទាមទារទៅតុលាការឱ្យលុបចោល អាពាហ៍ពិពាហ៍នោះបាន។

**២.ការមានទ្វេពន្ធភាព**

បុគ្គលដែលមានប្តីឬប្រពន្ធហើយ ហើយចំណងអាពាហ៍ពិពាហ៍មុននៅមានសុពលភាព នៅឡើយ (មិនទាន់លែងលះគ្នាដាច់ស្រឡះ) ហើយបានរៀបអាពាហ៍ពិពាហ៍ប្តី ឬប្រពន្ធថ្មីមួយ ទៀត គេអាចស្នើលុបចោលអាពាហ៍ពិពាហ៍នោះបាន។

អ្នកដែលមានសិទ្ធិទាមទារអោយលុបចោលមានដូចជា ភាគីនីមួយៗ ញាតិសន្តានរបស់ ជននោះ តំណាងអយ្យការអាចទាមទារទៅតុលាការឱ្យលុបចោលបាន។

បើសិនមានសហព័ទ្ធណាមួយ បានរៀបអាពាហ៍ពិពាហ៍រួចទៅហើយ ហើយអាពាហ៍ពិពាហ៍ នោះមិនទាន់បានរំលាយជាផ្លូវការអាពាហ៍ពិពាហ៍ក្រោយអាចទុកជាមោឃៈ។ ប៉ុន្តែអាពាហ៍ពិពាហ៍ក្រោយអាចទៅជាពេញលក្ខណច្បាប់ បើអាពាហ៍ពិពាហ៍មុនត្រូវបានរំលាយមុន ក៏អាចទាមទារប្តឹងសុំលុបចោលអាពាហ៍ពិពាហ៍[22]
។

**៣.ការលុបចោលអាពាហ៍ពិពាហ៍ធ្វើឡើងអំឡុងពេលហាមឃាត់មិនអោយរៀបអាពាហ៍ពិពាហ៍ថ្មីទៀត**

ស្ត្រីដែលបានរៀបអាពាហ៍ពិពាហ៍ម្តងទៀត ក្នុងពេលមិនទាន់ផុតរយៈពេលត្រូវរង់ចាំចំនួន ១២០ថ្ងៃ បន្ទាប់ពីអាពាហ៍ពិពាហ៍លើកមុនត្រូវបានរំលាយ អាពាហ៍ពិពាហ៍នេះអាចត្រូវបានលុប ចោលផងដែរ។ ក៏ប៉ុន្តែ សិទ្ធិទាមទារឱ្យលុបចោលត្រូវរលត់ ប្រសិនបើនារីដែលបានរៀប អាពាហ៍ពិពាហ៍ក្នុងអំឡុងពេលហាមឃាត់ (រយៈពេល ១២០ថ្ងៃ)នោះ ហើយអំឡុងពេលនោះបាន កន្លងផុតទៅដោយគិតចាប់ពីថ្ងៃដែលអាពាហ៍ពិពាហ៍ក្នុងអំឡុងពេល ១ ២០ថ្ងៃ បើផុតរយៈពេល នោះ ហើយភាគីមិនបានស្នើសុំលុបចោលសិទ្ធិលុបនោះក៏ត្រូវរលត់ដែរ។ សិទ្ធិទាមទារឱ្យលុប ចោលត្រូវរលត់ផងដែរ ក្នុងករណីនារីដែលបានរៀបអាពាហ៍ពិពាហ៍ក្នុងអំឡុងពេលហាមឃាត់ ១២០ថ្ងៃ ហើយស្តីនោះគ្មានផ្ទៃពោះ ឬ មានផ្ទៃពោះក្រោយពីបានរៀបអាពាហ៍ពិពាហ៍ថ្មីទៀត។ ដោយហេតុថា ស្ត្រីនោះគ្មានផ្ទៃពោះ ឬ មានផ្ទៃពោះក៏ដោយ បញ្ហាបិតុភាពលែងចោទជាបញ្ហាទៀត ហើយដោយសារតែទារកក្នុងគភ៌នោះ អាចបញ្ជាក់ថា ជាកូនរបស់ប្តីមុន ឬ ជាកូនរបស់ប្តីក្រោយហើ យ។ នៅក្នុងករណីដែលអាពាហ៍ពិពាហ៍មុនត្រូវបានបញ្ចប់ដោយមរណភាព លែងលះ ឬ មោឃ ភាពនៃអាពាហ៍ពិពាហ៍នោះ បុរសម្នាក់

[22] មាត្រា ៩៦០ ចំណុចទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

អាចរៀបការជាថ្មីម្តងទៀតនៅពេលណាក៏បាន ក្រោយការ បញ្ចប់អាពាហ៍ពិពាហ៍មុន។ បើសិនជាតុលាការបានសម្រេចឱ្យប្តីប្រពន្ធលែងលះតាមផ្លូវច្បាប់ រយៈ ពេលរង់ចាំត្រូវរាប់ចាប់តាំងពីថ្ងៃមានសាលក្រម ឬ មានសាលដីកាឱ្យនៅបែកគ្នា។ ច្បាប់តម្រូវឱ្យស្ត្រីរង់ចាំ ១២០ថ្ងៃ ដើម្បីកំណត់បិតុភាពនៃកូនដែលកើតមកនៅក្នុងឆ្នាំបន្ទាប់ពីការបញ្ចប់ អាពាហ៍ពិពាហ៍លើកមុន។ អ្នកដែលមានសិទ្ធិទាមទារឱ្យលុបចោលមានដូចជា ភាគីនីមួយៗ សហព័ទ្ធ របស់ភាគី ឬ សហព័ទ្ធមុន ញាតិសន្តានរបស់ជននោះ តំណាងអយ្យការ អាចទាមទារទៅតុលាការ ឱ្យលុបចោលបាន។

### ៤.ការលុបចោលអាពាហ៍ពិពាហ៍រវាងញាតិលោហិត

បុរស និងស្ត្រីដែលបានរៀបអាពាហ៍ពិពាហ៍នឹងគ្នា ដោយមានជាប់ចំណងញាតិលោហិត ផ្ទាល់ ឬ សាខាញាតិលោហិតរហូតដល់ថ្នាក់ទី៣ ត្រូវហាមឃាត់។ ឧទាហរណ៍ ការរៀប អាពាហ៍ពិពាហ៍រវាងឪពុកម្តាយ និងកូនបង្កើត ឬ រវាងឪពុកម្តាយចិញ្ចឹម និង កូនសុំហើយទោះបី ក្នុងករណីមានការបញ្ចប់នូវទំនាក់ទំនងរវាងឪពុកម្តាយនឹងកូនបង្កើត ឬ ការកាត់កាល់រវាងឪពុក ម្តាយចិញ្ចឹម និង កូនសុំហើយក៏ដោយ អាពាហ៍ពិពាហ៍ទាំងអស់នេះអាចត្រូវបានលុបចោលផង ដែរ[23]។

អាពាហ៍ពិពាហ៍រវាងមនុស្សដែលជាប់សាច់ញាតិនឹងគ្នា ក្នុងថ្នាក់ណាមួយដែលច្បាប់ហាម ឃាត់ អាពាហ៍ពិពាហ៍នោះត្រូវលុបចោល។ ច្បាប់មិនបានកម្រិតពេលវេលា សម្រាប់ឱ្យបុគ្គលដាក់ ពាក្យប្តឹងសុំលុបចោលនូវអាពាហ៍ពិពាហ៍ប្រភេទនោះទេ។ អ្នកដែលមានសិទ្ធិទាមទារឱ្យលុបចោល មានដូចជា ភាគីនីមួយៗ ញាតិសន្តានរបស់ជននោះ តំណាងអយ្យការអាចទាមទារទៅតុលាការឱ្យ លុបចោលបាន។

### ៥.ការលុបចោលអាពាហ៍ពិពាហ៍រវាងញាតិពន្ធ

បុរស និងស្ត្រីដែលបានរៀបអាពាហ៍ពិពាហ៍នឹងគ្នា ហើយមានជាប់ចំណងញាតិពន្ធក្នុង ខ្សែផ្ទាល់ ដែលក្រមរដ្ឋប្បវេណីបានហាមឃាត់មិនអនុញ្ញាតឱ្យរៀបអាពាហ៍ពិពាហ៍នឹងគ្នា អាពាហ៍ពិពាហ៍ នោះអាចលុបចោលបាន។ ទោះបីក្នុងករណញាតិពន្ធខ្សែផ្ទាល់បានបញ្ចប់ទំនាក់ ទំនងញាតិពន្ធហើយក៏ដោយច្បាប់មិនអនុញ្ញាតឱ្យញាតិពន្ធខ្សែផ្ទាល់នោះអាចរៀបអាពាហ៍ពិពាហ៍ នឹងគ្នាដែរ ហើយអាពាហ៍ពិពាហ៍នោះអាចលុបចោលបាន។

ការរៀបអាពាហ៍ពិពាហ៍រវាងសាខាញាតិពន្ធរហូតដល់ថ្នាក់ទី៣ ហើយទោះបីទំនាក់ទំនង រវាងញាតិពន្ធត្រូវបញ្ចប់ហើយក៏ដោយក៏អាពាហ៍ពិពាហ៍នោះអាចលុបចោលបាន។ការរៀបអាពាហ៍ពិពាហ៍រវាងសាខាញាតិពន្ធរហូតដល់ថ្នាក់ទី៣ ហើយទោះបីទំនាក់ទំនង រវាងញាតិពន្ធត្រូវបញ្ចប់ហើយក៏ដោយក៏អាពាហ៍ពិពាហ៍នោះអាចលុបចោលបាន[24]។

---

[23] មាត្រា ៩៥១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[24] មាត្រា ៩៦០ ចំណុចទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

**៦.ការលុបចោលអាពាហ៍ពិពាហ៍ដោយការឆបោក**

បុរស និង ស្ត្រីដែលបានរៀបអាពាហ៍ពិពាហ៍នឹងគ្នា ដោយការឆបោករបស់ភាគីម្ខាងទៀត ឬ តតិយជន ដោយមធ្យោបាយធ្វើឱ្យភាគីម្ខាងទៀតធ្លាក់ទៅក្នុងការភាន់ច្រឡំ ភាគីដែលបានបង្ហាញ ឆន្ទៈដោយការឆបោកនោះ អាចស្នើទៅតុលាការដើម្បីលុបចោលអាពាហ៍ពិពាហ៍។

សិទ្ធិនៃការស្នើសុំលុបចោលអាពាហ៍ពិពាហ៍នោះ មានរយៈពេល៣ខែ ចាប់តាំងក្រោយថ្ងៃ ដែលភាគីបានរកឃើញការឆបោកនោះ។ បើផុតរយៈពេល៣ខែនោះ ភាគីមិនបានស្នើទៅតុលាការ ដើម្បីរំលាយអាពាហ៍ពិពាហ៍ ឬ ក្នុងអំឡុងពេលដែលបានរកឃើញអំពើឆបោកនោះ ភាគីបានធ្វើ សច្ចានុម័ត ភាគីនោះរលត់សិទ្ធិ ដើម្បីប្តឹងលុបចោលអាពាហ៍ពិពាហ៍[25]។

**៧.ការលុបចោលអាពាហ៍ពិពាហ៍ដោយការគំរាម**

បុរស និងស្ត្រីដែលបានរៀបអាពាហ៍ពិពាហ៍នឹងគ្នាដោយការគំរាមរបស់ភាគីម្ខាងទៀត ឬ របស់តតិយជន តាមគ្រប់មធ្យោបាយធ្វើឱ្យភាគីម្ខាងទៀតភិតភ័យសុខចិត្តទទួលយកការរៀប អាពាហ៍ពិពាហ៍ដោយខុសពីឆន្ទៈរបស់ខ្លួន ភាគីដែលបានបង្ហាញឆន្ទៈដោយការគំរាមកំហែងនោះ អាចស្នើទៅតុលាការ ដើម្បីលុបចោលអាពាហ៍ពិពាហ៍បាន។

សិទ្ធិស្នើសុំលុបចោលអាពាហ៍ពិពាហ៍នេះ មានរយៈពេល៣ខែ ចាប់តាំងក្រោយថ្ងៃដែល ភាគីបានគេចចេញពីការគំរាមនោះ។ បើផុតរយៈពេល៣ខែនោះ ភាគីមិនបានស្នើទៅតុលាការ ដើម្បីរំលាយអាពាហ៍ពិពាហ៍ ឬ ក្នុងអំឡុងពេលដែលបានគេចចេញពីការគំរាមនោះ ភាគីបានធ្វើ សច្ចានុម័ត ភាគីនោះរលត់សិទ្ធិ ដើម្បីប្តឹងលុបចោលអាពាហ៍ពិពាហ៍[26]។

**៨.អានុភាពនៃការលុបចោលអាពាហ៍ពិពាហ៍**

ការលុបចោលអាពាហ៍ពិពាហ៍ មានអានុភាពគតិយុត្តមួយចំនួន ដែលមានដូចជា៖

- ការលុបចោលអាពាហ៍ពិពាហ៍ ពុំមានអានុភាពទៅលើអតីតកាលឡើយ[27] ពោលគ្រាន់តែ មានអានុភាពតែទៅលើអនាគតប៉ុណ្ណោះ។ មានន័យថា គេមិនអាចធ្វើអ្វីឱ្យមានលក្ខណៈ ដូចកាលពីមុនមិនទាន់រៀបអាពាហ៍ពិពាហ៍ ដូចជាភាពនៅកំលោះ ឬ ភាពនៅក្រមុំ ឬ ភាពមិនមានកូន។ ចំពោះកូនដែលកើតមកត្រូវសន្មតថា ជាកូនរបស់ប្តីមុន។

[25] មាត្រា ៩៦៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[26] មាត្រា ៩៦៣ ចំណុចទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[27] មាត្រា ៩៦៤ ចំណុចទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

- ភាគីដែលមិនបានដឹងអំពីមូលហេតុនៃការលុបចោលនៅពេលរៀបអាពាហ៍ពិពាហ៍ប្រសិនបើបានទទួលទ្រព្យសម្បត្តិដោយការរៀបអាពាហ៍ពិពាហ៍ត្រូវសងទ្រព្យសម្បត្តិ នោះត្រឹមកម្រិតនៃផលប្រយោជន៍ដែលបានទទួលទៅឱ្យភាគីម្ខាងទៀតវិញ[28]។
- ភាគីដែលបានដឹងអំពីមូលហេតុនៃការលុបចោលនៅពេលរៀបអាពាហ៍ពិពាហ៍ត្រូវសង នូវផលប្រយោជន៍ទាំងអស់ដែលបានទទួលដោយការរៀបអាពាហ៍ពិពាហ៍នោះ។ ប្រសិនបើ ភាគីម្ខាងទៀតសុច្ចរិតវិញ ត្រូវទទួលខុសត្រូវចំពោះសំណងខូចខាតនោះ[29]។
- ក្រោយពេលអាពាហ៍ពិពាហ៍ត្រូវបានលុបចោល មានអានុភាពដល់ការកំណត់បិតុភាពរបស់ទារកផងដែរ។ ក្រមរដ្ឋប្បវេណីចែងកំណត់ថា៖

  ទី១ ទារកនៅក្នុងគភ៌របស់ប្រពន្ធដែលមាននៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ត្រូវ សន្មតថាជាកូនរបស់ប្តីនោះ។

  ទី២ ប្រសិនបើក្នុងករណីកូនដែលបានកើតនៅក្រោយអំឡុងពេល ១៨០ថ្ងៃគិតចាប់ពី ថ្ងៃ ដែលអាពាហ៍ពិពាហ៍ត្រូវបានបង្កើត ឬ ក្នុងអំឡុងពេល៣០០គិតចាប់ពីថ្ងៃដែល អាពាហ៍ពិពាហ៍ត្រូវបានបង្កើត ឬ ក្នុងអំឡុងពេល ៣០០ថ្ងៃ គិតចាប់ពីថ្ងៃដែលបាន រំលាយ ឬ លុបចោលអាពាហ៍ពិពាហ៍ ច្បាប់បានសន្មតថា ស្ត្រីនោះមានគភ៌ក្នុងពេលមាន ចំណងអាពាហ៍ពិពាហ៍នោះ។

  ទី៣ ក្នុងករណីដែលកូននោះមិនអាចកំណត់ឪពុកបាន តាមចំណុចទី១ និង ទី២ ខាង លើនេះទេ កូននោះត្រូវច្បាប់សន្មតថាជាកូនរបស់ប្តីដែលបានរៀបអាពាហ៍ពិពាហ៍ ក្រោយ[30]។

[28] មាត្រា ៩៦៤ ចំណុចទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[29] មាត្រា ៩៦៤ ចំណុចទី៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[30] មាត្រា ៩៦៤ ចំណុចទី៤ និងមាត្រា ៩៨៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

# ជំពូកទី២
# ការលែងលះ

## ផ្នែកទី១.សញ្ញាណនៃការលែងលះ

### កថាខណ្ឌទី១.និយមន័យ

ការលែងលះគ្នាត្រូវ បានឱ្យនិយមន័យថា ជាសាលក្រម ឬជាសាលដីការបស់តុលាការ ដែលប្រកាសថាអាពាហ៍ពិពាហ៍ដែលត្រឹមត្រូវតាមលក្ខណច្បាប់ ត្រូវបានរំលាយ ហើយភាគីទាំងពីរលែងមានចំណងអាពាហ៍ពិពាហ៍ ជាមួយគ្នាទៀតហើយ។ សាលក្រម ឬសាលដីកា គឺជាសេចក្ដី សម្រេចរបស់តុលាការ ដែលបានធ្វើក្រោយពេលពិចារណាទៅលើ ភស្តុតាង ដែលទាក់ទងទៅនឹងបញ្ហាដែលត្រូវសម្រេចក្នុងរឿងវិវាទ អាពាហ៍ពិពាហ៍។

ការលែងលះគឺជាការផ្ដាច់ចំណងអាពាហ៍ពិពាហ៍រវាងប្ដី និងប្រពន្ធដែលបានរៀប អាពាហ៍ពិពាហ៍ស្របច្បាប់ ដែលមានការចុះសំបុត្រអាពាហ៍ពិអាហ៍នៅចំពោះមុខក្រុមប្រឹក្សាឃុំ សង្កាត់បានត្រឹមត្រូវ ហើយអាស្រ័យដោយមានការព្រមព្រៀងពីសហព័ទ្ធទាំងពីរ។ ការលែងលះគឺ បណ្ដាលមកពីការរស់នៅមិនចុះសម្រុងគ្នានូវប្រការណាមួយដែលមានមូលហេតុកំណត់ជាក់លាក់ ដែលឈានដល់ការលែងលះ។ ក្រោយពីបានរស់នៅក្នុងចំណងអាពាហ៍ពិពាហ៍ហើយប្រសិនបើ សហព័ទ្ធណាមួយយល់ឃើញថា ជីវិតអាពាហ៍ពិពាហ៍របស់ខ្លួន ពុំអាចបន្តរស់នៅជាមួយគ្នាតទៅ ទៀតបាន ដោយបានលើកឡើងនូវមូលហេតុ មកធ្វើការសំអាងយ៉ាងច្បាស់លាស់តាមបញ្ញត្តិដែល មានចែងនៅក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

### កថាខណ្ឌទី២.ប្រភេទនៃការលែងលះ

#### ១.ការលែងលះគ្នាដោយមានកំហុស

តាមការលែងលះគ្នាដោយមានកំហុសសហព័ទ្ធម្នាក់អាច លែងលះបាន ប្រសិនបើសហព័ទ្ធនោះអាចបង្ហាញឱ្យឃើញថា សហព័ទ្ធម្នាក់ទៀតបានប្រព្រឹត្តកំហុស ដែលសង្គមទទួលស្គាល់ថា មានលក្ខណធ្ងន់ធ្ងរល្មមនឹងបញ្ចប់ចំណងអាពាហ៍ពិពាហ៍។ ជាទូទៅ កំហុសនានាដែលសង្គមបានសម្រេចថា ធ្ងន់ធ្ងរល្មមនឹងបញ្ចប់ចំណងអាពាហ៍ពិពាហ៍ ត្រូវបានរៀបរាប់នៅក្នុងក្រមរដ្ឋប្បវេណី[31]។

ការលែងលះគ្នាដោយកំហុស គឺផ្អែកលើគំនិតថា អាពាហ៍ ពិពាហ៍ គឺជាការប្ដេជ្ញាអស់មួយជីវិត ដែលមនុស្សម្នាក់ៗ មិនត្រូវឱ្យ រួចពីកាតព្វកិច្ចដោយងាយៗពីការប្ដេជ្ញាចិត្តនោះទេ។ ប៉ុន្តែការ លែងលះគ្នាដោយកំហុសបានទទួលស្គាល់ថា នៅក្នុងកាលៈ ទេសៈខ្លះ សហព័ទ្ធម្នាក់ត្រូវបានអនុញ្ញាតឱ្យដកខ្លួនពីចំណងអា ពាហ៍ពិពា

[31] ទំព័រ ១៨៥ កថាខណ្ឌទី១ សៀវភៅ នីតិគ្រួសារ និង អាពាហ៍ពិពាហ៍

ហ៍។ កាលៈទេសៈទាំងនេះកើតមានជាទូទៅ នៅពេល ដែលសហព័ទ្ធម្នាក់បានប្រព្រឹត្តអំពើល្មើសដ៏ធ្ងន់ធ្ងរលើករណីយ កិច្ចជាប្ដីប្រពន្ធ[32]។

តាមប្រពៃណី ប្រទេសជាច្រើនបានប្រើប្រព័ន្ធការលែងលះ គ្នាដោយផ្អែកលើកំហុស។ ការទទួលយកការលែងលះគ្នានៅក្រោមប្រព័ន្ធច្បាប់ដែលផ្អែកលើកំហុសអាចជាការលំបាកណាស់។ នេះព្រោះតែសហព័ទ្ធដែលលែងលះគ្នា ត្រូវតែបង្ហាញដល់ តុលាការនូវភស្តុតាងនៃកំហុសមួយក្នុងចំណោមកំហុសនានា ដែល បានរៀបរាប់នៅក្នុងច្បាប់។

ឧទាហរណ៍ ប្រសិនបើសហព័ទ្ធមានកំហុសបដិសេធថា មិនបាន ប្រព្រឹត្តកំហុស ហើយពុំមានភស្តុតាងនៃកំហុសទៀតផង តុលាការ ប្រហែលជាមិនជឿសហព័ទ្ធដែលបានប្ដឹងសុំលែងលះនោះទេ។

**២.ការលែងលះគ្នាដោយឥតកំហុស**

ផ្ទុយទៅវិញការលែងលះគ្នាដោយឥតកំហុស សហព័ទ្ធម្នាក់ មិនចាំបាច់ត្រូវបង្ហាញកំហុសរបស់សហព័ទ្ធម្នាក់ទៀត ដើម្បីផ្ដាច់ ចំណងអាពាហ៍ពិពាហ៍នោះទេ។ ដូចនេះ នៅក្រោមគោលការណ៍នៃការលែងលះគ្នាដោយឥតកំហុស សហព័ទ្ធម្នាក់អាចទទួលបាន ការលែងលះគ្នា ដោយសារតែសហព័ទ្ធនោះលែងមានសេចក្ដីសប្បាយចិត្តក្នុងចំណងអាពាហ៍ពិពាហ៍ទៀតប៉ុណ្ណោះ។ តាមធម្មតា វិធាននៃការលែងលះគ្នាដោយឥតកំហុសមានភាពងាយស្រួល ជាងប្រព័ន្ធនៃការលែងលះគ្នាដែលផ្អែកលើកំហុស ដោយហេតុថា ភាគីដែលស្វែងរកការលែងលះមិនចាំបាច់បង្ហាញពីកំហុស[33]។

ច្បាប់ស្ដីពីការលែងលះគ្នាដោយឥតកំហុស មានច្រើន ប្រភេទ។ ឧទាហរណ៍នៅក្រោមច្បាប់ស្ដីពីការលែងលះគ្នាដោយ ឥតកំហុស សហព័ទ្ធដែលចង់បានការលែងលះគ្នាគ្រាន់តែបង្ហាញ ថា អាពាហ៍ពិពាហ៍ «ត្រូវបែកបាក់មិនអាចស្រោចស្រង់វិញបាន» ឬថា មាន «ទំនាស់មិនអាចផ្សះផ្សាបាន» រវាងសហព័ទ្ធទាំងពីរ។ ច្បាប់ស្ដីពីការលែងលះគ្នាដោយឥតកំហុសផ្សេងទៀត ការលែង លះនេះត្រូវបានអនុញ្ញាត ប្រសិនបើប្ដីប្រពន្ធបានរស់នៅបែកគ្នា ក្នុងរយៈពេលជាក់លាក់មួយ។

ការលែងលះគ្នាដោយឥតកំហុសគឺផ្អែកទៅលើសញ្ញាណ ទំនើបនៃសុភមង្គលផ្ទាល់ខ្លួន ច្រើនជាងការលែងលះគ្នាដោយផ្អែកលើកំហុស។ គំនិតមួយនៅពីខាងក្រោយការលែងលះគ្នាដោយឥត កំហុស គឺថា មនុស្សត្រូវតែមានសេរីភាពក្នុងការបញ្ចប់ទំនាក់ទំនង ដែលលែងជាប្រភពនៃការពេញចិត្តផ្ទាល់ខ្លួនតទៅទៀត។ ការ

[32] ទំព័រ ១៨៥ កថាខណ្ឌទី២ សៀវភៅ នីតិគ្រួសារ និង អាពាហ៍ពិពាហ៍

[33] ទំព័រ ១៨៧ កថាខណ្ឌទី១ សៀវភៅ នីតិគ្រួសារ និង អាពាហ៍ពិពាហ៍

លែង លះគ្នាដោយឥតកំហុសនេះ ក៏ត្រូវផ្អែកទៅលើទស្សនៈដែលថា ប្រសិនបើសហព័ទ្ធម្នាក់ពិតជាមានបំណងលែងលះមែន វាពុំមែន ជាការល្អទេក្នុងការបង្ខំឱ្យសហព័ទ្ធនោះ ឱ្យនៅរក្សាចំណងអាពាហ៍ពិពាហ៍។

**៣.ការលែងលះគ្នាដោយការព្រមព្រៀង**

វិធីលែងលះគ្នាជាទូទៅ ទី៣ គឺការលែងលះគ្នាដោយការ ព្រមព្រៀងគ្នាទៅវិញទៅមក[34]។ តាមវិធីនេះការលែងលះគ្នាត្រូវបាន អនុញ្ញាត នៅពេលដែលភាគីទាំងពីរព្រមព្រៀងលែងលះគ្នាដោយ ស្ម័គ្រចិត្ត។ នៅក្នុងករណីខ្លះ ភាគីទាំងពីររស់នៅជាមួយគ្នាយូរទៅ អស់និស្ស័យជាមួយគ្នា ឬហៅថា លែងមានចិត្តស្រឡាញ់គ្នាវៀងៗ) ភាគីទាំងពីរ អាចសម្រេចចិត្តលែងលះគ្នាដោយស្ម័គ្រចិត្តដោយគ្មានកំហុសរបស់ភាគីណាមួយ។ ច្បាប់ត្រូវ (ខ្លួនបង្កើតឡើងដោយ ឈរលើទស្សនៈគោរពសិទ្ធិ និងការសម្រេចចិត្តរបស់បុគ្គលជារឿង សំខាន់ ដូច្នេះ បើភាគីទាំងពីរអស់និស្ស័យនឹងគ្នា ឬមិនអាចរស់នៅ ជាមួយគ្នាតទៅទៀតបាន គេមិនអាចបង្ខំមនុស្សដែលមិនចង់រស់ នៅជាមួយគ្នាឱ្យបន្តរស់នៅជាមួយគ្នាតទៅទៀតបានទេ ច្បាប់បាន គោរពសេចក្តីសម្រេចចិត្តរបស់ភាគីទាំងពីរ ក្នុងការព្រមព្រៀង លែងលះគ្នា ប៉ុន្តែការព្រមព្រៀងនេះ មិនត្រូវមានការគំរាមកំហែង ការបង្ខិតបង្ខំពីភាគី ឬពីតតិយជនឡើយ។

## ផ្នែកទី២.នីតិវិធីនៃការប្តឹងលែងលះគ្នា

ដំណើរការនៃការលែងលះ ចាប់ផ្តើមពីពេលដែលសហព័ទ្ធ មួយ ឬសហព័ទ្ធទាំងពីរដាក់ពាក្យប្តឹងសុំលែងលះ។ បណ្តឹងគឺជា ឯកសារផ្លូវច្បាប់ដែលភាគីមួយដាក់ប្រឆាំងនឹងភាគីមួយទៀត ដែល ថ្លែងកើតទុក្ខមិនសុខចិត្តដើម្បីឱ្យប្រព័ន្ធច្បាប់ជួយដោះស្រាយ។ ដើម្បីដោះស្រាយ និងសម្រេចឱ្យបានត្រឹមត្រូវតាមច្បាប់ករណីការលែងលះគ្នានៃការរៀបអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមលក្ខណច្បាប់ ភាគីត្រូវដាក់ប្តឹង និងត្រូវដោះស្រាយតាមផ្លូវតុលាការ ចំណែកការ រៀបអាពាហ៍ពិពាហ៍ដែលមិនត្រឹមត្រូវតាមច្បាប់ តុលាការមិន ទទួលការដោះស្រាយបណ្តឹងលែងលះគ្នាឡើយ ដែលធ្វើឱ្យមាន ផលវិបាកមួយចំនួនដែលយើងនឹងសិក្សានៅខាងក្រោមនេះ។

**១.ការផ្តើមនៃបណ្តឹង**

**១.១.ការសរសេរពាក្យបណ្តឹង**

បណ្តឹងសុំលែងលះគ្នា ត្រូវធ្វើជាលាយលក្ខណ៍អក្សរដោយ ត្រូវរៀបរាប់អំពីមូលហេតុដែលសហព័ទ្ធសុំលែងលះគ្នា ហើយត្រូវ ចុះហត្ថលេខាដោយសហព័ទ្ធដែលជាអ្នកប្តឹង។ សហព័ទ្ធដែលជា អ្នកដាក់ពាក្យប្តឹងហៅថា «ភាគីដើមបណ្តឹង»ឬ«ដើមចោទ»។ សហព័ទ្ធទទួលរងការប្តឹងនោះហៅថា ចុងចម្លើយ ។

[34] ទំព័រ ១៨៩ សៀវភៅ នីតិគ្រួសារ និង អាពាហ៍ពិពាហ៍

មាត្រា៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណីបានចែងអំពីរបៀបនៃ ការដាក់ពាក្យបណ្ដឹង និងចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្ដឹង ដូចតទៅ ៖

- ពាក្យប្ដឹងត្រូវសរសេរជាលាយលក្ខណ៍អក្សរ និងប្ដឹងទៅ តុលាការសាលាដំបូងនៃលំនៅដ្ឋានរបស់ភាគីចុងចម្លើយ
- នៅក្នុងលិខិតនៃពាក្យបណ្ដឹង ត្រូវសរសេរបញ្ជាក់នូវ ចំណុចសំខាន់ៗដូចខាងក្រោមៈ
  - ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់ភាគីហើយនិងឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។
  - ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យ តុលាការចេញ និងអង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ។
- នៅក្នុងពាក្យបណ្ដឹង ដើមចោទគប្បីសរសេរបញ្ជាក់ឱ្យច្បាស់លាស់នូវអង្គហេតុ ដែលជាមូលហេតុនៃការទាមទារនិងតាមចំណុចដែលត្រូវសរសេរបញ្ជាក់ភស្តុ តាង គប្បីសរសេរបញ្ជាក់នូវអង្គហេតុសំខាន់ៗក្នុងចំណោមអង្គហេតុទាំងមូលដែលទាក់ទងនឹងអង្គហេតុដែលជាមូលហេតុនៃការទាមទារ និងភស្តុតាង។
- ពាក្យបណ្ដឹងត្រូវមានសរសេរអំពីមធ្យោបាយទប់ទល់និងការការពារខ្លួន។

ច្បាប់កម្ពុជា ប្ដី និងប្រពន្ធទាំងពីរនាក់មានសិទ្ធិដាក់ពាក្យប្ដឹង សុំលែងលះគ្នា។ ប៉ុន្តែ ច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ចែង ថា ចំពោះប្ដីដែលប្រពន្ធខ្លួនមានផ្ទៃពោះ អាចនឹងសុំលែងលះបាន លុះត្រាតែប្រពន្ធនោះសម្រាលកូនរួចបានមួយឆ្នាំសិន ។ នៅក្នុង ក្រមរដ្ឋប្បវេណីថ្មីមិនមានចែងអំពីចំណុចនេះទេ។

នៅក្នុងពាក្យបណ្ដឹង ភាគីដើមចោទត្រូវបង់ប្រាក់ប្រដាប់ក្ដី ៥០០០ រៀល សម្រាប់ពន្ធដាក់ពាក្យសុំ និងប្រាក់ប្រដាប់ក្ដីក្រៅពី ពន្ធ ដូចជា ចំនួនទឹកប្រាក់ចាំបាច់ដើម្បីឱ្យតុលាការពិនិត្យភស្ដុតាងការបញ្ជូនឯកសារ ឬចំនួនទឹកប្រាក់សម្រាប់សោហ៊ុយធ្វើដំណើរ និងសោហ៊ុយស្នាក់នៅរបស់ចៅក្រម និងក្រឡាបញ្ជីក្នុងករណីមាន ការពិនិត្យភស្ដុតាង និងសោហ៊ុយសកម្មភាពផ្សេងទៀតតាមនីតិវិធី ក្នុងបណ្ដឹងរដ្ឋប្បវេណី ដើម្បីដំណើរការស៊ើបអង្កេតរឿងនោះ ។ ប៉ុន្តែចំនួនប្រាក់ប្រដាប់ក្ដីសម្រាប់ភាគីដែលទទួលបន្ទុកចេញ គឺភាគី ដែលចាញ់ក្ដីជាអ្នកទទួលបន្ទុកចេញសងវិញ។

### **១.២.ទីកន្លែងដាក់ពាក្យបណ្ដឹង**

សម្រាប់អាពាហ៍ពិពាហ៍ដែលត្រឹមត្រូវតាមច្បាប់ កន្លែងដាក់ ពាក្យបណ្ដឹងមានពីរ ដើម្បីឱ្យភាគីជ្រើសរើសដាក់ពាក្យប្ដឹងសុំលែង លះ។ ភាគីដើមបណ្ដឹងអាចដាក់ពាក្យប្ដឹងដោយផ្ទាល់ទៅតុលាការ រាជធានី ឬខេត្តខាងលំនៅឋានរបស់ភាគីចុងចម្លើយ ឬក៏ភាគីដើម ចោទអាចដាក់ពាក្យប្ដឹងជាមួយមេឃុំ ឬចៅសង្កាត់ខាងលំនៅរបស់ ភាគីចុងចម្លើយក៏បាន។ ក្នុងករណីដែលភាគីចុងចម្លើយមិនមាន លំនៅឋាន ឬមានលំនៅឋានមិនពិត

ប្រាកដក្នុងប្រទេសកម្ពុជា អាចដីកាដែលទទួលស្គាល់ការទាមទាររបស់ដើមចោទ នៅក្នុងបណ្តឹង ទាមទារលុបចោលចំណងអាពាហ៍ពិពាហ៍ ឬលែងលះគ្នា តុលាការ ត្រូវធ្វើការសម្រេចសេចក្តីអ្នកមានអំណាចមេបា ដោយឆន្ទានុសិទ្ធិ ឬការចាត់ចែងទាក់ទងនឹងការបែងចែកទ្រព្យសម្បត្តិ ការបង្គាប់ឱ្យ ភាគីប្រគល់កូន ឬបង់ប្រាក់ឬក៏ផ្តល់តាវកាលិកផ្សេងៗទៀត ។

**២.ការផ្សះផ្សា**

ក្រោយពេលដែលក្រុមប្រឹក្សាឃុំ សង្កាត់ ឬតុលាការបាន ទទួលពាក្យបណ្តឹងជាផ្លូវការ ដែលភាគីទាមទារលែងលះគ្នាហើយ ក្រុមប្រឹក្សាឃុំ សង្កាត់ និងតុលាការត្រូវមាននីតិវិធីសំខាន់មួយគឺ ការផ្សះផ្សា។

នៅកម្ពុជា ការផ្សះផ្សាគឺជាផ្នែកមួយដ៏សំខាន់បំផុតនៃនីតិវិធី លែងលះគ្នា។ មុនពេលប្តីប្រពន្ធត្រូវបានអនុញ្ញាតឱ្យលែងលះគ្នា ក្រមរដ្ឋប្បវេណីថ្មី ក៏ដូចជាច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ចាស់ បានតម្រូវឱ្យប្តីប្រពន្ធចូលរួមនៅក្នុងដំណើរការនៃការផ្សះផ្សាដែល មានគោលបំណងរក្សាចំណងអាពាហ៍ពិពាហ៍ឱ្យនៅគង់វង្ស។តម្រូវការនេះឆ្លុះបញ្ចាំងឱ្យឃើញនូវតម្លៃដែលសង្គមខ្មែរបានយក ចិត្តទុកដាក់ចំពោះចំណងអាពាហ៍ពិពាហ៍ជានិរន្តរ៍។

ការផ្សះផ្សា ធ្វើឡើងដោយមានការដាក់កំហិតយ៉ាងតឹងរឹង ស្របតាមឆន្ទៈសេរីរបស់ភាគីទាំងពីរ ដូច្នេះមានន័យថា ត្រូវធ្វើ ឡើងតាមការស្ម័គ្រចិត្តជាដាច់ខាត។

**២.១.ការផ្សះផ្សានៅថ្នាក់ឃុំសង្កាត់**

ប្រសិនបើមនុស្សម្នាក់បានប្តឹងទៅក្រុមប្រឹក្សាឃុំឬសង្កាត់ មន្ត្រីទាំងនោះត្រូវសាកល្បងធ្វើការផ្សះផ្សាក្នុងរយៈពេល ១៥ថ្ងៃ ក្រោយពីបានទទួលពាក្យប្តឹង។ ប្រសិនបើភាគីទាំងពីរពុំព្រមបន្ត ការរួមរស់ជាមួយគ្នាទេ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវចាត់ទុកថា មាន ពាក្យបណ្តឹងសុំលែងលះ ហើយក្រុមប្រឹក្សាបញ្ជូនពាក្យបណ្តឹងទៅតុលាការ «ជាបន្ទាន់។»។ ទោះបីជាក្រមរដ្ឋប្បវេណីមិនមានចែងថា ការផ្សះផ្សាត្រូវធ្វើឡើងច្រើនដងក៏ដោយ ប៉ុន្តែនៅក្នុងការអនុវត្ត ក្រុមប្រឹក្សាឃុំ សង្កាត់ ទាំងនោះអាចព្យាយាមធ្វើការផ្សះផ្សាជាច្រើន ដងមុននឹងបញ្ជូនរឿងនេះទៅតុលាការ។ ក្រុមប្រឹក្សាឃុំ សង្កាត់ ពុំ មានអំណាចសម្រេចឱ្យមានការលែងលះគ្នា ឬសម្រេចអំពីការថែ រក្សាកូន ការជួយផ្គត់ផ្គង់សហព័ទ្ធ ឬការបែងចែកទ្រព្យសម្បត្តិ។

**២.២.ការផ្សះផ្សាដោយតុលាការ**

នីតិវិធីនៅតុលាការមានលក្ខណៈដូចគ្នា មិនថា តុលាការ ទទួលពាក្យបណ្តឹងដោយផ្ទាល់ពីភាគីដើមចោទ ឬតុលាការទទួល ពាក្យបណ្តឹងពីមេឃុំ ឬចៅសង្កាត់ទេ។ ក្រោយពេលទទួលពាក្យបណ្តឹងតុលាការត្រូវចាត់តាំងចៅក្រមមួយរូបដើម្បីធ្វើការផ្សះផ្សា។

ទោះបីជាសហព័ទ្ធម្ខាង ទាមទារលែងលះគ្នាខ្លាំងយ៉ាងណា ក៏ដោយ តុលាការអាចនឹងធ្វើការផ្សះផ្សាដោយឆន្ទានុសិទ្ធិ "។ ជា ពិសេសក្នុងករណីពិនិត្យឃើញថា ប្តីប្រពន្ធមានកូនជាអនីតិជន ឬ ក្នុងករណីប្តីប្រពន្ធម្ខាងទៀតជួបប្រទះការលំបាកផ្នែកសេដ្ឋកិច្ច។

ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណីមិនបានចែង លម្អិតអំពីនីតិវិធីដែលត្រូវធ្វើការផ្សះផ្សាដោយតុលាការទេ ប៉ុន្តែនៅ ក្នុងច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ មានការចែងលម្អិតអំពី នីតិវិធីដែលត្រូវផ្សះផ្សាដោយតុលាការនេះ។

## ៣.វិធានការចាត់ចែងរក្សាការពារ

ពេលខ្លះដើម្បីបានការលែងលះគ្នា គឺត្រូវការពេលវេលាមួយ យ៉ាងវែង ជាពិសេសពេលមានការសាកល្បងជាច្រើនលើក ដើម្បី ផ្សះផ្សាសហព័ទ្ធទាំងនោះ។នៅពេលមានករណីខ្លះដូច្នេះ តុលាការ អាចនឹងចេញវិធានការបណ្តោះអាសន្ន វិធានការចាត់ចែងរក្សាការពារ ដើម្បីដោះស្រាយបញ្ហាខ្លះរវាងសហព័ទ្ធនោះ ក្នុងពេលគេរង់ចាំសាលក្រមស្ថាពរនៃការលែងលះ។ វិធានការនេះ គឺ ជាការណែនាំ ឬបញ្ជាដែលតុលាការបង្គាប់ទៅភាគីទាំងអស់ហើយ ដែលតុលាការត្រូវចុះក្នុងកំណត់ត្រារបស់តុលាការ។ វិធានការទាំង នេះមានលក្ខណជា«បណ្តោះអាសន្ន» ព្រោះមានប្រសិទ្ធភាពតែក្នុង រយៈពេលសំណុំរឿងលែងលះនៅក្នុងស្ថានភាពរង់ចាំ។ នៅពេល ដែលតុលាការចេញសាលក្រមស្ថាពរ សាលក្រមស្ថាពរនោះនឹង ជំនួសឱ្យវិធានការបណ្តោះអាសន្នរបស់តុលាការ។

### ៣.១វិធានការឱ្យសហព័ទ្ធត្រូវតែរស់នៅបែកគ្នា

ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ អនុញ្ញាតឱ្យតុលាការ ចេញវិធានការឱ្យភាគីទាំងពីររស់នៅបែកគ្នាបណ្តោះអាសន្ន ក្នុងកំ ឡុងពេលនៃនីតិវិធីលែងលះគ្នា ក្នុងករណីភាគីទាំងពីរមានប្រើអំពើ ហិង្សាក្នុងគ្រួសារ។ ប៉ុន្តែក្រមរដ្ឋប្បវេណីថ្មី មិនមានចែងអំពីវិធាន - ការឱ្យសហព័ទ្ធត្រូវតែរស់នៅបែកគ្នាបណ្តោះអាសន្នទេ ក្នុងករណីភាគីទាំងពីរមានប្រើអំពើហិង្សាក្នុងគ្រួសារ និងបានប្តឹងសុំលែងលះគ្នា តើតុលាការត្រូវដោះស្រាយបណ្តឹងសំអាងលើច្បាប់អ្វី? ករណី នេះ ប្រហែលជាពួកគេពឹងផ្អែកទៅលើច្បាប់ស្តីពីការទប់ស្កាត់អំពើ ហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ដែលផ្តល់អំណាច ទៅឱ្យមេឃុំ ចៅសង្កាត់ក្នុងដំណាក់កាលនៃការជួយអន្តរាគមលើក ដំបូង។

មាត្រា១៤ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ បានផ្តល់សិទ្ធិអំណាចទៅដល់មេឃុំ ចៅសង្កាត់ អាចចាត់វិធានការបណ្តោះអាសន្នដែលមានដូចជា ៖

- ហាមប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារដោយខ្លួនឯងផ្ទាល់ ឬ ដោយអ្នកផ្សេង។
- ហាមបំផ្លាញទ្រព្យសម្បត្តិ ឬណែនាំកុំឱ្យចាត់ចែងលក់ ទ្រព្យសម្បត្តិរួមឬរបស់ជនរងគ្រោះ ឬ របស់ញាតិសាលោហិតរបស់ជនរងគ្រោះ។

- ហាមជនមុខសញ្ញាចូលទៅជិត ឬចូលទៅក្នុងទីលំនៅរួម កន្លែងស្នាក់នៅ ឬកន្លែងធ្វើការរបស់ជនរងគ្រោះ បើគ្មាន ការអនុញ្ញាតពីជនរងគ្រោះ និងអាជ្ញាធរមានសមត្ថកិច្ច។
- ចាត់វិធានការស្របច្បាប់ផ្សេងទៀតដែលចាំបាច់សម្រាប់ ការពារសុវត្ថិភាពជនរងគ្រោះ និងសមាជិកគ្រួសារ ឬជនដែលពាក់ព័ន្ធ។

ទន្ទឹមនឹងការធ្វើអន្តរាគមន៍របស់អាជ្ញាធរមានសមត្ថកិច្ច ជន រងគ្រោះក៏អាចធ្វើបណ្តឹងទៅតុលាការរាជធានី ខេត្ត ដើម្បីសុំចេញ ដីកាការពារ។ តុលាការដែលទទួលបណ្តឹងដើម្បីចាត់ការ អាចចេញដីកាការពារដោយមានវត្តមាន ឬពុំចាំបាច់មានវត្តមានសហ ព័ទ្ធដែលបានប្រើអំពើហិង្សា។

### ៣.២.វិធានការឲ្យមានការថែរក្សាកូនបណ្តោះអាសន្ន

ប្រសិនបើភាគីទាំងពីរមិនព្រមព្រៀងគ្នាលើការថែរក្សាកូន ក្នុងកំឡុងពេលនៃនីតិវិធីលែងលះគ្នា ចៅក្រមអាចចេញវិធានការ កំណត់ថាតើឪពុក ឬម្តាយដែលត្រូវថែរក្សាកូនជាបណ្តោះអាស ន្ន។ ដូចដែលយើងនឹងពិភាក្សាជាលម្អិតនៅពេលក្រោយ ឪពុកម្តា យដែលទទួលភារៈ «ថែរក្សាកូន» ជាទូទៅមានន័យថា ជាឪពុកម្តា យដែលមានអំណាចធ្វើសេចក្តីសម្រេចទាក់ទងនឹងកូន ដែលច្បាប់ហៅថា «ឪពុកម្តាយមានអំណាចមេបា» ហើយជាឪពុកម្តាយដែល រស់នៅជាមួយកូននោះ។

## ៤.ការដោះស្រាយបណ្តឹងអាពាហ៍ពិពាហ៍មិនស្របច្បាប់

ដូចដែលយើងបានសិក្សាពីខាងដើមខ្លះហើយ ក្នុងករណី នៃអាពាហ៍ពិពាហ៍ដែលមិនស្របច្បាប់ សំដៅដល់ការដែលរៀបអាពាហ៍ពិពាហ៍ហើយមិនបានទៅចុះ សំបុត្រអាពាហ៍ពិពាហ៍(មិនបានរៀបអាពាហ៍ពិពាហ៍ខាងស៊ីវិល) ឬករណីដែលភាគីមិនបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ហើយរស់នៅជាមួយគ្នាជាប្តីប្រពន្ធ។ ការរស់នៅជាមួយគ្នាដោយមិនរៀបអាពាហ៍ពិពាហ៍បែបនេះ ក៏មាន អ្នកដែលស្រឡាញ់ភេទដូចគ្នាផងដែរ (ឬហៅថាភេទី ៣)។ ការរស់ នៅរបៀបនេះជាការរស់នៅរបៀបជាសង្សារនឹងគ្នា ដែលច្បាប់ ហៅថា ការរស់នៅរបៀប«អនីតិសង្វាស»។មានករណីខ្លះពួកគេមានទ្រព្យសម្បត្តិរួមគ្នា ហើយករណីខ្លះ ទៀត មានកូនជាមួយគ្នា។ ក្នុងករណីដែលមានការលែងលះគ្នាគេត្រូវប្តឹងទៅខាងណា ហើយតើការបែងចែកទ្រព្យសម្បត្តិ និងការ បែងចែកកូន តើត្រូវធ្វើយ៉ាងណា?

ឧទាហរណ៍ អនាគតប្តីប្រពន្ធពីរនាក់នោះមានបំណងនឹងរៀប អាពាហ៍ពិពាហ៍ ដោយមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍នៅចំពោះ មុខមន្ត្រីអត្រានុកូលដ្ឋាន ដែលហៅថា «ការចុះអេតាស៊ីវិល ឬរៀប អាពាហ៍ពិពាហ៍ខាងស៊ីវិល»។ ឧបមាថាប្តីប្រពន្ធទាំង២មិនដែល បានទាក់ទងជាមួយរដ្ឋអំណាច ហើយបានត្រឹមតែរៀបចំអាពាហ៍ ពិពាហ៍នៅលំនៅឋានដោយមានព្រះសង្ឃ និងញាតិមិត្តចូលរួមដឹង ឮ ឬគ្រាន់តែរៀបចំពិធីសែនព្រេន ដើម្បីរំលឹកនិងជំរាបដំណឹងដល់ ដូនតាដែលចែកឋានទៅដើម្បីកុំឱ្យពួកគាត់ប្រកែប្រកាន់ (កាច់កូន ចៅ)។ នៅក្នុង

ករណីនេះជាការច្បាស់ណាស់ថា ប្តីប្រពន្ធនោះមិន បានបំពេញជាដុំកំភួនទៅតាមតម្រូវការនៃនីតិវិធីច្បាប់ ដើម្បីឱ្យ អាពាហ៍ពិពាហ៍នោះមានលក្ខណត្រឹមត្រូវតាមច្បាប់។ បុរសស្ត្រី នោះយល់ដោយខុសថាគេបានរៀបអាពាហ៍ពិពាហ៍ត្រឹមត្រូវតាម លក្ខណច្បាប់ ព្រោះគេបានរៀបពិធីមង្គលការតាមប្រពៃណីខ្មែរ ហើយ តើច្បាប់ទទួលស្គាល់អាពាហ៍ពិពាហ៍របស់គេថា មានតម្លៃ ត្រឹមត្រូវតាមច្បាប់ដែរឬទេ?

ប្រទេសផ្សេងៗទៀត បានដោះស្រាយរឿងហេតុនេះដោយ វិធីផ្សេងៗ។ នៅក្នុងប្រទេសជាច្រើន ការខកខានមិនបានប្រារព្ធ ពិធីចុះបញ្ជីអាពាហ៍ពិពាហ៍ ឬហៅថា ការចុះអេតាស៊ីវិល គឺជាការរំលោភខាងនីតិវិធីច្បាប់ធ្ងន់ធ្ងរណាស់ ដែលនឹងធ្វើឱ្យប៉ះពាល់ដល់ លក្ខណត្រឹមត្រូវតាមច្បាប់របស់អាពាហ៍ពិពាហ៍។ នៅក្នុងប្រទេសទាំងនោះច្បាប់មិនទទួលស្គាល់ថា «អាពាហ៍ពិពាហ៍ជាផ្លូវការទេ, បើមិនមានពិធីចុះបញ្ជីអាពាហ៍ពិពាហ៍ ឬពិធីចុះអេតាស៊ីវិលនៅ ចំពោះមុខអាជ្ញាធរមានសមត្ថកិច្ច។ នេះជាការពិតណាស់នៅក្នុង ប្រទេសបារាំង និងនៅក្នុងប្រទេសជាច្រើនផ្សេងទៀតដែលនៅ ក្រោមឥទ្ធិពលនៃច្បាប់បារាំង។ ទម្រង់បែបនេះ កើតមានដោយ សារប្រវត្តិសាស្ត្របារាំងបានផ្តល់ជាគំរូយ៉ាងច្រើននៅក្នុងច្បាប់ របស់ប្រទេសនានា ជាពិសេស ទៅលើចុះបញ្ជីអាពាហ៍ពិពាហ៍ ឬ ការចុះអេតាស៊ីវិល។

ប៉ុន្តែនៅប្រទេសដទៃទៀត នៅក្នុងកាលៈទេសៈខ្លះច្បាប់នឹង ទទួលស្គាល់ថា «អាពាហ៍ពិពាហ៍» មួយមានលក្ខណត្រឹមត្រូវតាម ច្បាប់ ទោះបីជាមិនមានពិធីចុះបញ្ជីអាពាហ៍ពិពាហ៍ ឬការចុះអេតា ស៊ីវិលក៏ដោយ។ តម្រូវឱ្យអាពាហ៍ពិពាហ៍នោះបំពេញលក្ខខណ្ឌ ៣ ដូចតទៅ ដើម្បី អាពាហ៍ពិពាហ៍នោះមានលក្ខណត្រឹមត្រូវតាមច្បាប់ ៖

- អនាគតប្តីប្រពន្ធនោះមានបំណង និងយល់ព្រមភ្ជាប់ ចំណងអាពាហ៍ពិពាហ៍
- ប្តីប្រពន្ធបាននិងកំពុងរស់នៅជាមួយគ្នា ។
- ប្តីប្រពន្ធថ្លែងប្រាប់សហគមន៍ថា បានរៀបអាពាហ៍ ពិពាហ៍។

### ៤.១.ការលែងលះគ្នានៃអាពាហ៍ពិពាហ៍ដែលមិនស្របច្បាប់

ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ មិនបានចែងអំពីនីតិវិធីសម្រាប់ ការលែងគ្នាសម្រាប់ការរៀបអាពាហ៍ពិពាហ៍ដែលមិនត្រឹមត្រូវតាម លក្ខណច្បាប់ទេ។

ការសាកសួរចៅក្រមជាច្រើននៅក្នុងឆ្នាំ២០១២បានបង្ហាញថា នៅពេលដែលភាគីមិនចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ ឬមិនបានចុះ អេតាស៊ីវិលពេញលេញលក្ខណច្បាប់ នៅពេលមានបណ្តឹងលែង លះគ្នាកើតឡើងនៅពេលប្តឹងទៅតុលាការ តុលាការមិនទទួល ពាក្យបណ្តឹងលែងលះគ្នាទេ គេត្រូវដោះស្រាយបញ្ហាដោយខ្លួនឯង ប៉ុន្តែក្នុងករណីដែលភាគីបានព្រមព្រៀងលែងលះគ្នា ភាគីអាចទៅ ផ្តិតមេដៃលែងលះគ្នានៅសាលាឃុំសង្កាត់ដើម្បីឱ្យមេឃុំ ចៅ សង្កាត់ដឹងឮ និងធ្វើជាសាក្សី។ មេឃុំ ចៅសង្កាត់មានសិទ្ធិសម្រុះ សម្រួលដើម្បីឱ្យភាគីត្រូវរ៉ូវគ្នា

វិញ ប៉ុន្តែមិនមានសិទ្ធិសម្រេចឱ្យភាគី លែងលះគ្នា។ ដូចគ្នាដែរ ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខណ្ឌពុំមានសិទ្ធិ អំណាចដើម្បីសម្រេចរឿងក្តីបណ្តឹងលែងលះគ្នាឡើយ។

ក្នុងករណីដែលប្តីប្រពន្ធនៃអាពាហ៍ពិពាហ៍មិនស្របច្បាប់ មានកូន ឬមានទ្រព្យសម្បត្តិ ហើយភាគីមិនបានឯកភាពគ្នាក្នុងការ បែងចែកកូននិងការបែងចែកទ្រព្យសម្បត្តិទេ ភាគីអាចប្តឹងទៅ តុលាការស្នើសុំបែងចែកទ្រព្យសម្បត្តិ ការបែងចែកកូន និងទាមទារ អំណាចមេបាលើកូនបាន ប៉ុន្តែតុលាការមិនកាត់ក្តីរឿងលែងលះគ្នាទេ តុលាការសម្រេចសេចក្តីតែចំពោះរឿងបែងចែកកូន និង ការ បែងចែកទ្រព្យសម្បត្តិតែប៉ុណ្ណោះ។

បញ្ហាផលវិបាកនៃអាពាហ៍ពិពាហ៍មិនស្របច្បាប់នៅត្រង់ថា ក្នុងករណីភាគីមួយចង់លែងលះ ហើយភាគីម្ខាងទៀតមិនចង់លែង លះ តើភាគីនោះត្រូវធ្វើយ៉ាងណា។ ក្នុងករណីខ្លះទៀត ភាគីបានត្រឹមតែរៀបអាពាហ៍ពិពាហ៍ ឬបានធ្វើពិធីសែនព្រេនតាមប្រពៃណី ប៉ុន្តែ មិនបានចុះបញ្ជីអាពាហ៍ពិពាហ៍ ឬមិនបានចុះអេតាស៊ីវិល មិនអាច មានភស្តុតាងសម្រាប់ប្តឹងលែងលះគ្នា ហើយតុលាការមិនមានភស្តុតាងទទួលពាក្យបណ្តឹងលែងលះគ្នាទេ។ភាគីម្ខាងក៏មិនអាចទៅទប់ស្កាត់មិន ឱ្យភាគីម្ខាងទៀតដែលទៅរៀបអាពាហ៍ពិពាហ៍ជាមួយ ប្តីប្រពន្ធថ្មីបានដែរ ដោយគ្រាន់តែយករូបថតនៃអាពាហ៍ពិពាហ៍ ឬ រូបថតពិធីសែនព្រេនតាមប្រពៃណីទៅជាភស្តុតាងសំអាងនោះ។

## **ផ្នែកទី៣.នីតិវិធីនៃការជម្រះក្តីនិងការស៊ើបអង្កេតរបស់ចៅក្រម**

នីតិវិធីនៃការជម្រះក្តីក្នុងរឿងរដ្ឋប្បវេណី ដែលមានចែងនៅ ក្នុងក្រមនីតិវិធីរដ្ឋប្បវេណី មានលក្ខណលម្អិតជាងពេលមុនដែល ទាមទារឱ្យប្រើពេលវេលាយូរ និងមាននីតិវិធីសាំញ៉ាំជាងមុនផង ដែរសម្រាប់អាពាហ៍ពិពាហ៍ដែលស្របច្បាប់។

ប្រសិនបើការផ្សះផ្សារបស់តុលាការ មិនអាចនាំឱ្យសហព័ទ្ធ ព្រមព្រៀងគ្នាបន្តការរួមរស់ជាមួយគ្នាបានទេ នោះតុលាការនឹង ចេញដីកាកោះហៅសហព័ទ្ធឱ្យមកបង្ហាញខ្លួន ដើម្បីធ្វើការស៊ើប អង្កេតនិងវិនិច្ឆ័យពីបណ្តឹងសុំលែងលះ។

### **១.ដំណើរការទាញហេតុផលផ្ទាល់មាត់**

ដើម្បីកំណត់អំពីអង្គហេតុ និងអង្គច្បាប់អោយមានភាពច្បាស់លាស់ទាក់ទងទៅនឹងបណ្តឹងតុលាការត្រូវបង្គាប់ឱ្យភាគីទាំងពីរ ជូនភស្តុតាងចាំបាច់នានាដល់តុលាការនិងអញ្ជើញសាក្សីឱ្យចូល មកបំភ្លឺរឿងនេះដល់តុលាការ ដើម្បីឱ្យភាគីអះអាង ឬបញ្ជាក់ភស្តុ តាងនានាដល់តុលាការ ។

នៅក្នុងដំណើរការនេះ ភាគីអាចទាមទារឱ្យតុលាការសាក សួរសំណួរចាំបាច់ទៅភាគីម្ខាងទៀតបាននៅក្នុងកាលបរិច្ឆេទនៃ នីតិវិធីសម្រាប់ការទាញហេតុផលឬការទាញហេតុផលផ្ទាល់មាត់ បាន។

ច្បាប់មិនបានកំណត់កាលបរិច្ឆេទ នៅក្នុងដំណាក់កាលនៃ ការទាញហេតុផលផ្ទាល់មាត់នេះទេ។នៅក្នុងដំណាក់កាលនេះ ភាគីអាចដាក់ជូនតុលាការនូវ មធ្យោបាយការពារខ្លួន ឬមធ្យោបាយតទល់ជាមួយភាគីម្ខាងទៀត បាន ដែលធ្វើជាមូលដ្ឋានសម្រាប់ការពិចារណា និងការចេញ សាលក្រមរបស់តុលាការ។ មធ្យោបាយតទល់ជាអ្វីៗទាំងឡាយ ដែលភាគីដើមចោទដាក់ទៅតុលាការ ដើម្បីឱ្យតុលាការយកធ្វើជា មូលដ្ឋាននៃពាក្យសុំ(បណ្តឹង)រីឯមធ្យោបាយការពារខ្លួន គឺជាអ្វីៗ ទាំងឡាយដែលចុងចម្លើយដាក់ទៅតុលាការ ដើម្បីឱ្យតុលាការ យកមកធ្វើជាមូលដ្ឋាននៃពាក្យសុំប្រឆាំងតបវិញ។

**២.ឯកសារត្រៀម**

នៅពេលធ្វើនីតិវិធីត្រៀមសម្រាប់ទាញហេតុផល និងការទាញហេតុផលផ្ទាល់មាត់ តុលាការអាចបង្គាប់ឱ្យភាគីដាក់ឯកសារត្រៀមបាន។

នៅក្នុងឯកសារត្រៀម ភាគីត្រូវសរសេរអំពីមធ្យោបាយ តទល់ ឬការពារខ្លួន និងសេចក្តីថ្លែងការណ៍ចំពោះមធ្យោបាយ តទល់ ឬការពារខ្លួនរបស់ភាគីម្ខាងទៀត។

នៅក្នុងឯកសារត្រៀមដែលចុងចម្លើយដាក់ទៅតុលាការ លើកដំបូង ត្រូវសរសេរអំពីការឆ្លើយតបចំពោះខ្លឹមសារនៃសាល ក្រមដែលដើមចោទបានសរសេរទាមទារនៅក្នុងពាក្យបណ្តឹង និង ការទទួលស្គាល់ ឬមិនទទួលស្គាល់នូវអង្គហេតុដែលមានសរសេរ នៅក្នុងពាក្យបណ្តឹង និងអង្គហេតុដើម្បីតវ៉ាចំពោះអង្គហេតុដែល មានសរសេរនៅក្នុងពាក្យបណ្តឹង។

តុលាការជាអ្នកកំណត់អំពីពេលវេលាសមស្របសម្រាប់ការ ដាក់ឯកសារត្រៀមរបស់ដើមចោទ និងឯកសារតទល់ឬការពារ ខ្លួន និងសេចក្តីថ្លែងការណ៍ចំពោះមធ្យោបាយតទល់ ឬការពារខ្លួន របស់ភាគីចុងចម្លើយ។ ប៉ុន្តែច្បាប់មិនបានកំណត់ពេលវេលាច្បាស់ លាស់សម្រាប់ការដាក់ឯកសារត្រៀមនេះទេ ដើម្បីទុកឱ្យចៅក្រម ជាអ្នកមានឆន្ទានុសិទ្ធិកំណត់។

**៣.នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**

គោលបំណងនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺ តុលាការត្រូវរៀបចំសេចក្តីអះអាងរបស់ភាគីបំភ្លឺនូវចំណុចវិវាទនៃ រឿងក្តីដែលភាគីយល់ថា មិនយល់ស្របគ្នា និងរៀបចំភស្តុតាងដែលទាក់ទងនឹងចំណុចនៃរឿងក្តីនោះ ដើម្បីអាចធ្វើការវិនិច្ឆ័យ រឿងក្តីនៅក្នុងនីតិវិធីនៃការទាញហេតុផលឱ្យបានល្អិតល្អន់ៗ។

នីតិវិធីសម្រាប់ត្រៀមការទាញហេតុផលនេះខុសពីនីតិវិធី សម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ ដោយសារថា នីតិវិធី សម្រាប់ត្រៀមការទាញហេតុផលមិនបាច់ធ្វើនៅក្នុងសាលសវនា ការទេ គឺអាចធ្វើនៅក្នុងបន្ទប់ធម្មតាណាមួយ ដែលដាក់ឈ្មោះថា ជាបន្ទប់ត្រៀមក៏បានដែរ ប៉ុន្តែតុលាការមិនចាំបាច់ហាមឃាត់អ្នកផ្សេងចូលរួមសង្កេតការណ៍ទេ។

នីតិវិធីសម្រាប់ការត្រៀមទាញហេតុផលនេះ តុលាការក៏ជា អ្នកកំណត់កាលបរិច្ឆេទសមរម្យ ដែលភាគីទាំងពីរអាចចូលរួមបាន ដើម្បីគោរពគោលការណ៍ចំពោះមុខតុលាការរបស់ភាគីដែលនឹង បើកឱ្យភាគីអាចចូលរួមទាំងសងខាង។

នៅក្នុងនីតិវិធីនេះ តុលាការក៏អាចចេញដីកាសម្រេចដែល ទាក់ទងនឹងការស្នើសុំពិនិត្យភស្តុតាង ដូចជាដីកាសម្រេចបង្គាប់ឱ្យ ដាក់ឯកសារ ការស្នើសុំឱ្យផ្ញើឯកសារ ឬការប្រគល់កិច្ចការកោសល វិច័យ ដីកាសម្រេចយកឬមិនយកភស្តុតាងដែលភាគីស្នើសុំឱ្យពិនិត្យ ជាដើម។ តុលាការក៏អាចចេញដីកាសម្រេចផ្សេងៗទៀត ដូចជា ការអនុញ្ញាត ឬមិនអនុញ្ញាតបន្ថែម ឬប្តូរកម្មវត្ថុនៃបណ្តឹងការសម្រេចសេចក្តីស្តីអំពីការអនុញ្ញាតការចូលរួមអន្តគមន៍ ឬមិនអនុញ្ញាតជាដើម។

**៤.ការទាញហេតុផលផ្ទាល់មាត់**

ដើម្បីចេញសាលក្រមលើបណ្តឹងលែងលះគ្នា តុលាការ ចាំបាច់ត្រូវឆ្លងកាត់នូវការទាញហេតុផលដោយផ្ទាល់មាត់។ ប៉ុន្តែ ចំពោះរឿងក្តី ឬចំណុចណាដែលត្រូវសម្រេចដោយដីកាសម្រេច តុលាការត្រូវកំណត់ថាត្រូវធ្វើការទាញហេតុផលផ្ទាល់មាត់ ឬមិន ធ្វើ។ ក្នុងករណីដែលតុលាការសម្រេចមិនធ្វើការទាញហេតុផល ផ្ទាល់មាត់ តុលាការអាចសាកសួរភាគីបាន។

មាត្រា១៦ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈ បុគ្គលចែងថា ការទាញហេតុផលផ្ទាល់មាត់នៃបណ្តឹងលែងលះគ្នា ឬបណ្តឹងទាក់ទងនឹងឋានៈបុគ្គល តុលាការមិនអាចធ្វើជាសាធារណៈ ឱ្យមហាជនទូទៅចូលរួមស្តាប់បានទេ។ ប៉ុន្តែតុលាការ អាចធ្វើជា សាធារណៈបានដែរ ឬអាចអនុញ្ញាតឱ្យជនណាដែលតុលាការយល់ឃើញថា សមរម្យ ចូលរួមស្តាប់ក្នុងឋានៈជាអ្នកសង្កេតការណ៍បាន។

**៥.ភស្តុតាង**

នៅមុនពេលដែលតុលាការសម្រេចសេចក្តី តុលាការត្រូវ ស្វែងរកភស្តុតាងនានា ដើម្បីធ្វើជាមូលដ្ឋានសម្រាប់ការសម្រេច សេចក្តី។ អង្គហេតុដែលភាគីបានសារភាពនៅចំពោះមុខតុលាការ និងអង្គហេតុដែលតុលាការយល់ឃើញថា មានភាពជាក់ស្តែង តុលាការពុំចាំបាច់ទទួលស្គាល់អង្គហេតុនោះ ដោយផ្អែកលើភស្តុតាង។ ការស្វែងរកភស្តុតាងនានានោះ មានដូចជា ទី១ ភស្តុតាងពីការទាញហេតុផលផ្ទាល់មាត់ ទី២ ភស្តុតាងសាក្សីទី៣ តាងភាគី ទី៤ ភស្តុតាងកោសលវិច្ឆ័យ ទី៥ ភស្តុតាងឯកសារ។

ជាគោលការណ៍ទូទៅ ភស្តុតាងនៅក្នុងរឿងក្តីរដ្ឋប្បវេណីគឺ មានចាប់ពីលើស ៥១ ភាគរយឡើងទៅ តុលាការអាចសម្រេចសេច ក៏បាន ប៉ុន្តែសម្រាប់រឿងក្តីព្រហ្មទណ្ឌ តុលាការត្រូវមានភស្តុតាង យ៉ាងរឹងមាំ គឺចាប់ពីជាង ៩០ ភាគរយទៅទើបតុលាការជឿជាក់ និង អាចយកមកធ្វើជាមូលដ្ឋានសម្រាប់ការសម្រេចសេចក្តីបាន។

**៦.ការអះអាងអង្គហេតុដោយតំណាងអយ្យការ**

មាត្រា៤ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល បានចែងថា ចំពោះបណ្តឹងទាក់ទងនឹងការលែងលះគ្នា ឬបណ្តឹង ទាក់ទងនឹងឋានៈបុគ្គល ការចូលរួមរបស់តំណាងអយ្យការ អាចធ្វើ ការអះអាងអំពីអង្គហេតុដែលតំណាងអយ្យការបានដឹង ឬអាចស្នើ សុំឱ្យពិនិត្យភស្តុតាងបានប្រសិនបើយល់ឃើញថា ចាំបាច់ និងមាន ប្រយោជន៍ដល់ការពិចារណារបស់ចៅក្រម ក្នុងការសម្រេចសេចក្តី។

**៧.ការស្រាវជ្រាវដោយឆន្ទានុសិទ្ធិដោយតុលាការ**

មាត្រា១៥ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈ បុគ្គលបានចែងថា បណ្តឹងលែងលះគ្នា ឬបណ្តឹងទាក់ទងនឹងឋានៈ បុគ្គល តុលាការអាចយកអង្គហេតុដែលមិនបានអះអាងដោយភាគី មកធ្វើជាមូលដ្ឋាននៃសាលក្រមដោយឆន្ទានុសិទ្ធិបាន ទោះបីជា ភាគីមិនបានស្នើសុំឱ្យពិនិត្យពីអង្គហេតុនោះក៏ដោយ។ ក្នុងករណីនេះ តុលាការអាចសាកសួរមតិពីភាគីអំពីអង្គហេតុទាំងនោះបាន។

**៨.ការសម្រេចសេចក្តី**

ការស៊ើបអង្កេត ដែលត្រូវមានសវនាការនៅមុខតុលាការជា ច្រើន ក្រមរដ្ឋប្បវេណីមិនបានកំណត់ពេលវេលាច្បាស់លាស់ដើម្បី តុលាការសម្រេចសេចក្តីនោះទេ។ ប៉ុន្តែនៅក្នុងច្បាប់ស្តីពីអាពាហ៍ ពិពាហ៍និងគ្រួសារបានកំណត់ថា តុលាការត្រូវតែធ្វើការវិនិច្ឆ័យដល់ អង្គសេចក្តីក្នុងរយៈពេល ១៥ថ្ងៃ គិតពីថ្ងៃស៊ើបអង្កេតរួចមក។

ក្រោយពេលតុលាការបានបញ្ចប់ការស៊ើបអង្កេតរួចមក ត្រូវ ធ្វើការវិនិច្ឆ័យដល់អង្គសេចក្តី ដោយតុលាការត្រូវចេញសាលក្រម។ សាលក្រមគឺជាសេចក្តីសម្រេចសេចក្តីដែលតុលាការធ្វើលិខិត សាលក្រមដែលមានលក្ខណគ្រប់គ្រាន់ ទៅតាមទម្រង់ដែលច្បាប់ * បានកំណត់។ ផ្អែកលើការទាញហេតុផលដោយផ្ទាល់មាត់តាមរយៈសាលក្រមនេះ តុលាការកំណត់ថាតើចំណងអាពាហ៍ពិពាហ៍ត្រូវរំលាយ ឬបន្ត។

**៩.ករណីមិនអាចប្តឹង និង សាលក្រមកំបាំងមុខ**

**៩.១.ការហាមមិនអោយដាក់ពាក្យបណ្តឹងសាលក្រមស្ថាពរ**

ក្រោមពេលសាលក្រម ឬសាលដីការនៃបណ្តឹង ឬបណ្តឹងទាក់ទងនឹងឋានៈបុគ្គលចូលជាស្ថាពរហើយ ដើមចោទមិនអាចដាក់ពាក្យបណ្តឹងទាក់ទងនឹងការលែងលះគ្នា ឬបណ្តឹងទាក់ទងនឹងឋានៈបុគ្គលដដែល ដោយផ្អែកលើអង្គហេតុដែលខ្លួនអាចអះអាងបាន ដោយការបន្ថែម ឬការផ្លាស់ប្តូរនូវការទាមទារ ឬ មូលហេតុនៃការទាមទារក្នុងបណ្តឹងនោះបានឡើយ។

ចុងចម្លើយក៏មិនអាចដាក់ពាក្យបណ្តឹងទាក់ទងនឹងការលែង លះគ្នាឬបណ្តឹងទាក់ទងនឹងឋានៈបុគ្គលបានដែរ ក្រោយពេល សាលក្រម ឬសាលដីការចូលជាស្ថាពរ ដោយផ្អែកលើអង្គហេតុ ដែលខ្លួនអាចអះអាងបាន។ ប៉ុន្តែដើមចោទឬចុងចម្លើយនៅតែ អាចដាក់ពាក្យបណ្តឹងបាន ក្នុងករណីដែលសាលក្រម ឬសាលដីកា នោះបានលើបណ្តឹងចោល ដោយហេតុថា បណ្តឹងនោះមាន លក្ខណផ្ទុយនឹងច្បាប់។

**៩.២.ការបញ្ចប់បណ្តឹងដោយមរណភាពដើមចោទ**

ក្នុងករណីដែលដើមចោទបានទទួលមរណភាពនៃបណ្តឹង ទាក់ទងនឹងការលែងលះគ្នា ឬបណ្តឹងទាក់ទងនឹងឋានៈបុគ្គល នៅ ពេលធ្វើបណ្តឹងនោះ បណ្តឹងនោះត្រូវចប់ដោយស្វ័យប្រវត្ត។

**៩.៣.ការបញ្ចប់បណ្តឹងដោយមរណភាពចុងចោទ**

ក្នុងករណីដែលចុងចម្លើយនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ដែលមានគោលបំណងលែងលះគ្នា ឬកាត់កាល់បានទទួលមរណ ភាពនៅពេលដែលបណ្តឹងនេះកំពុងចាត់ការបណ្តឹងនោះត្រូវចប់ ដោយស្វ័យប្រវត្តផងដែរ។

**៩.៤សាលក្រមកំបាំងមុខ**.

ក្រមនីតិវិធីរដ្ឋប្បវេណី បានអនុញ្ញាតឱ្យតុលាការចេញ សាលក្រមកំបាំងមុខក្នុងករណីលែងលះគ្នា ដោយយោងទៅតាម កាលៈទេសៈដូចមានរៀបរាប់នៅក្នុងលក្ខខណ្ឌខាងក្រោម ៖

សាលក្រមកំបាំងមុខ គឺជាសាលក្រមដែលបានចេញឱ្យនៅ ពេលដែលចុងចម្លើយមិនបានបង្ហាញខ្លួននៅកាលបរិច្ឆេទលើកទី១ នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុទេ តុលាការត្រូវច្រានចោល ការទាមទាររបស់ដើមចោទនោះ ដោយសាលក្រមកំបាំងមុខ។ ដោយហេតុថា តុលាការយល់ថា ដើមចោទគ្មានឆន្ទៈក្នុងការធ្វើ ទៅតាមនីតិវិធីនៃបណ្តឹង។

ប្រសិនបើដើមចោទមិនបានបង្ហាញខ្លួននៅកាលបដិច្ឆេទ នៃការទាញហេតុផលដោយផ្ទាល់មាត់ទេ តុលាការត្រូវច្រានចោលការទាមទាររបស់ដើមចោទនោះដោយសាលក្រមកំបាំងមុខ។

**៩.៥.ករណីមិនអាចចេញសាលក្រមកំបាំងមុខ**

បើយោងតាមមាត្រា ២០២ នៃក្រមនីតិវិធីរដ្ឋប្បវេណី បានកំណត់នូវលក្ខខណ្ឌមួយចំនួន ដែលតុលាការមិនអាចចេញសាលក្រមកំបាំងមុខបានដូចជា៖

- ភាគីដែលមិនបង្ហាញខ្លួន មិនបានទទួលដីការកោះហៅដោយស្របច្បាប់
- ភាគីដែលមិនបានបង្ហាញខ្លួន មានមូលហេតុដែលអាចទទួលស្គាល់បានថា ពិតជាមិនអាចបង្ហាញខ្លួនបានមែនដោយសារគ្រោះមហន្តរាយធម្មជាតិ ឬកាលៈទេសៈផ្សេងទៀតដែលមិនអាចចៀសវាងបាន
- បណ្តឹងមិនស្របច្បាប់
- ខ្លឹមសារនៃសេចក្តីថ្លែងការណ៍ដែលដើមចោទបានធ្វើនៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់

**១០.ការបញ្ចប់នីតិវិធីដោយមិនសម្រេចសេចក្តី**

ក្រមនីតិវិធីរដ្ឋប្បវេណី បានកំណត់នូវលក្ខខណ្ឌមួយចំនួនដែលភាគីអាចបញ្ចប់សេចក្តី ដោយមិនធ្វើតាមការសម្រេចសេចក្តីនៅក្នុងករណីមួយចំនួនដូចខាងក្រោម៖

- ការដកពាក្យបណ្តឹងទាំងអស់ ឬមួយផ្នែក រហូតដល់សាលក្រមចូលជាស្ថាពរ។
- ក្នុងករណីដែលភាគីទាំងសងខាង មិនបានបង្ហាញខ្លួននៅកាលបរិច្ឆេទនៅនីតិវិធីសម្រាប់ការទាញហេតុផល ឬកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាលើមាត់ហើយមិនបានដាក់ពាក្យសុំឲ្យតុលាការកំណត់កាលបរិច្ឆេទថ្មីទៀតក្នុងអំឡុងពេល១ខែ នោះតុលាការបានចាត់ទុកថាភាគីបានដកពាក្យបណ្តឹង។
- ក្នុងករណីដែលភាគីទាំងសងខាង មិនបានបង្ហាញខ្លួននៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់២ដងជាប់គ្នា។

## ១១.ការប្តឹងទាស់នឹងសាលក្រមកំបាំងមុខ

ភាគីមួយ អាចដាក់ពាក្យប្តឹងទាស់នឹងសាលក្រមកំបាំងមុខដោយស្នើសុំឲ្យតុលាការដើមធ្វើការពិចារណារឿងសាជាថ្មី។ ហើយនេះហៅថា "បណ្តឹងទាស់" ។ ការប្តឹងនេះ មានការខុសគ្នាពី ប្តឹងឧទ្ធរណ៍ ដែលត្រូវពិភាក្សានៅក្នុងផ្នែកខាងមុខ។ ការប្តឹងទាស់នឹងសាលក្រមកំបាំងមុខត្រូវប្តឹងក្នុងរយៈពេល ១៤ថ្ងៃ (២សប្តាហ៍) គិតចាប់ពីថ្ងៃឲ្យដំណឹងពីសាលក្រមកំបាំងមុខទៅដល់គូក្តីទាំងពីរផ្ទាល់ ឬក្នុងរយៈពេល១៤ថ្ងៃ គិតចាប់ពីឲ្យដំណឹងពីសាលក្រមកំបាំងមុខដល់លំនៅរបស់គូក្តីទាំងពីរ។ក្នុងករណីដែលពាក្យបណ្តឹងទាស់ មិនស្របនឹងបញ្ញត្តិអំពីរបៀបប្តឹងទាស់តុលាការត្រូវកំណត់អំឡុងពេលសមរម្យ និងបង្គាប់ឲ្យកែតម្រូវចំណុចខ្វះខាតនៃពាក្យបណ្តឹងនោះ ក្នុងអំឡុងពេលនោះ។ ប្រសិនបើភាគីដែលប្តឹងទាស់មិនបានកែតម្រូវចំណុចខ្វះខាតទេ តុលាការត្រូវលើកពាក្យបណ្តឹងទាស់នោះចោលដោយដីការសម្រេច។ចំពោះដីការសម្រេចនេះ ភាគីអាចប្តឹងជំទាស់បាន។

## ១២.សាលក្រមថ្មី និង សាលក្រមកំបាំងមុខលើកទី២

### ១២.១.សាលក្រមថ្មី

ប្រសិនបើសាលក្រម ដែលត្រូវចេញដោយផ្អែកលើការជំនុំជម្រះជាថ្មី បន្ទាប់ពីចាប់ផ្តើមអនុវត្តនីតិវិធីឡើងវិញ មានលទ្ធផលដូចសាលក្រមកំបាំងមុខ នោះតុលាការត្រូវចេញសាលក្រមថ្មីដែលប្រកាសតម្កល់សាលក្រមកំបាំងមុខនោះទុកជាបានការ។ប្រសិនបើសាលក្រមដែលត្រូវចេញដោយផ្អែកលើការជំនុំជម្រះជាថ្មីបន្ទាប់ពីចាប់ផ្តើមអនុវត្តនីតិវិធីឡើងវិញ គ្មានលទ្ធផលដូចសាលក្រមកំបាំងមុខទេ ហើយតុលាការត្រូវតែលុបចោលសាលក្រមកំបាំងមុខនោះនៅក្នុងសាលក្រមថ្មី។

### ១២.២.សាលក្រមកំបាំងមុខលើកទី២

ប្រសិនបើភាគីដែលបានប្តឹងទាស់ មិនបានបង្ហាញខ្លួននៅកាលបរិច្ឆេទដំបូង ក្រោយពេលចាប់ផ្តើមអនុវត្តនីតិវិធីឡើងវិញទេតុលាការត្រូវច្រានចោលបណ្តឹងទាស់ ដោយសាលក្រមកំបាំងមុខម្តងទៀត ហើយសាលក្រមកំបាំងមុខលើកទី២នេះ ភាគីមិនអាចប្តឹងទាស់បានទៀតទេ។

សាលក្រមចំពោះមុខ គឺជាសាលក្រមនៅក្នុងរឿងក្តីមួយដែលសហព័ន្ធទាំងពីរនាក់បានចូលរួមក្នុងនីតិវិធី។

សាលក្រមកំបាំងមុខ សំដៅដល់សាលក្រមដែលតុលាការសម្រេចដោយគ្មានវត្តមានដើមចោទ ឬភាគីចុងចម្លើយ ឬក៏អ្នកតំណាងស្របច្បាប់របស់ដើមចោទ ឬចុងចម្លើយ។

**ផ្នែកទី៤.អានុភាពនៃការលែងលះ**

**១.ការរំលាយចំណងអាពាហ៍ពិពាហ៍**

នៅពេលដែលសាលក្រមលែងលះចូលជា ស្ថាពរវាមានអានុភាពរំលាយចំណងអាពាហ៍ពិពាហ៍ រវាងគូភាគី ដែលគិតចាប់ពីថ្ងៃដែលប្រកាសសាលក្រមស្ថាពរ ។ ដូច្នេះ ចំណងគតិយុត្តិអំពីបុគ្គលនៃអ្នកទាំងពីរត្រូវបានកាត់ផ្តាច់លែងមានសិទ្ធិ និងករណីយកិច្ចរវាង គ្នានឹងគ្នា ដូចកាលនៅមានចំណងអាពាហ៍ពិពាហ៍នឹងគ្នាទៀតហើយ ។ ការរំលាយចំណង អាពាហ៍ពិពាហ៍ ជាមូលហេតុធ្វើឲ្យចំណងគតិយុត្តិ ដែលមានការទាក់ទងដទៃទៀតប្រែប្រួល និង ផ្លាស់ប្តូរដែរ មានដូចជាការបែងចែកទ្រព្យសម្បត្តិជាដើម ។

**២.ការបែងចែកទ្រព្យ**

នៅពេលដែលសហព័ទ្ធជាប្តីប្រពន្ធលែងលះគ្នា ធ្វើឲ្យមានការពិបាកនៅក្នុងការបែងចែក ទ្រព្យ ។ សហព័ទ្ធម្ខាងតែងតែទាមទារចង់បានចំណែកច្រើនរៀងៗខ្លួន ដែលវាជាបញ្ហាដែលពិបាក ដោះស្រាយបំផុតចំពោះការបែងចែក ។ ដោយយោងទៅតាមក្រមរដ្ឋប្បវេណីថ្មី ឆ្នាំ២០០៧ បាន កំណត់ការបែងចែកទ្រព្យជាពីរគឺ ការបែងចែកទ្រព្យសម្បត្តិតាមការព្រមព្រៀង និង ការបែងចែក ទ្រព្យសម្បត្តិដោយគ្មានការព្រមព្រៀង ។

**២.១ការបែងចែកទ្រព្យសម្បត្តិតាមការព្រមព្រៀង.**

នៅពេលដែលគូភាគីបានធ្វើការលែងលះ ការបែងចែកទ្រព្យសម្បត្តិក៏កើតមានឡើងដោយ ផ្អែកទៅតាមការពិភាក្សារបស់សហព័ទ្ធទាំងសងខាងផងដែរ ។ ហើយការបែងចែកទ្រព្យ សម្បត្តិតាមការព្រមព្រៀងនេះ មានលក្ខណៈងាយស្រួលសម្រាប់ចៅក្រមក្នុងការសម្រេចសេចក្តី ។ ដោយយោងទៅតាមបញ្ញត្តិច្បាប់នៃក្រមរដ្ឋប្បវេណីថ្មី ឆ្នាំ២០០៧ បានអនុញ្ញាតឲ្យសហព័ទ្ធទាំងពីរ អាចព្រមព្រៀងគ្នាចុះកិច្ចសន្យានៅលើទ្រព្យសម្បត្តិនៅមុន ឬ ក្រោយអាពាហ៍ពិពាហ៍បានដោយមិន ឲ្យផ្ទុយនឹងអាហាកាតព្វកិច្ច និងភាគបម្រុងឡើយ ហើយការបែងចែកទ្រព្យសម្បត្តិគឺ ត្រូវតែផ្អែកទៅ កិច្ចព្រមព្រៀងរបស់ភាគីដែលបានចែងក្នុងកិច្ចសន្យានោះផងដែរ ។ ការធ្វើបែបនេះវាអាចជានីតិវិធី មួយ ដែលជាភាពងាយស្រួលក្នុងការបែងចែកទ្រព្យសម្បត្តិនៅពេលដែលសហព័ទ្ធធ្វើ

ការលែង លះគ្នា ដោយសារតែភាគីបានព្រមព្រៀងគ្នាចុះកិច្ចសន្យាជាមុនរួចហើយ ហើយពួកគាត់អាចធ្វើការបែងចែកទ្រព្យសម្បត្តិដោយផ្អែកទៅតាមកិច្ចសន្យាដែលសហព័ទ្ធបានចុះជាមួយគ្នានោះ។ 92 ក្នុងករណីដែលសហព័ទ្ធទាំងពីរ បានពិភាក្សាព្រមព្រៀងគ្នាតាមឆន្ទៈរបស់អ្នកទាំងពីរហើយ តុលាការនឹងធ្វើការបែងចែកទ្រព្យសម្បត្តិទាំងនោះ ដោយយុត្តិធម៌ដែលផ្អែកទៅតាមការពិភាក្សារបស់ សហព័ទ្ធទាំងសងខាង ។ ចំពោះការព្រមព្រៀងតាមការពិភាក្សាគ្នានេះ តុលាការត្រូវតែមានការ ប្រុងប្រយ័ត្នខ្ពស់ ដោយពិនិត្យមើលឲ្យច្បាស់ថា ការព្រមព្រៀងនោះកើតឡើងដោយការបង្ខិតបង្ខំ ឬ ការគំរាមកំហែងដែលសកម្មភាពបែបនេះមិនមែនជាការព្រមព្រៀងដែលផុសចេញពីឆន្ទៈរបស់ សហព័ទ្ធនោះទេ ។ តែប្រសិនបើការព្រមព្រៀងនោះពិតជាឯកភាពតាមការពិភាក្សាមែននោះ តុលាការត្រូវបែងចែកដោយយុត្តិធម៌ដោយផ្អែកទៅតាមការពិភាក្សានោះ ទោះបីជាទ្រព្យសម្បត្តិនោះ ជាទ្រព្យរួម ឬ ទ្រព្យដោយឡែកក៏ដោយ ។

### ២.២.ការបែងចែកទ្រព្យសម្បត្តិដោយគ្មានការព្រមព្រៀង

ក្នុងករណីដែលសហព័ទ្ធទាំងសងខាងមិនអាចធ្វើការពិភាក្សាគ្នាបានទេ ត្រូវបែងចែកទ្រព្យ សម្បត្តិ ដោយផ្អែកតាមតាមចំណុចនីមួយៗដូចកំណត់ខាងក្រោមនេះ ៖

- សហព័ទ្ធនីមួយៗត្រូវទទួលបាននូវទ្រព្យសម្បត្តិដោយឡែកដែលពួកគាត់មានមុនពេល អាពាហ៍ពិពាហ៍ ដូចដែលបានកំណត់ក្នុងមាត្រា៩៧២ ហើយ ទ្រព្ (ទ្រព្យសម្បត្តិដោយឡែក)យសម្បត្តិដោយឡែកនោះ រួមមាន ៖
    - ❖ ទ្រព្យសម្បត្តិដែលសហព័ទ្ធមាន នៅមុនពេលអាពាហ៍ពិពាហ៍
    - ❖ ទ្រព្យសម្បត្តិដែលសហព័ទ្ធទទួលបាន ដោយប្រទានកម្ម សន្តតិកម្ម អច្ច័យទាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍
    - ❖ ទ្រព្យសម្បត្តិជាតម្លៃតប ដែលទទួលបានពីការចាត់ចែងទ្រព្យសម្បត្តិដោយឡែក របស់សហព័ទ្ធនៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ ។
- បន្ថែមពីលើទ្រព្យសម្បត្តិដោយឡែកសហព័ទ្ធនីមួយៗ មានសិទ្ធិទទួលពាក់កណ្តាលនៃទ្រព្យ សម្បត្តិរួម។ ប៉ុន្តែបើមានករណីពិសេស និងមានការទាមទាររបស់ប្តីប្រពន្ធណាម្ខាង តុលាការក៏អាចចែងចែកទ្រព្យសម្បត្តិរួមដោយពិចារណាទៅលើស្ថានភាពផ្សេងៗដូចជា ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗ ទំហំនៃការបរិច្ចាគរបស់ ភាគីនីមួយៗចំពោះលទ្ធកម្ម នៃទ្រព្យសម្បត្តិ ការថែរក្សា ឬ ការបង្កើតទ្រព្យអំឡុងពេលអាពាហ៍ពិពាហ៍ កម្រិតជីវភាព រស់នៅនៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ អាយុ ស្ថានភាពផ្លូវកាយ និងផ្លូវចិត្ត វិជ្ជាជីវៈ ប្រាក់ចំណូល លទ្ធភាពធ្វើការងាររបស់ភាគីនីមួយៗ និង ផលប្រយោជន៍

របស់កូន ជាអាទិ៍ ។ ជាងនេះទៅទៀត ការងារគេហកិច្ច ក៏ត្រូវបានចាត់ទុកថាមានតម្លៃស្មើនឹងការងារដែលធ្វើក្រៅផ្ទះ។

ចំពោះបញ្ហាបំណុលដែលសហព័ទ្ធទាំងសងខាង ជំពាក់នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ សហព័ទ្ធអាចធ្វើការពិភាក្សាដោយផ្អែកតាមការព្រមព្រៀងគ្នា ក្នុងការសងបំណុលបាន។ ម៉្យាងវិញ ទៀតតុលាការនៅតែមានសិទ្ធិសម្រេចសេចក្ដី នៅពេលដែលសហព័ទ្ធមិនអាចពិភាក្សាគ្នាបានឬ បំណុលនោះអាចបែងចែកជាការសងពាក់កណ្ដាលម្នាក់ក៏បានដែរ ជាងនេះថែមទៀត តុលាការកំ ត្រូវសម្រេចនូវអំណាចមេបាផងដែរ ក្នុងការបីបាច់ថែរក្សាកូនដែលជាអនីតិជន នឹងធ្វើការគ្រប់គ្រង ទ្រព្យសម្បត្តិរបស់កូននោះ ។

### ៣.ការបែងចែកកូន

#### ៣.១.ការបែងចែកកូនតាមការព្រមព្រៀងរបស់ភាគី

កូនជាកត្តាសំខាន់សម្រាប់សហព័ទ្ធ ដែលលែងលះគ្នា បើមានការព្រមព្រៀងគ្នាក្នុងការ ប្រគល់ និង ទទួលយកកូនរបស់សហព័ទ្ធទាំងពីរ នោះតុលាការត្រូវសម្រេចសេចក្ដីទៅតាមការព្រម ព្រៀងរបស់សហព័ទ្ធ ។ រាល់ការសម្រេចអំពីអំណាចមេបានៅពេលដែលសហព័ទ្ធលែងលះគ្នា ត្រូវកំណត់យកឪពុក ឬ ម្ដាយជាអ្នកមានអំណាចមេបាតាមការពិភាក្សារបស់ឪពុកម្ដាយ ។ ផ្ទុយទៅ វិញ បើឪពុកម្ដាយបានលែងលះគ្នាមុនកំណើតរបស់កូន នោះម្ដាយជាអ្នកមានអំណាចមេបាចំពោះ កូនដែលបានកើតនោះ ។ ហើយឪពុកម្ដាយអាចធ្វើការពិភាក្សាគ្នា ប្រសិនបើគាត់ធ្វើការលែងលះ ក្រោយកំណើតរបស់កូន ដោយកំណត់យកឪពុកជាអ្នកមានអំណាចមេបា ។

#### ៣.២.ការបែងចែកកូនតាមការមិនព្រមព្រៀងរបស់ភាគី

ប្រសិនបើករណីខាងលើពុំអាចសម្រេច ឬ ពុំអាចពិភាក្សាបានទេ_ច្បាប់បានធ្វើការផ្ដល់ អំណាចឆន្ទានុសិទ្ធិទៅតុលាការ ដើម្បីកំណត់អ្នកមានអំណាចមេបាក្នុងការអប់រំថែរក្សា ដោយគិត ដល់ផលប្រយោជន៍របស់កូន មានន័យថា បើតុលាការស៊ើបអង្កេតឃើញថាសហព័ទ្ធម្ខាងមាន ជីវភាពធូធារ ដែលមានលទ្ធភាពក្នុងការចិញ្ចឹម បីបាច់ថែរក្សាកូនបានល្អដោយមិនឲ្យខូចប្រយោជន៍ របស់កូននោះតុលាការមានឆន្ទានុសិទ្ធិក្នុងការប្រគល់កូនឲ្យសហព័ទ្ធនោះជាអ្នកថែរក្សា ។ ជាគោលការណ៍ កូនដែលនៅបៅដោះនៅពេលដែលឪពុកម្ដាយលែងលះគ្នាត្រូវបានទៅនៅខាង ម្ដាយដែលជាអ្នកថែរក្សា ពីព្រោះម្ដាយជាអ្នកមានទឹកដោះដើម្បីចិញ្ចឹមកូន និងមានភាពស្ទាត់ ជំនាញខាងថែរក្សាទារកជាងបុរសដែលជាឪពុក ។ ចំពោះកូនដែលលែងបៅដោះក៏មិនអាចកំណត់ បានថាបានទៅខាងឪពុកជាអ្នកគ្រប់គ្រងដែរ វាជាឆន្ទានុសិទ្ធិរបស់តុលាការជាអ្នកដែលធ្វើការ សម្រេចលើបញ្ហានេះ។ ចំណែកកូនដែលទើបនឹងធំដឹងក្ដីនៅពេលឪពុកម្ដាយលែងលះគ្នា តុលាការ អាចសាកសួរទៅកូននោះថាតើចង់ទៅរស់នៅជាមួយឪពុក ឬ ម្ដាយ ប្រសិនបើកូននោះនិយាយថា ចង់រស់នៅជាមួយឪពុក ឬ ម្ដាយ នោះតុលាការមានសិទ្ធិសម្រេចតាមការសម្រេចរបស់កូន ។ ញាតិ នៅក្នុងថ្នាក់ទី៤ របស់កូនសហព័ទ្ធអាចធ្វើការ

ទាមទារតុលាការឲ្យមានការផ្លាស់ប្តូរអំណាច មេបាបាន ប្រសិនបើតុលាការទទួលស្គាល់ថាជាការចាំបាច់ដើម្បី ផលប្រយោជន៍កូន ។

ទោះបីជាចំណងអាពាហ៍ពិពាហ៍របស់សហព័ទ្ធទាំងពីរបានកាត់ផ្តាច់មែន ក៏ប៉ុន្តែចំណង ឪពុកម្តាយ ជាមួយកូន មិនអាចកាត់ផ្តាច់បានឡើយ ។ សហព័ទ្ធដែលមើលថែរក្សាកូន ត្រូវតែផ្តល់ លទ្ធភាពឲ្យទៅភាគីម្ខាង ទៀតបានមកសួរសុខទុក្ខកូនបានគ្រប់ពេលវេលា ដោយមិនធ្វើឲ្យមានភាព ស្មុគស្មាញ ឬ រារាំងដល់សហព័ទ្ធ ម្ខាងទៀតមិនឲ្យប្រាស្រ័យទាក់ទងជាមួយកូនឡើយ និង មាន ករណីកិច្ចទទួលបន្ទុកលើសោហ៊ុយដែលចាំបាច់ ដើម្បីគ្រប់គ្រងថែរក្សាកូន១ ។ ប្រសិនបើការចូល ជួបកូនពុំបានសម្រេច តុលាការត្រូវកំណត់អំពីរបៀបចូលជួប ប្រាស្រ័យទាក់ទងនិងសោហ៊ុយ ចាំបាច់ដែលត្រូវទទួលបន្ទុក ដើម្បីថែរក្សាកូនតាមការទាមទាររបស់ឪពុក ឬ ម្តាយ។ យោងតាម សេចក្តីសម្រេចរបស់តុលាការ កូនដែលមានអាយុក្រោម៦ឆ្នាំ ច្រើនប្រគល់ឲ្យទៅរស់នៅជាមួយ ម្តាយ។ចំពោះកូនដែលមានអាយុលើសពី៦ឆ្នាំ បើជាកូនស្រីត្រូវតែទៅរស់នៅជាមួយម្តាយ ហើយកូនប្រុស ត្រូវ ទៅរស់នៅជាមួយឪពុក ។ ប៉ុន្តែជាទូទៅតុលាការតែងតែធ្វើសេចក្តីសម្រេច ឲ្យទៅម្តាយជាអ្នកជាគ្រប់គ្រងថែរក្សា ចិញ្ចឹមកូនដើម្បីចៀសវាងកុំឲ្យកូនរស់នៅបែកគ្នា ។

### ៤.អាហារកិច្ចចំពោះកូន

#### ៤.១.អាហារកិច្ចដោយការព្រមព្រៀងរបស់ភាគី

ប្តីប្រពន្ធដែលបានលែងលះគ្នាហើយ ត្រូវបីបាច់ថែរក្សាជួយផ្គត់ផ្គង់ផ្តល់សោហ៊ុយអប់រំ ការ ហូបចុក និង ការរៀនសូត្រដល់កូនទៅតាមលទ្ធភាពរបស់ខ្លួន ។ ពោលគឺ តុលាការត្រូវសម្រេច សេចក្តីតាមការព្រមព្រៀង របស់សហព័ទ្ធទាំងពីរ ។ ផ្ទុយទៅវិញ បើមិនមានការព្រមព្រៀងពីភាគី ម្ខាងដែលទទួលយកកូនទៅចិញ្ចឹមថាមិន ព្រមទទួលយកអាហារកិច្ចចិញ្ចឹមពីសហព័ទ្ធម្ខាងទៀតទេ នោះតុលាការមិនសម្រេចសេចក្តីតាមការព្រមព្រៀង នោះទេ គឺសម្រេចឲ្យសហព័ទ្ធដែលមិនទទួល យកកូនទៅចិញ្ចឹមឲ្យបង់អាហារកិច្ចចិញ្ចឹមកូនធ្វើយ៉ាងនេះគឺដើម្បី កុំឲ្យសហព័ទ្ធដែលមិនបាន ចិញ្ចឹមកូនមានការឃ្លាតឆ្ងាយពីកូនខ្លាំងពេក ។

#### ៤.២.អាហារកិច្ចដោយការមិនព្រមព្រៀងរបស់ភាគី

ក្នុងករណីមិនមានការព្រមព្រៀងរបស់សហព័ទ្ធទាំងពីរចំពោះ អាហារកិច្ចរបស់កូនទេនោះ តុលាការត្រូវ ពិនិត្យអំពីជីវភាព និងប្រាក់ចំណូលរបស់សហព័ទ្ធដែលត្រូវផ្តល់ ហើយសម្រេចសេក្តី ទៅតាមលទ្ធភាពរបស់គេ ដោយមិនត្រូវឲ្យលើសពីសម្ថភាពរបស់គេនោះទេ ហើយអាហារកិច្ចនេះ ត្រូវសម្រេចរហូតដល់កូនមាននីតិភាព ។ ការមិនព្រមបង់អាហារកិច្ចដល់កូន គឺជាអំពើដែលចាត់ ទុកថាជាបទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោសតាម ច្បាប់ជាធរមាន បើកាលណាមានភស្តុតាង បញ្ជាក់ថាសហព័ទ្ធដែលត្រូវផ្តល់អាហារកិច្ចនោះមានភាពមិនស្មោះ ត្រង់ ។ ប្រសិនបើ សហព័ទ្ធជា ឪពុក ឬ ម្តាយដែលអនុវត្តអំណាចមេបា បានបំពានសិទ្ធិអំណាចក្នុងនាមជាអ្នក

មានអំណាចមេបា ឬ ធ្វើឲ្យធ្វេសប្រហែសក្នុងការបំពេញករណីកិច្ចក្នុងនាមជាអ្នកមានអំណាចមេបា ដោយឲ្យកូនធ្លាក់ ក្នុងភាពយ៉ាប់យឺនពាលាអាវ៉ាសែ ដោយពុំបានគិតគូពីផលប្រយោជន៍របស់កូន មិនបានអប់រំទូន្មានកូន និងពុំបានផ្គត់ផ្គង់ឲ្យកូនបានទៅរៀនដែលអាចនឹងឃើញថាកូនរបស់ខ្លួននឹងគ្មានអនាគត បើបន្តរស់នៅជាមួយអ្នកមានអំណាចមេបានោះតទៅទៀត នោះសហព័ទ្ធដែលមិនមានអំណាចមេបា ក្នុងការថែរក្សាកូនមានសិទ្ធិប្ដឹងមកតុលាការដើម្បីដកយកកូននោះមកចិញ្ចឹមវិញហើយតុលាការ អាចប្រកាសព្យួរ ឬ ដកហូតអំណាចមេបាតាមការស្នើសុំនោះបាន ឬ តាមការទាមទាររបស់ញាតិ ទាំង៤ថ្នាក់របស់កូនមេឃុំចៅសង្កាត់ នាយកមជ្ឈមណ្ឌល-សាធារណៈសម្រាប់សុខមាលភាព ឬ តំណាងអយ្យការបាន។

ប្រសិនបើការកាត់ក្ដីរបស់ចៅក្រមនៅក្នុងសាលក្រមនេះ មានសហព័ទ្ធណាមួយមិនសុខចិត្ត នោះសហព័ទ្ធដែលមិនសុខចិត្តនោះ មានសិទ្ធិប្ដឹងទៅសាលាឧទ្ធរណ៍ក្នុងកំឡុងរយៈពេលកំណត់២ ខែចំពោះសាលក្រមចំពោះមុខ ។ ចំពោះសាលក្រមកំបាំងមុខវិញ គឺប្ដឹងទាស់រយៈពេល១៥ថ្ងៃ និង ប្ដឹងឧទ្ធរណ៍រយៈពេល ២ខែ គិតត្រឹមពីថ្ងៃផុតកំណត់ប្ដឹងទាស់ ។ ក្នុងរយៈពេលនេះ បើពុំមានសហ ព័ទ្ធណាមួយចូលមកប្ដឹងក្នុងរយៈពេលនេះទេ សាលក្រមចូលជាស្ថាពរ ហើយសហព័ទ្ធទាំងពីរ ត្រូវអនុវត្តតាមសាលក្រមនេះជាកំណត់ ។

អាហារកិច្ចដែលសហព័ទ្ធនីមួយៗត្រូវផ្ដល់ឲ្យកូនត្រូវឲ្យជាទឹកប្រាក់ ឬ អាចជារបស់អ្វីមួយ សំរាប់ខែនីមួយៗ ។

## ៥.អាហារកិច្ចចំពោះសហព័ទ្ធ

### ៥.១.អាហារកិច្ចដោយការព្រមព្រៀងរបស់ភាគី

ជាទូទៅការបញ្ចប់ចំណងអាពាហ៍ពិពាហ៍ ករណីកិច្ចដែលសហព័ទ្ធមានចំពោះគ្នានឹងគ្នាក្នុង ឋានៈជាប្ដី-ប្រពន្ធក៏បញ្ចប់ដែរ។ ប៉ុន្តែចំពោះករណីអាហារកិច្ចដែលប្ដីប្រពន្ធត្រូវបំពេញចំពោះគ្នាក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ អាចបន្តទៅទៀតបានបន្ទាប់ពីការលែងលះគ្នា ។ ហេតុនេះហើយបានជា អតីតស្វាមី ឬ អតីតភរិយាអាចមានករណីកិច្ចបន្តទៅមុខទៀតបានបន្ទាប់ពីការលែងលះគ្នាបានបញ្ចប់ ដើម្បីចេញប្រាក់ជួយគាំទ្រអតីតប្រពន្ធ ឬ ប្ដីរបស់ខ្លួន ។ ប្រសិនបើក្រោយការលែងលះគ្នាបានចប់ សព្វគ្រប់ហើយ សហព័ទ្ធណាម្ខាងមានស្ថានភាពខ្វះខាតខាងផ្នែកជីវភាព នោះសហព័ទ្ធនោះអាចស្នើ សុំដល់តុលាការសុំឲ្យសហព័ទ្ធម្ខាងទៀត ទោះជាកំហុសក្ដី ឬ គ្មានកំហុសក្ដី និងមានជីវភាពប្រសើរ ជាងខ្លួនឲ្យជួយឧបត្ថម្ភអាហារកិច្ចដល់ខ្លួនទៅតាមលទ្ធភាព ប៉ុន្តែបើសហព័ទ្ធដែលខ្វះខាតនោះមានប្ដី ឬ ប្រពន្ធថ្មីទៀតនោះនឹងមិនមានសិទ្ធិដើម្បីទទួលអាហារកិច្ចនេះទៀតទេ ។

**៥.២.អាហារកិច្ចដោយការមិនព្រមព្រៀងរបស់ភាគី**

ជាគោលការណ៍ការផ្តល់អាហារកិច្ចដល់សហព័ទ្ធខ្វះខាតក្តី តុលាការអាចសម្រេចកែ ប្រែបានដោយអាចបន្ថយ ឬ បន្ថែមចំនួននៃការផ្តល់ ប្រសិនបើមានសំណូមពរពីសហព័ទ្ធម្ខាង ។ ការសម្រេចកែប្រែនេះ គឺយោងទៅតាមលទ្ធភាពរបស់សហព័ទ្ធដែលជាអ្នកផ្គត់ផ្គង់អាហារកិច្ច មាន ន័យថាមុនធ្វើការសម្រេចចិត្ត តុលាការត្រូវស៊ើបអង្កេតឲ្យបានច្បាស់លាស់ពីចំណូលប្រចាំខែរបស់ សហព័ទ្ធម្ខាងនោះ ជាពិសេសគឺទៅតាមការសម្រេចចិត្តរបស់ពួកគេផ្ទាល់ ។

ការខ្វះខាតរបស់សហព័ទ្ធរួមមាន : សមត្ថភាពរកប្រាក់បាននៃសហព័ទ្ធដែលចង់ឲ្យ សហព័ទ្ធម្ខាងទៀតផ្តល់អាហារកិច្ចដល់ខ្លួន អាយុ សុខភាព និងកំរិតជីវភាពរបស់សហព័ទ្ធស្នើសុំ ការផ្តល់អាហារកិច្ច ។

កំណត់សម្គាល់ចុងក្រោយ ការមិនបង់អាហារកិច្ចដល់សហព័ទ្ធចាត់ទុកថាជាបទល្មើសព្រហ្ម ទណ្ឌដែលត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន បើរកឃើញភស្តុតាងបញ្ជាក់ថាជនដែលត្រូវផ្តល់ អាហារកិច្ចនោះ មានភាពមិនស្មោះត្រង់ចំពោះអ្នកទទួលអាហារកិច្ច ។ ប្រសិនបើសហព័ទ្ធដែល ទទួលខុសត្រូវផ្គត់ផ្គង់អាហារកិច្ចមិនបានគោរពតាមសេចក្តីសម្រេចស្ថានភាពរបស់តុលាការ ដោយមិនព្រមបង់រយៈពេល ២ (ពីរ) ខែយ៉ាងតិចនូវអាហារកិច្ចដល់សហព័ទ្ធ ឬ អតីតសហព័ទ្ធ របស់ខ្លួន ដល់កូនជាអនីតិជនត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីរ ១ខែ ដល់ ១ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន)រៀល ដល់ ២.០០០.០០០ (ពីរលាន)រៀល ។

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីពួកយើងទាំងពីរដែលជាសិស្សសារណាដែល បានធ្វើការសិក្សាស្រាវជ្រាវនៃប្រធានបទអាពាហ៍ពិពាហ៍ និងការលែងលះមួយនេះឡើងពួកយើងសុំសរុបសេចក្តីនៃប្រធានទាំងមូលនេះថា ជាការពិតណាស់អាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាឱឡារិកធ្វើឡើងដោយគោលការណ៍ស្ម័គ្រចិត្ត និងមានចំណងតាមផ្លូវច្បាប់ សម្រាប់បុរសនិងនារីដែលជាសហព័ន្ធ។ការរស់នៅក្នុងជីវិតរបស់មនុស្សម្នាតែងតែប្រាថ្នាចង់រៀបអាពាហ៍ពិពាហ៍មួយដែលសមប្រកបដោយសុភមង្គលនៅក្នុងគ្រួសារដូច្នេះហើយទើបច្បាប់បានបញ្ញត្តិនូវច្បាប់អាពាហ៍ពិពាហ៍ឡើង ក្នុងគោលបំណងដើម្បីឲសហព័ន្ធទាំងពីរ ទទួលបានការយល់ដឹងជាច្រើនអំពីលក្ខណៈលក្ខខណ្ឌដើម្បីទទួលបានអាពាហ៍ពិពាហ៍មួយដែលស្របច្បាប់ មិនតែប៉ុណ្ណោះច្បាប់ក៏បានកំណត់នូវលក្ខខណ្ឌដើម្បីឲគូភាគីដែលបានរៀបអាពាហ៍ពិពាហ៍ត្រូវបញ្ជាក់សំបុត្រអាពាហ៍ពិពាហ៍ផងដែរ ដើម្បីរឹតចំណងអាពាហ៍ពិពាហ៍ឲកាន់តែគង់វង្សស្ថិតស្ថេរ។

ប៉ុន្តែយ៉ាងណាមិញការរស់នៅជាសហព័ន្ធទាំងនោះតែងមានភាពរកាំរកោះ ឬ វិវាទក្នុងគ្រួសារ វិវាទខ្លះគូភាគីទាំងពីរអាចដោះស្រាយបញ្ហាដោយសន្តិវិធីបានហើយ បញ្ហាខ្លះពិតជាមិនអាចរកវិធីដោះស្រាយក្រៅពីបញ្ចប់ទនាក់ទំនងគូសហព័ន្ធនឹងគ្នា ដោយការរំលាយចំណងអាពាហ៍ពិពាហ៍គឺវិធីនៃការលែងលះគ្នាតាមផ្លូវតុលាការ ហើយយើងក៏មើលឃើញថាវិធីសាស្ត្រដ៏ល្អក្នុងការបញ្ចប់ទំនាកទំនងអាពាហ៍ពិពាហ៍ គឺការដោះស្រាយតាមប្រព័ន្ធតុលាការ ដោយអនុលោមទៅតាមច្បាប់ដែលបានកំណត់ នៅក្នុងច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារ។ការរំលាយចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ ដែលប្តីប្រពន្ធបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រូវតែធ្វើឡើងតាមផ្លូវតុលាការដែល ភាគីទាំងពីរមិនអាចបង្កើតកិច្ចព្រមព្រៀងលែងលះក្រៅប្រព័ន្ធតុលាការ ឬ គ្រាន់តែដាក់លិខិតជូនដំណឹងទៅសាលាឃុំ សង្កាត់បានទេ។

សរុបសេចក្តីមក បុគ្គលគ្រប់រូបមុននឹងសម្រេចចិត្តចាប់ដៃគ្នាបង្កើតនូវចំណងអាពាហ៍ពិពាហ៍ ដើម្បីបង្កើតជាក្រុមគ្រួសារមួយនៅក្នុងសង្គម ត្រូវតែធ្វើការត្រិះរិះពិចារណាឲ្យបានម៉ត់ចត់ គ្រប់ជ្រុង ជ្រោយថាខ្លួនអាចមានសមត្ថភាពគ្រប់គ្រាន់ក្នុងការដើរតួនាទីជាស្វាមី ជាភរិយា ជាឪពុក ជាម្តាយ ដ៏ល្អបានហើយឬនៅ ។ ម្យ៉ាងវិញទៀត ដើម្បីជៀសវាងនូវការបែកបាក់ក្រុមគ្រួសាររបស់សហព័ទ្ធ ដែលការបែកបាក់នោះធ្វើឲ្យបាត់បង់នូវផលប្រយោជន៍របស់សហព័ទ្ធជាពិសេសនោះ ចំណងអាពាហ៍ពិពាហ៍របស់អ្នកទាំងពីរនិងពុំមានសេចក្តីសុខឡើយ។

# អនុសាសន៍

ឆ្លងកាត់តាមរយៈការសិក្សាស្រាវជ្រាវនៃប្រធានបទខាងលើនេះរួចមក ពួកយើងទាំងពីរដែលជានិស្សិតស្រាវជ្រាវប្រធានបទនេះក៏បានយល់ឃើញទាក់ទងទៅនឹងសង្គមខ្មែរបច្ចុប្បន្នថា គ្រប់ស្រទាប់វណ្ណៈមិនថា ទាំងគ្រួសារអ្នកដែលមានជីវភាពល្អ ឬ មធ្យម ឬ មិនថារស់នៅតាមជនបទ ឬ ទីក្រុងក៏ដោយ បុគ្គលគ្រប់រូបនោះត្រូវតែអាចឆ្លងកាត់ជីវិតរៀបអាពាហ៍ពិពាហ៍ យ៉ាងណាមិញមិនថាបុគ្គលដែលជាសាមីខ្លួន ឬ ជាឪពុកម្ដាយទេ សុទ្ធតែចង់អោយការរៀបអាពាហ៍ពិពាហ៍នោះប្រកបដោយសុភមង្គល និងសេចក្ដីសុខជាទីបំផុត ប៉ុន្តែវាជារឿងមួយដែលពួកយើងមិនអាចមើលឃើញថាជីវិតក្រោយរៀបអាពាហ៍ពិពាហ៍នឹងជួបរឿងអ្វីខ្លះ វាអាចជាសុភមង្គល ឬ អាចនឹងជួបជីវិតបែបរកាំរកោះ រហូតដល់ឈានដល់ការលែងលះផងដែរ ហេតុដូច្នេះហើយទើបច្បាប់សម្រេចបញ្ញាតិនូវច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារនេះឡើង ក៏ជាប្រយោជន៍រួមដល់បុគ្គលគ្រប់ស្រទាប់វណ្ណៈអោយមានការយល់ដឹងបន្ថែមពីសមត្ថភាពនៃការរៀបអាពាហ៍ពិពាហ៍ អំពីការរៀបពិធីអាពាហ៍ពិពាហ៍ និងនីតិវិធីនៃការចុះសំបុត្រអាពាហ៍ពិពាហ៍ផងដែរ។សម្រាប់គូដែរអស់និស្ស័យជាប្ដីប្រពន្ធហើយនោះ ក៏ច្បាប់បានផ្ដល់នូវនីតិវិធីនៃការលែងលះដោយប្រព័ន្ធតុលាការ ផងដែរ។ដោយយល់ឃើញពីសារៈប្រយោជន៍ជាច្រើននៃច្បាប់អាពាហ៍ពិពាហ៍នេះហើយ ក្រុមយើងខ្ញុំក៏សុំបញ្ចេញនូវគំនិតបន្តិចបន្តួច ដើម្បីជាប្រយោជន៍បន្ថែមៈ

- ផ្សព្វផ្សាយនូវចំណេះដឹងបន្ថែមទៅដល់ប្រជាជនដែលរស់តាមជនបទ ដែលដាច់ស្រយាល ដោយការចុះទៅផ្ទាល់ ឬបង្កើតជាកម្មវិធី ឬសិក្ខាសាលាជាដើម។
- ផ្សព្វផ្សាយជាចំណេះដឹង សម្រាប់បុគ្គលដែលមានវ័យស្ទើង ហើយឆាប់រៀបការ ជាពិសេសប្រជាជនដែលរស់នៅតាមជនបទ អោយយល់ដឹងបន្ថែមអំពីបុគ្គលិកលក្ខណៈ ឬជាសមត្ថភាពមុននឹងសម្រេចចិត្តរៀបការ ដែលជាវិធីមួយបង្ការការលែងលះអោយកើតមានផងដែរ ។
- បង្កើតជាមាតិកាអប់រំទៅលើប្រព័ន្ធផ្សព្វផ្សាយជាសាធារណៈអោយបានច្រើន ដូចជាផ្សព្វផ្សាយតាមរយៈ Internet ឬ វិទ្យុ ទូរទស្សន៍ជាដើម។

## ឯកសារយោង

1. ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧
2. ក្រមនីតិវិធីរដ្ឋប្បវេណី
3. សៀវភៅ នីតិគ្រួសារ និង អាពាហ៍ពិពាហ៍
4. ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ

# ឧបសម្ព័ន្ធ

# ច្បាប់

# ស្តីពី

# អាពាហ៍ពិពាហ៍

# និង

# គ្រួសារ

# ១៩៨៩

# ច្បាប់

# ស្តីពី

# អាពាហ៍ពិពាហ៍ និងគ្រួសារ

**រដ្ឋកម្ពុជា**

ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល

ក្រុមប្រឹក្សារដ្ឋ

លេខ : ៥៦ ក្រ.

# ក្រឹត្យ

## ក្រុមប្រឹក្សារដ្ឋ

## នៃ

## រដ្ឋកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃរដ្ឋកម្ពុជា

- បានឃើញច្បាប់ស្តីពីការរៀបចំរដ្ឋសភា និងក្រុមប្រឹក្សារដ្ឋ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជាដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៤ក្រ. ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២

**សំរេច**

ប្រកាសអោយប្រើច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារដែលរដ្ឋសភានៃរដ្ឋកម្ពុជា បានអនុម័តនៅថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ១៩៨៩ នាសម័យប្រជុំសាមញ្ញលើកទី ១៧ នីតិកាលទី ១ ។

ធ្វើនៅភ្នំពេញ, ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៨៩

ជ.ក្រុមប្រឹក្សារដ្ឋ

ប្រធាន

ហត្ថលេខា និង ត្រា : **ហេង សំរិន**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋសភា

# ច្បាប់

## ស្តីពី

## អាពាហ៍ពិពាហ៍ និង គ្រួសារ

## ជំពូកទី ១

## បទបញ្ញត្តិទូទៅ

**មាត្រា ១.** ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ដោយផ្អែកលើមាត្រា ៧ និងមាត្រា ៨ នៃរដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជា មានគោលដៅ ដាក់បទបញ្ជា និង ការរៀបអាពាហ៍ពិពាហ៍ និងគ្រួសារ ធានាសមភាពរវាងសហព័ទ្ធ ក្នុងអាពាហ៍ពិពាហ៍ និង ក្នុងជីវភាពគ្រួសារ ពង្រឹងការទទួលខុសត្រូវរបស់ឪពុកម្តាយ ក្នុងការចិញ្ចឹមថែរក្សាកូន និង ជំរុញការបណ្តុះបណ្តាលសីលធម៌ និងការអប់រំ ដើម្បីឱ្យទៅជាពលរដ្ឋល្អ មានមនសិការស្នេហាជាតិ ស្រឡាញ់ការងារ មានសម្បជញ្ញៈទទួលខុសត្រូវចំពោះសង្គម ។

**មាត្រា ២.** ហាមឃាត់ដាច់ខាត នូវអាពាហ៍ពិពាហ៍ដែលគូស្រករនៅក្មេងពេក អាពាហ៍ពិពាហ៍ដោយបង្ខិតបង្ខំ អំពើដែលមានឧបសគ្គដល់សេរីភាពនៃអាពាហ៍ពិពាហ៍ ។

## ជំពូកទី ២

## អំពីអាពាហ៍ពិពាហ៍

### ផ្នែកទី ១

### អំពីលក្ខខណ្ឌដែលត្រូវមានដើម្បីរៀបអាពាហ៍ពិពាហ៍

**មាត្រា ៣.** អាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាដ៏ឱឡារិកមួយ ធ្វើឡើងដោយបុរសម្នាក់ និង ស្ត្រីម្នាក់ដែលប្តេជ្ញាថា ខ្លួននិងរួម សមគ្គសង្វាសជាមួយគ្នាតាមបញ្ញត្តិច្បាប់ ហើយដែលមិនអាចរំលាយទៅវិញបានតាមទំនើងចិត្ត របស់ខ្លួន ។

អាពាហ៍ពិពាហ៍នឹងមានអានុភាពពេញលក្ខណៈច្បាប់បាន លុះត្រាតែអាពាហ៍ពិពាហ៍នោះធ្វើឡើងស្របតាមក្បួនខ្នាតដែលមានចែងក្នុងច្បាប់នេះ ។

**មាត្រា ៤.** បុរស និង នារី ដែលមានអាយុពេញលក្ខណៈច្បាប់ មានសិទ្ធិពេញលេញក្នុងការសំរេចអាពាហ៍ពិពាហ៍ ។ ភាគីម្ខាងមិនអាចបង្ខំឆន្ទៈរបស់ភាគីម្ខាងទៀតបានឡើយ ។

គ្មាននរណាមួយអាចបង្ខំបុគ្គលម្នាក់ឱ្យរៀប ឬ រារាំងមិនឱ្យរៀបអាពាហ៍ពិពាហ៍បានឡើយ បើ អាពាហ៍ពិពាហ៍នោះរៀបតាមក្បួនខ្នាតដែលមានចែងក្នុងច្បាប់នេះ ។

**មាត្រា ៥**.- អាចរៀបអាពាហ៍ពិពាហ៍បាន បុរសចាប់ពីអាយុ ២០ឆ្នាំឡើង នារីចាប់ពីអាយុ ១៨ ឆ្នាំឡើង ។

ក្នុងករណីពិសេស បុរសដែលមានអាយុមិនទាន់ដល់ ២០ ឆ្នាំ និង នារីដែលមានអាយុមិនទាន់ដល់ ១៨ ឆ្នាំ អាចរៀបអាពាហ៍ពិពាហ៍ស្របច្បាប់បាន ប្រសិនបើនារីមានផ្ទៃពោះ ហើយមានការអនុញ្ញាតពីឪពុកម្តាយ ឬ អ្នកអាណាព្យាបាល ។

**មាត្រា ៦**.- មិនអាចរៀបអាពាហ៍ពិពាហ៍បាន :

-បុគ្គលមានភេទដូចគ្នា
- បុគ្គលគ្មានពលានុភាពនៃលិង្គ
- បុគ្គលមានជម្ងឺឃ្លង់ របេង មហារីក កាមរោគ ដែលមិនទាន់ព្យាបាលបានជាដាច់
- ជនវិកលចរិត ជនមិនដឹងខុសត្រូវ
- បុគ្គលមានចំណងអាពាហ៍ពិពាហ៍ពីមុនមិនទាន់រលាយ ។

**មាត្រា ៧**.- អាពាហ៍ពិពាហ៍ត្រូវហាមឃាត់ រវាងបុគ្គលដែលជាប់ចំណងញាតិលោហិត ឬ ញាតិពន្ធក្នុងខ្សែផ្ទាល់ គ្រប់ថ្នាក់ទោះចំណងនោះមានខាន់ស្លាក្តី ឥតមានខាន់ស្លាក្តី ឬ សាច់ចិញ្ចឹមក្តី ។

**មាត្រា ៨**.- អាពាហ៍ពិពាហ៍ត្រូវហាមឃាត់ រវាងសាខាញាតិ ទោះសាខាញាតិនោះមានខាន់ស្លាក្តី ឥតខាន់ស្លាក្តី សាច់ចិញ្ចឹមក្តី រួមម្តាយក្តី រួមឪពុកក្តី ជាញាតិលោហិតក្តី ឬ ជាញាតិពន្ធក្តី រហូតដល់ថ្នាក់ទី ៣ រាប់ទាំងថ្នាក់ទី ៣ នេះផង ។

ក្នុងករណីពិសេស ប្រសិនបើសហព័ន្ធណាមួយស្លាប់ សហព័ន្ធដែលនៅរស់អាចរៀប អាពាហ៍ពិពាហ៍ ជាមួយ សាខាញាតិពន្ធ ថ្នាក់ទី ២ ឬ ថ្នាក់ទី ៣ បាន ។

**មាត្រា ៩**.- ក្រោយពីអាពាហ៍ពិពាហ៍រលាយដោយមូលហេតុ ប្តីស្លាប់ មោឃភាពនៃអាពាហ៍ពិពាហ៍ ឬ លែងលះគ្នា នារីអាចរៀបអាពាហ៍ពិពាហ៍ថ្មីមួយទៀតបាន ប៉ុន្តែត្រូវស្ថិតនៅក្នុងវិចរភាព " ភាពមេម៉ាយ " ចំនួន ៣០០ថ្ងៃ គិតពីថ្ងៃដែលប្តីស្លាប់ ឬ ពីថ្ងៃប្រកាសសាលក្រមដែលសំរេចពីមោឃភាព នៃអាពាហ៍ពិពាហ៍ ឬ ពីថ្ងៃប្រកាសសាលក្រមស្ថាពរនៃការលែងលះ ។ ក្នុងករណីដែលតុលាការប្រជាជនបានចេញដីកាសំរេច ឱ្យប្តីប្រពន្ធនៅបែកគ្នា នោះសាលក្រមនៃការលែងលះត្រូវគិតវិចរភាពតាំងពីថ្ងៃដែលចេញដីកានេះ ។

ប៉ុន្តែ បើនារីរៀបអាពាហ៍ពិពាហ៍មុនផុត រយៈពេល ៣០០ ថ្ងៃ ប្តីដែលរៀបអាពាហ៍ពិពាហ៍ថ្មីនេះ ត្រូវចាត់ទុកជា ឪពុករបស់កូនដែលកើតក្នុងអាពាហ៍ពិពាហ៍ថ្មីនេះ លើកលែងតែមានការជំទាស់ពីប្តី មុន ដោយមានភស្តុតាងច្បាស់លាស់ ។

**មាត្រា ១០.** ក្នុងករណីដែលសហព័ទ្ធណាមួយបាត់ខ្លួនកន្លងហួសពីមួយឆ្នាំ គិតពីថ្ងៃដែលបាត់ខ្លួននោះមក ដោយគ្មានដំណឹងអ្វីសោះ ហើយក៏គ្មាននរណាដឹងថា ជននោះស្លាប់ ឬ រស់ សហព័ទ្ធម្នាក់ទៀត អាចនឹងរៀបអាពាហ៍ពិពាហ៍ទៀតបាន បើផុតរយៈពេល ១៥ ថ្ងៃ គិតពីថ្ងៃប្រកាសសាលក្រម ដែលបញ្ជាក់ថា ជននោះបានបាត់ខ្លួនពិតមែន ។

ជនណាក៏ដោយ មិនអាចប្តឹងសុំបដិសេធអាពាហ៍ពិពាហ៍ថ្មីនេះបានឡើយ ទោះបីសហព័ទ្ធ ដែល បាត់ខ្លួននោះត្រឡប់មកវិញក៏ដោយ ។

**មាត្រា ១១.** មុនពេលរៀបអាពាហ៍ពិពាហ៍ អនាគតប្តី ប្រពន្ធ ត្រូវប្តឹងដល់គណៈកម្មាធិការប្រជាជន ឃុំ ឬ សង្កាត់ខាងលំនៅរបស់នារី ដោយមានឪពុក ឬម្តាយ ឬអ្នកអាណាព្យាបាលចូលរួមផងក៏ដោយ ។

**មាត្រា ១២.** ប្រធាន ឬ សមាជិកនៃគណៈកម្មាធិការប្រជាជន ឃុំ ឬ សង្កាត់ ក្នុងឋានៈជាមន្ត្រីអត្រានុកូល-ដ្ឋាន ត្រូវប្រកាសផ្សាយជាសាធារណៈ នូវអាពាហ៍ពិពាហ៍នោះដោយបិទប័ណ្ណប្រកាសនៅលំនៅរបស់នារី និង នៅទីស្នាក់ការឃុំ ឬ សង្កាត់របស់ខ្លួន ។

ប័ណ្ណប្រកាសពីរទៀត ត្រូវផ្ញើទៅជូនមន្ត្រីអត្រានុកូលដ្ឋាន ឃុំ ឬ សង្កាត់ខាងបុរស ដើម្បីយកទៅបិទនៅលំនៅរបស់បុរស និង នៅទីស្នាក់ការឃុំ ឬ សង្កាត់របស់ខ្លួន ។

ប័ណ្ណប្រកាសត្រូវចុះ :

១- ត្រកូល ឈ្មោះ អាយុ មុខរបរ និង លំនៅនៃអនាគតប្តី និង ប្រពន្ធ ។

២- ប្រកូល ឈ្មោះ អាយុ មុខរបរ និង លំនៅរបស់ឪពុកម្តាយនៃអនាគតប្តីប្រពន្ធ " បើឪពុក ឬ ម្តាយស្លាប់ ត្រូវដាក់ថា ស្លាប់ផង " ។

៣- រយៈពេលប្តឹងជំទាស់ ។

**មាត្រា ១៣.** ប័ណ្ណប្រកាសត្រូវបិទផ្សាយក្នុងរយៈពេល ១០ ថ្ងៃ ដើម្បីឱ្យជនដែលមានផលប្រយោជន៍ក្នុងរឿងនេះដឹងឮ ហើយអាចប្តឹងជំទាស់នឹងអាពាហ៍ពិពាហ៍នោះបាន ប្រសិនបើមានការមិនយល់ស្របនឹងអាពាហ៍ពិពាហ៍នោះ ។ ផុតរយៈពេល ១០ ថ្ងៃនេះ ពិធីអាពាហ៍ពិពាហ៍អាចធ្វើទៅបាន បើគ្មានការប្តឹងជំទាស់ ។

**មាត្រា ១៤.** អាពាហ៍ពិពាហ៍ និង ចាត់ទុកជាត្រឹមត្រូវតាមលក្ខណៈច្បាប់បាន លុះត្រាតែបុរស និងនារីដែលស្ម័គ្រចិត្តយកគ្នាជាប្តីជាប្រពន្ធ ចុះកិច្ចសន្យាអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានខាងលំនៅរបស់នារី ។

កិច្ចសន្យានេះត្រូវចុះក្នុងបញ្ជីអាពាហ៍ពិពាហ៍ ហើយត្រូវចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋាន ប្តីប្រពន្ធ និង សាក្សីគ្រប់អាយុការពីរនាក់ ។

## ផ្នែកទី ២

## អំពីបណ្តឹងអាពាហ៍ពិពាហ៍ឱ្យរៀបអាពាហ៍ពិពាហ៍

**មាត្រា ១៥**- ក្នុងរយៈពេល ១០ថ្ងៃ គិតពីថ្ងៃដែលបិទផ្សាយជាសាធារណៈ ញាតិក្តី ជនដែលមានប្រយោជន៍ក្នុងរឿងនេះក្តី អាចនឹងប្តឹងជំទាស់មិនឱ្យរៀបអាពាហ៍ពិពាហ៍បាន ។

**មាត្រា ១៦**- បណ្តឹងទាស់នេះ នឹងយកជាការបាន លុះណាតែអ្នកប្តឹងជំទាស់ចុះហត្ថលេខា លើពាក្យរបស់ខ្លួនដោយផ្ទាល់ដៃខ្លួនឯង ។

បណ្តឹងនេះ ត្រូវចង្អុលពីមូលហេតុនៃការប្តឹងទាស់ ។ មូលហេតុដែលអាចយកមក ប្តឹងជំទាស់បាន នោះ គឺអសមត្ថភាពរបស់បុរស ឬ នារី ឬ មានប្រកាសណាមួយ ដែលច្បាប់ហាមឃាត់ក្នុងមាត្រា ៥ វាក្យខ័ណ្ឌទី ១ មាត្រា ៦ មាត្រា ៧ មាត្រា ៨ នៃច្បាប់នេះ ។

**មាត្រា ១៧**- បណ្តឹងទាស់នោះ ត្រូវអ្នកប្តឹងជំទាស់ ឬ តំណាងរបស់ខ្លួនយកទៅជូនគណៈកម្មាធិការប្រជាជនឃុំ ឬ សង្កាត់ខាងលំនៅអនាគតប្រពន្ធ ។ គណៈកម្មាធិការនេះត្រូវសំរេចក្នុងរយៈពេល ៣ ថ្ងៃ គិតពីថ្ងៃទទួលបណ្តឹងទាស់ ។

បើអ្នកប្តឹងជំទាស់ ឬ អនាគតប្តីប្រពន្ធ មិនសុខចិត្តនឹងសេចក្តីសំរេចនេះ គណៈកម្មាធិការប្រជាជនឃុំ ឬ សង្កាត់ ត្រូវបញ្ជូនសំណុំរឿងទៅតុលាការប្រជាជនក្នុងរយៈពេល ៥ ថ្ងៃយ៉ាងយូរ គិតពីថ្ងៃទទួលបណ្តឹងទាស់ ដើម្បីសំរេច ។

**មាត្រា ១៨**- តុលាការប្រជាជន ត្រូវសំរេចសេចក្តីពីបណ្តឹងទាស់ក្នុងរយៈពេល ៧ ថ្ងៃយ៉ាងយូរ គិតពីថ្ងៃបានទទួលសំណុំរឿង ។

សាលក្រមរបស់តុលាការប្រជាជន មិនអាចប្តឹងតវ៉ាបានឡើយ ទោះបីសាលក្រមនោះជាសាលក្រមកំបាំងមុខក៏ ដោយ ។

**មាត្រា១៩**-បើតុលាការប្រជាជនបដិសេធបណ្តឹងទាស់ចោលអនាគតប្តីប្រពន្ធអាចរៀបអាពាហ៍ពិពាហ៍ បាន។

បើតុលាការប្រជាជនចាត់ទុកបណ្តឹងទាស់នោះជាត្រឹមត្រូវមន្ត្រីអត្រានុកូលដ្ឋានត្រូវបញ្ឈប់មិនឱ្យរៀបអាពាហ៍ពិពាហ៍ ។

**មាត្រា ២០**- នៅពេលដែលដឹងថា បុរស ឬ នារីជាអសមត្ថជន ឬ មានប្រការណាមួយដែលច្បាប់ហាមឃាត់ដូចមានចែងក្នុងមាត្រា ១៦ មន្ត្រីអត្រានុកូលដ្ឋានមានសិទ្ធិជំទាស់មិនឱ្យរៀបអាពាហ៍ពិពាហ៍ដោយធ្វើរបាយការណ៍ពីបណ្តឹងទាស់នេះ ជូនទៅតុលាការ ប្រជាជនក្នុងរយៈពេល ២ ថ្ងៃយ៉ាងយូរ ដើម្បីសំរេច ។

តុលាការប្រជាជន ត្រូវសំរេចសេចក្តីតាមបទបញ្ញត្តិដែលមានចែងក្នុងមាត្រា ១៨ និង ១០ ខាងលើ ។

## ផ្នែកទី ៣

## អំពីមោឃភាពនៃអាពាហ៍ពិពាហ៍

មាត្រា ២១ៈ អាពាហ៍ពិពាហ៍ត្រូវទុកជាមោឃៈ ប្រសិនបើអាពាហ៍ពិពាហ៍នោះ ចុះបញ្ជីនៅពេលដែលសហព័ន្ធណាម្នាក់ឆ្កួត ឬ មិនដឹងខុសត្រូវ ។ តែបើសហព័ន្ធនោះបានជាស្រួលឡើងវិញហើយ ហេតុដែលនាំឱ្យទុកជាមោឃៈនោះត្រូវរលាយទៅវិញដែរ ។

មាត្រា ២២ៈ អាពាហ៍ពិពាហ៍រវាងបុរសអាយុតិចជាង ២០ ឆ្នាំ ឬ នារីអាយុតិចជាង ១៨ ឆ្នាំ ត្រូវទុកជាមោឃៈ ។

អាពាហ៍ពិពាហ៍ដែលទុកជាមោឃៈនោះនឹងលែងមោឃៈទៅវិញ កាលបើប្តី ឬ ប្រពន្ធ នោះចំរើនវ័យ ដល់អាយុតាម បញ្ញត្តិច្បាប់ ឬ ក្នុងករណីដែលមានចែងក្នុងមាត្រា ៥ វាក្យខ័ណ្ឌទី ២ ។

មាត្រា ២៣ៈ អាពាហ៍ពិពាហ៍ត្រូវទុកជាមោឃៈ កាលបើសហព័ន្ធណាម្នាក់ប្តឹងថា ខ្លួនត្រូវគេចាប់បង្ខំឱ្យរៀបអាពាហ៍ពិពាហ៍

ការប្តឹងសុំមោឃភាពនៃអាពាហ៍ពិពាហ៍ត្រូវផុតអាជ្ញាយុកាល ប្រសិនបើការប្តឹងនោះ មិនធ្វើក្នុង រយៈ ៦ ខែ គិតពីថ្ងៃដែលគេលែងបង្ខំមក ។

មាត្រា ២៤ៈ អាពាហ៍ពិពាហ៍ត្រូវទុកជាមោឃៈ បើចំណងអាពាហ៍ពិពាហ៍មុនរបស់សហព័ន្ធណាម្នាក់មិនទាន់រលាយ ។

ការប្តឹងសុំមោឃភាពនៃអាពាហ៍ពិពាហ៍ក្រោយ មិនអាចធ្វើបានឡើយ បើក្រោយពីថ្ងៃចុះអាពាហ៍ពិពាហ៍ក្រោយ នេះមក អាពាហ៍ពិពាហ៍មុនត្រូវបានរំលាយ ។

មាត្រា ២៥ៈ អាពាហ៍ពិពាហ៍រវាងញាតិលោហិត ឬ ញាតិព័ន្ធក្នុងថ្នាក់ដែលច្បាប់ហាមឃាត់ ត្រូវទុក ជាមោឃៈ លើកលែងតែករណីដែលមានចែងក្នុងមាត្រា ៨ វាក្យខ័ណ្ឌទី ២ ។

ការប្តឹងសុំមោឃភាព នៃអាពាហ៍ពិពាហ៍ខាងលើនេះ មិនអាចផុតអាជ្ញាយុកាលឡើយ ។

មាត្រា ២៦ៈ មានតែសហព័ន្ធ រដ្ឋអាជ្ញា និង ជនដែលមានប្រយោជន៍ស្របច្បាប់ក្នុងការប្តឹងសុំមោឃភាពនៃអាពាហ៍ពិពាហ៍ទេ ទើបអាចដាក់ពាក្យប្តឹងសុំមោឃភាពនៃអាពាហ៍ពិពាហ៍ទៅតុលាការប្រជាជនបាន ។

បើជនដែលបានដាក់ពាក្យប្តឹងនោះស្លាប់ សិទ្ធិវន្តអាចប្តឹងជំនួសបាន ។

មាត្រា ២៧ៈ កូនកើតអំពីអាពាហ៍ពិពាហ៍ដែលតុលាការបានប្រកាសជាមោឃៈ ត្រូវទុកជាកូនមានខាន់ស្លា ទោះបីហេតុដែលនាំឱ្យមានមោឃភាពនោះ យ៉ាងណាក៏ដោយ ។

សិទ្ធិ និង កាតព្វកិច្ចរបស់ឪពុក ម្តាយ និង កូនត្រូវមានដូចគ្នាក្នុងករណីនៃឪពុក ម្តាយលែងលះគ្នា ។

ការចែកទ្រព្យសម្បត្តិរវាង ប្តី ប្រពន្ធ នៃអាពាហ៍ពិពាហ៍ដែលតុលាការប្រកាសជាមោឃៈ ក៏ត្រូវធ្វើដូចក្នុងករណីលែងលះគ្នាដែរ ។

មាត្រា ២៨- តុលាការប្រជាជន ត្រូវចាត់ចែងឱ្យចម្លងសេចក្តីវិនិច្ឆ័យ នៃសាលាក្រមស្ថាពរដែលប្រកាសមោឃភាពអាពាហ៍ពិពាហ៍ ចុះនៅរឹមទំព័រ នៃសំបុត្រអាពាហ៍ពិពាហ៍ដែលត្រូវទុកជាមោឃៈ ។

## ផ្នែកទី ៤

## សិទ្ធិ និង ករណីយកិច្ចរបស់សហព័ន្ធ

មាត្រា ២៩- ក្នុងគ្រួសារ ប្តី ប្រពន្ធ ត្រូវមានភាពស្មើគ្នាលើគ្រប់ទស្សនៈ ។

មាត្រា ៣០- ប្តី ប្រពន្ធ មានករណីយកិច្ចស្រឡាញ់គ្នាទៅវិញទៅមក គោរពគ្នាទៅវិញទៅមក ថែរក្សាគ្នា និង ជួយគ្នាទៅវិញទៅមក ដើម្បីឈានទៅកាន់វឌ្ឍនភាពព្រមទាំងកសាងគ្រួសារមួយមានសាមគ្គីភាព និង ប្រកបដោយសុភមង្គល ។

មាត្រា ៣១- ប្រពន្ធ ប្តី មានសិទ្ធិជ្រើសដោយសេរីនូវវិជ្ជាជីវៈរបស់ខ្លួន មានសិទ្ធិចូលរួមប្រាស្រ័យដោយសេរីក្នុងសកម្មភាពនយោបាយ វប្បធម៌ និង សង្គម ។

មាត្រា ៣២- ប្រពន្ធនិងប្តី មានសិទ្ធិស្មើគ្នាក្នុងការប្រើប្រាស់ ការអាស្រ័យផល ការចាត់ចែងទ្រព្យសម្បត្តិរួម ។

សហព័ន្ធម្នាក់ៗ មានសិទ្ធិពេញលេញក្នុងការប្រើប្រាស់ អាស្រ័យផល និង ចាត់ចែងទ្រព្យផ្ទាល់របស់ខ្លួន ។

មាត្រា ៣៣- ទ្រព្យសម្បត្តិរួម គឺជាអ្វីៗ ទាំងអស់ដែលសហព័ន្ធទាំងពីរ រកបានជាមួយគ្នា ឬ សហព័ន្ធណាម្នាក់រកបានក្នុងរយៈពេលមានចំណងអាពាហ៍ពិពាហ៍ ។

មាត្រា ៣៤- ត្រូវចាត់ទុកជាទ្រព្យសម្បត្តិផ្ទាល់របស់សហព័ន្ធ :

១- ទ្រព្យសម្បត្តិដែលសហព័ន្ធមានមុនរៀបអាពាហ៍ពិពាហ៍ ។

២- ទ្រព្យសម្បត្តិដែលសហព័ន្ធបានទទួលជាអំណោយជាមតិក ឬ ជាបច្ច័យទានក្នុងរយៈពេលមានចំណងអាពាហ៍ពិពាហ៍ ។

មាត្រា ៣៥- ត្រូវធ្លាក់លើបន្ទុកទ្រព្យសម្បត្តិរួម :

១- ការផ្គត់ផ្គង់គ្រួសារ និង ចំណាយដើម្បីអប់រំ និង បណ្តុះបណ្តាលកូន ។

២- បំណុល និង កាតព្វកិច្ចទាំងឡាយ ដែលសហព័ន្ធទាំងពីរបានព្រមព្រៀងគ្នាសំរេច ក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ ឬ ដែលសហព័ន្ធណាម្នាក់សំរេចក្នុងរយៈពេលមានចំណង អាពាហ៍ពិពាហ៍ដោយមានការយល់ព្រមពីសហព័ន្ធម្នាក់ទៀត ។

៣- ការថែទាំ និង ការគ្រប់គ្រងទ្រព្យសម្បត្តិរួម ។

មាត្រា ៣៦- សហព័ន្ធម្នាក់ៗ អាចប្រើប្រាស់សម្ភារៈដែលជាទ្រព្យសម្បត្តិរួម តាមការតម្រូវនៃសម្ភារៈនោះ ។

សហព័ន្ធទាំងពីរនាក់ត្រូវគ្រប់គ្រងទ្រព្យសម្បត្តិរួមជាមួយគ្នា។ សហព័ន្ធម្នាក់អាចទាមទារឱ្យសហព័ន្ធម្នាក់ទៀតយល់ព្រមលើវិធានការចាំបាច់ដើម្បីថែទាំទ្រព្យសម្បត្តិរួម ឬ រក្សាទុកតម្លៃរបស់ទ្រព្យសម្បត្តិនោះ ។

មាត្រា ៣៧- ទ្រព្យសម្បត្តិរួមអាចលក់ដូរឬធ្វើអំណោយបាន លុះត្រាតែមានការព្រមព្រៀងពីសហព័ន្ធទាំងពីរ ។

## ជំពូកទី ៣

## អំពីការលែងលះគ្នា

### ផ្នែកទី ១

### អំពីមូលហេតុនៃការលែងលះគ្នា

**មាត្រា ៣៨.** ការលែងលះគ្នា គឺការផ្ដាច់ចំណងអាពាហ៍ពិពាហ៍របស់ប្ដីប្រពន្ធ ដែលបានរៀបការពេញច្បាប់ក្នុងពេលរស់នៅទាំងពីរនាក់ ។

**មាត្រា ៣៩.** ប្ដី ឬ ប្រពន្ធ អាចប្ដឹងសុំលែងលះគ្នាបាន កាលបើមានមូលហេតុគ្រប់គ្រាន់ បញ្ជាក់ថា ខ្លួនពុំអាចរួមរស់ជាមួយគ្នាតទៅទៀតបាន ។

មូលហេតុជាអាទិមានដូចខាងក្រោមនេះ :

១- ការចុះចោលលំនៅសង្វាស ដោយឥតមូលហេតុត្រឹមត្រូវ ហើយឥតមានផ្គត់ផ្គង់ស្បៀងអាហារ និង ទំនុកបំរុងកូនសោះ ។

២- វាយដំឃោរឃៅ ធ្វើទុក្ខបុកម្នេញប្រមាថមើលងាយធ្ងន់ធ្ងរ ចំពោះសហព័ន្ធ ឬ ចំពោះបុព្ពញាតិរបស់សហព័ន្ធនេះ ។

៣- មានចរិយាផ្ទុយពីសីលធម៌ ឬ ប្រព្រឹត្តអនាចារ ។

៤- អពលានុភាពនៃលិង្គ ។

៥- បែកគ្នាអស់រយៈពេលជាង ១ ឆ្នាំ

**មាត្រា ៤០.** ប្ដីប្រពន្ធ អាចលែងលះគ្នាដោយស្ម័គ្រចិត្តបាន ។

### ផ្នែកទី ២

### អំពីនីតិវិធី នៃ ការលែងលះគ្នា

**មាត្រា ៤១.** ការសំរេចអំពីការលែងលះគ្នា ជាសមត្ថកិច្ចរបស់តុលាការប្រជាជនខេត្ត-ក្រុង ខាងលំនៅរបស់ចុងចម្លើយ ។

**មាត្រា ៤២.** បណ្ដឹងលែងលះគ្នា ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ចុះមូលហេតុនាំឱ្យលែងលះគ្នា ។

បណ្ដឹងនោះត្រូវដើមចោទយកទៅជូនតុលាការប្រជាជនខេត្ត-ក្រុងផ្ទាល់ក៏បាន ឬជូនគណៈកម្មាធិការប្រជាជន ឃុំ ឬសង្កាត់ខាងលំនៅរបស់ចុងចម្លើយ ដោយខ្លួនឯងផ្ទាល់ក៏បាន ។

ក្នុងករណីខាងក្រោមនេះ គណៈកម្មាធិការប្រជាជនឃុំ ឬសង្កាត់ត្រូវធ្វើការផ្សះផ្សាក្នុងរយៈ១៥ថ្ងៃ ក្រោយពីបានទទួលពាក្យបណ្ដឹង ។ បើផ្សះផ្សាពុំបានសម្រេច ត្រូវបញ្ជូនសំណុំរឿងជាបន្ទាន់ទៅតុលាការប្រជាជនខេត្ត-ក្រុង ។

**មាត្រា ៤៣**~ តុលាការប្រជាជនខេត្ត-ក្រុង ត្រូវអញ្ជើញអ្នកប្តឹងឱ្យចូលមក ហើយសំរួលយ៉ាណោតាមដែលខ្លួនយល់ឃើញ ដើម្បីបញ្ចូលចិត្តអ្នកនោះឱ្យឈប់ប្តឹង លើកលែងតែតុលាការប្រជាជនខេត្ត-ក្រុងយល់ឃើញថា ពាក្យសុំលែងលះគ្នានេះមានអាចហេតុធ្ងន់ធ្ងរណាស់ ។

**មាត្រា ៤៤**~ ក្រោយពីពេលបានទទួលបណ្តឹងសុំលែងលះ បើយល់ឃើញថា ការចាំបាច់ តុលាការប្រជាជនខេត្ត-ក្រុងអាចចាត់វិធានការបណ្តោះអាសន្នបាន ដូចជាការបំបែកលំនៅប្តី ប្រពន្ធ ការឱ្យថែរក្សា ថែរក្សាទ្រព្យសម្បត្តិ ការផ្តល់អាហារកិច្ច ។ ក្នុងករណីនេះ មេធាវីនៃគូភាគីអាចចូលរួមស្តាប់បាន ។

**មាត្រា ៤៥**~ ប្រសិនបើដើមចោទនៅតែទទូចសុំលែង តុលាការប្រជាជនខេត្ត-ក្រុង ត្រូវអញ្ជើញប្តី ប្រពន្ធអោយមកកាន់តុលាការជាប្រញាប់ ដើម្បីធ្វើការផ្សះផ្សា ។ ក្នុងករណីនេះ មេធាវីមិនត្រូវចូលរួមស្តាប់ទេ ។

**មាត្រា ៤៦**~ប្រសិនបើផ្សះផ្សាចំពោះមុខដើមចោទ និងចុងចម្លើយហើយនៅតែពុំបានសំរេច តុលាការប្រជាជនខេត្ត-ក្រុង អាចធ្វើការផ្សះផ្សាជាលើកទី ២ បាន ។

**មាត្រា ៤៧**~ ប្រសិនបើនៅពេលផ្សះផ្សាលើកទី ១ ដើមចោទ ឬ ចុងចម្លើយ ដែលបានទទួលដីកាអញ្ជើញដោយត្រឹមត្រូវ ហើយមិនមកបង្ហាញខ្លួនតាមការអញ្ជើញនោះ តុលាការប្រជាជនខេត្ត-ក្រុងត្រូវអញ្ជើញភាគីទាំងពីរនោះជាលើកទី ២ ដើម្បីធ្វើការផ្សះផ្សា ។

**មាត្រា ៤៨**~ ប្រសិនបើដើមចោទ ដែលបានទទួលដីកាអញ្ជើញដោយត្រឹមត្រូវ ហើយមិនបានមកកាន់តុលាការ ប្រជាជនខេត្ត-ក្រុង ទាំងលើកទី ១ ទាំងលើកទី ២ ដោយគ្មានមូលហេតុនោះត្រូវចាត់ទុកថា សុខចិត្តឈប់ប្តឹង ។

**មាត្រា ៤៩**~ ប្រសិនបើចុងចម្លើយ បានទទួលដីកាអញ្ជើញត្រឹមត្រូវ ហើយនៅតែមិនព្រមចូលមកកាន់តុលាការប្រជាជនខេត្ត-ក្រុង ទាំងលើកទី ១ ទាំងលើកទី ២ ដោយគ្មានមូលហេតុ នោះត្រូវចាត់ទុកថា មិនព្រមសះជានឹងគ្នា ។

**មាត្រា ៥០**~ ប្រសិនបើអ្នកមិនបានមកតាមដីកាអញ្ជើញលើកទី ១ មិនមែនជាអ្នកមិនបានមកលើកទី ២ ទេ តុលាការប្រជាជនខេត្ត-ក្រុង ត្រូវអញ្ជើញភាគីនោះមកផ្សះផ្សាយជាលើកទី ៣ ។

**មាត្រា ៥១**~ ការផ្សះផ្សាម្តងៗ ត្រូវឱ្យឃ្លាតពីគ្នា ១ ខែ យ៉ាងឆាប់ និង ២ ខែយ៉ាងយូរ ។

**មាត្រា ៥២**~ ក្នុងការផ្សះផ្សាម្តងៗ ទោះបីបានលទ្ធផលយ៉ាងណាក្តី ត្រូវចុះក្នុងកំណត់ហេតុបញ្ជាក់អំពីការផ្សះផ្សាបានសំរេច មិនបានសំរេច ឬ ភាគីមិនបានចូល ហើយចៅក្រមទទួលបន្ទុកការផ្សះផ្សាត្រូវ ចុះហត្ថលេខា លើកំណត់ហេតុនោះជាមួយភាគីវត្តមាន និង លេខាធិការក្រឡាបញ្ជី ។

មាត្រា ៥៣~ បើការផ្សះផ្សាមិនបានសំរេច តុលារការប្រជាជនខេត្ត-ក្រុង ត្រូវអញ្ជើញប្តី ប្រពន្ធឱ្យចូលមកកាន់តុលាការប្រជាជន ដើម្បីជំនុំជំរះ ។

មាត្រា ៥៤~ ប្រសិនបើដើមចោទ ត្រូវបានតុលាការប្រជាជនអញ្ជើញដោយត្រឹមត្រូវ ហើយមិនបានមកបង្ហាញខ្លួន ចំពោះតុលាការប្រជាជន និងមិនបានជូនសេចក្តីដោះសា ឬ មិនបានសុំឱ្យបង្អង់កាត់សេចក្តីទៅថ្ងៃក្រោយទេនោះ ត្រូវចាត់ទុកថា សុខចិត្តឈប់ប្តឹងវិញហើយ ។

ក្នុងករណីនេះ ត្រូវចេញសាលក្រមចំណាយរឿងក្តីនោះចោល ។

មាត្រា ៥៥~ ប្រសិនបើចុងចម្លើយ មិនបានចូលមកកាន់តុលាការប្រជាជន ក្នុងល័ក្ខខ័ណ្ឌដូចខាងលើនេះដែរ ហើយបើយល់ឃើញថាហេតុដែលដើមចោទប្តឹងនោះមានភស្តុតាងពិតប្រាកដហើយ តុលាការប្រជាជនអាចសំរេចសេចក្តីឱ្យលែងលះគ្នាបាន ។ បើបណ្តឹងនោះមិនទាន់មានភស្តុតាងគ្រប់គ្រាន់ ទេ តុលាការប្រជាជនត្រូវធ្វើការអង្កេតស៊ើបសួរអំពីរឿងនោះ ។

មាត្រា ៥៦~ បើចុងចម្លើយប្រកែកថា សេចក្តីដែលប្តឹងពីខ្លួននោះមិនពិតទេ តុលាការប្រជាជនត្រូវបញ្ជាឱ្យធ្វើការអង្កេតស៊ើបសួរ ។

មាត្រា ៥៧~ ក្នុងរឿងលែងលះគ្នា បើមានការត្រូវអង្កេតស៊ើបសួរ តុលាការប្រជាជនត្រូវធ្វើការអង្កេតស៊ើបសួរជាបន្ទាន់ ត្រូវបង្គាប់ឱ្យគូភាគី ជូនភស្តុតាងចាំបាច់នានាអញ្ជើញសាក្សីដែលមានប្រយោជន៍ក្នុងរឿងនេះ និង ចាត់វិធានការទូទៅ បើយល់ឃើញថា គួរចាត់ ។

មាត្រា ៥៨~ ក្នុងករណីសុំលែងលះដោយព្រមព្រៀងគ្នា បើក្រោយពីការអង្កេតស៊ើបសួរឃើញថា ការសុំលែងលះគ្នានោះធ្វើដោយគ្មានការបង្ខិតបង្ខំ និង ដោយស្ម័គ្រចិត្តពិតប្រាកដ តុលាការប្រជាជនត្រូវសំរេចអោយលែងលះគ្នា ។

មាត្រា ៥៩~ ក្នុងករណីសុំលែងលះដោយឯកតោភាគី បើក្រោយពីការអង្កេតស៊ើបសួរឃើញថា ស្ថានភាពរវាងប្តី ប្រពន្ធ មានភាពធ្ងន់ធ្ងរ ការរួមរស់ជាមួយគ្នាមិនអាចពន្យាយូរបាន គោលបំណងអាពាហ៍ពិពាហ៍លែងបានសំរេច តុលាការប្រជាជនត្រូវសំរេចឱ្យលែងលះគ្នា ។

មាត្រា ៦០~ តុលាការប្រជាជនអាចធ្វើការស៊ើបសួរ និង ធ្វើការជំនុំជំរះដោយសម្ងាត់បាន ។

មាត្រា ៦១~ ការវិនិច្ឆ័យដល់អង្គសេចក្តី ត្រូវតែធ្វើក្នុងរយៈ ១៥ ថ្ងៃ គិតពីថ្ងៃអង្កេតស៊ើបសួររួចមក ។

មាត្រា ៦២~ តាមគោលការណ៍ សាលក្រមលែងលះគ្នាត្រូវសំរេចចំពោះមុខគូក្តី ។ ប្រសិនបើសាលក្រមនោះជាសាលក្រមកំបាំងមុខ គូក្តីអាចប្តឹងទាស់បាន ក្នុងរយៈ ១៥ ថ្ងៃ ។ រយៈពេលនេះគិតពីថ្ងៃដែលឱ្យដំណឹងពីសាលក្រមកំបាំងមុខដល់គូក្តីផ្ទាល់ ឬ ដល់លំនៅរបស់គូក្តី ។

មាត្រា ៦៣~ បណ្តឹងទាស់និងសាលក្រមកំបាំងមុខ ត្រូវធ្វើដោយសាមីខ្លួន ជាលាយលក្ខណ៍អក្សរ ឬ ដោយផ្ទាល់មាត់នៅតុលាការប្រជាជនខេត្ត ក្រុង ។ បណ្តឹងទាស់នាំឱ្យផ្អាកការអនុវត្តន៍សាលក្រម ។

**មាត្រា ៦៤.** ប្រសិនបើផុតរយៈពេលប្តឹងទាស់ សាលក្រមកំបាំងមុខនឹងទៅជាសាលក្រមស្ថាពរ ។

**មាត្រា ៦៥.** ប្រសិនបើអ្នកប្តឹងទាស់ បានប្តឹងក្នុងរយៈពេលកំណត់ ប៉ុន្តែមិនបានចូលខ្លួនមកក្នុងពេលជំនុំជំរះដោយគ្មានមូលហេតុ នោះសាលក្រមកំបាំងមុខត្រូវតំកល់ជាបានការ និង ទៅជាសាលក្រមស្ថាពរ ។

**មាត្រា ៦៦.** ប្រសិនបើបណ្តឹងជំទាស់ត្រឹមត្រូវតាមទម្រង់ច្បាប់តុលាការប្រជាជនខេត្ត-ក្រុង ត្រូវពិនិត្យ និង ជំនុំជំរះសាជាថ្មីលើអង្គសេចក្តី ។

តុលាការប្រជាជនអាចតំកល់ កែប្រែ ឬ បដិសេធសាលក្រមកំបាំងមុខ ដែលបានសំរេចសេចក្តី លើកមុនបាន កុំឱ្យតែបំពានលើច្បាប់ ឬ គោលការណ៍នៃច្បាប់ ។

**មាត្រា ៦៧.** កាលបើសាលក្រមលែងលះជាសាលក្រមស្ថាពរ តុលាការប្រជាជនខេត្ត-ក្រុង ត្រូវចាត់ចែងឱ្យចម្លងសេចក្តីនៃសាលក្រមស្ថាពរនោះ ចុះនៅរឹមទំព័រនៃសំបុត្រអាពាហ៍ពិពាហ៍ដែលត្រូវរលាយ ។

**មាត្រា ៦៨.** ប្រសិនបើប្រពន្ធមានផ្ទៃពោះ ប្តីងអាចនឹងសុំលែងលះបាន លុះត្រាតែប្រពន្ធនោះសំរាលកូនរួចបាន ១ឆ្នាំសិន ។

ការបន្ថយសិទ្ធិខាងលើមិនត្រូវអនុវត្តលើនារីទេ ។ នារីអាចសុំលែងលះបាននៅពេលមានផ្ទៃពោះ ។

## ផ្នែកទី ៣
## អំពីអនុភាពនៃការលែងលះគ្នា

**មាត្រា ៦៩.** ការលែងលះគ្នារំសាយអនុភាពអាពាហ៍ពិពាហ៍ ចាប់តាំងពីថ្ងៃដែលការលែងលះគ្នានោះ ទៅជាស្ថាពរ ។

**មាត្រា ៧០.** ក្នុងករណីនៃការលែងលះគ្នា ទ្រព្យសម្បត្តិត្រូវបែងចែកទៅតាមការព្រមព្រៀងនៃភាគីទាំងសងខាង ។ បើគ្មានការព្រមព្រៀង សហព័ន្ធម្នាក់ៗត្រូវយកតែទ្រព្យសម្បត្តិផ្ទាល់ខ្លួនដែលមានមុនរៀបអាពាហ៍ពិពាហ៍ និង ទ្រព្យសម្បត្តិដែលខ្លួនបានទទួលជាមតិកក្តី ជាអំណោយក្តី ជាអច្ច័យទានក្តី ក្នុងរយៈមានចំណងអាពាហ៍ពិពាហ៍ប៉ុណ្ណោះ ។

ក្រៅពីនេះ សហព័ន្ធម្នាក់ៗ មានសិទ្ធិត្រូវបានទ្រព្យសម្បត្តិរួមពាក់កណ្តាលម្នាក់ ។

ប៉ុន្តែក្នុងករណីពិសេស និង តាមសំណើរបស់សហព័ន្ធណាមួយ តុលាការប្រជាជនអាចសំរេចសេចក្តីចែកទ្រព្យសម្បត្តិរួម ផ្សេងពីគោលការណ៍ខាងលើបាន ដោយគិតទៅដល់ផលប្រយោជន៍របស់កូន និង ផលិតកម្ម ។

ការងារនៃគេហកិច្ច ត្រូវចាត់ទុកជាមានតម្លៃស្មើនឹងការងារផលិតកម្ម ។

**មាត្រា ៧១៲** ប្រសិនបើទ្រព្យសម្បត្តិផ្ទាល់របស់សហព័ន្ធម្នាក់ត្រូវសហព័ន្ធម្នាក់ទៀតបំផ្លាញ សហព័ន្ធនេះត្រូវតែសងតម្លៃ ទ្រព្យនោះវិញ ។

**មាត្រា ៧២៲** សាលក្រមដែលកាត់ឱ្យប្តីប្រពន្ធលែងលះគ្នានោះ ត្រូវសំរេចអំពីអំណាចមេបា ដែលត្រូវប្រគល់ឱ្យទៅឪពុក ឬ ទៅម្តាយ ហើយនិងត្រូវសំរេចអំពីការប្រាស្រ័យទាក់ទងរវាងឪពុក ម្តាយ និងកូននោះផង ។

**មាត្រា ៧៣៲** ដើម្បីផលប្រយោជន៍របស់កូន ការឱ្យភាគីណាមួយរក្សាកូន ត្រូវសំរេចតាមការយល់ព្រមនៃប្តីប្រពន្ធដែលលែងលះគ្នានោះ ។ តាមគោលការណ៍កូនដែលនៅបៅដោះត្រូវឱ្យទៅម្តាយរក្សា ។

ក្នុងករណីដែលគូភាគីទាំងសងខាង មិនឯកភាពគ្នាលើការរក្សាកូន តុលាការប្រជាជនត្រូវសំរេច ។

**មាត្រា ៧៤៲** ឪពុក ឬ ម្តាយដែលលែងលះគ្នា ត្រូវជួយផ្គត់ផ្គង់ ជួយបីបាច់រក្សា ជួយផ្តល់សោហ៊ុយ អប់រំ និងរៀនសូត្រដល់កូន តាមលទ្ធភាពរបស់ខ្លួន ។

កម្រិតអាហារកិច្ចដែលត្រូវឱ្យទៅកូន ត្រូវសំរេចតាមការព្រមព្រៀងនៃសហព័ន្ធដែលលែងលះគ្នា ។

ក្នុងករណីដែលគូភាគីទាំងសងខាង មិនឯកភាពគ្នា តុលាការប្រជាជនត្រូវសំរេច ដោយផ្អែកទៅតាមលទ្ធភាពរបស់សហព័ន្ធម្នាក់ៗ ។

អាហារកិច្ចត្រូវផ្តល់ឱ្យកូនរហូត ដល់កូនមាននីតិភាព ។

**មាត្រា ៧៥៲** ភាគីដែលមិនបានរក្សាកូន មានសិទ្ធិទៅសួរសុខទុក្ខកូន ។ ភាគីដែលទទួលសិទ្ធិរក្សាកូនត្រូវបង្កលក្ខណៈងាយស្រួលគ្រប់បែបយ៉ាងដល់ភាគីម្ខាងទៀត ។

ភាគីដែលមិនបានរក្សាកូន មានសិទ្ធិប្តឹងទៅតុលាការប្រជាជនគ្រប់ពេលវេលា ឱ្យដកសិទ្ធិរក្សាកូនពីភាគីម្ខាងនោះបាន បើមានការប៉ះពាល់ដល់ផលប្រយោជន៍របស់កូន ។

**មាត្រា ៧៦៲** ក្នុងករណីលែងលះគ្នា ភាគីដែលគ្មានកំហុសហើយខ្វះខាត អាចស្នើសុំអាហារកិច្ចពីភាគីម្ខាងទៀតបាន ។ ភាគីខាងក្រោយនេះ ត្រូវតែជួយឧត្ថម្ភទៅតាមលទ្ធភាពរបស់ខ្លួន ។

កំរិតអាហារកិច្ចត្រូវសំរេចតាមការយល់ព្រមរបស់គូភាគីទាំងសងខាង ។

ក្នុងករណីដែលគូភាគីទាំងសងខាង មិនឯកភាពគ្នា តុលាការប្រជាជនត្រូវសំរេចសេចក្តី ។

បើជនដែលទទួលអាហារកិច្ចរៀបអាពាហ៍ពិពាហ៍ថ្មីទៀត ជននោះឈប់មានសិទ្ធិទទួលអាហារកិច្ចទៀតហើយ ។

**មាត្រា ៧៧.-** តុលាការប្រជាជនខេត្ត-ក្រុង អាចកែប្រែដោយបង្កើន ឬ បន្ថយកំរិតអាហារកិច្ចបាន បើមានសំណូមពររបស់ភាគីម្ខាង ។ ការបង្កើន ឬ បន្ថយកកម្រិតអាហារកិច្ចនោះ ត្រូវធ្វើឡើងតាមលទ្ធភាពនៃភាគីដែលផ្តល់អាហារកិច្ច និង តាមសេចក្តីត្រូវការនៃភាគីដែលទទួលអាហារកិច្ច ។

អាហារកិច្ចអាចផ្តល់ឱ្យជាទឹកប្រាក់ ឬ ជារបស់ ។

**មាត្រា ៧៨.-** ការមិនព្រមបង់អាហារកិច្ចដូចបានចែងខាងលើនេះ ចាត់ទុកជាបទល្មើសព្រហ្មទណ្ឌ ដែលនឹងត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន បើកាលណាមានភស្តុតាង បញ្ជាក់ថា ជនដែលត្រូវផ្តល់អាហារកិច្ចនោះ មិនស្មោះត្រង់ ។

## តារាងនៃថ្នាក់ញាតិភាព
## (TABLEAU DES DEGRÉS DE LA PARENTÉ)

ខ្សែផ្ទាល់
( Ligne directe )

ខ្សែខាងឪពុក ខ្សែខាងម្តាយ




សាខាញាតិ
(Ligne collatérale)



ចំពោះខ្សែផ្ទាល់ ក៏ដូចជាសាខាញាតិ សុទ្ធតែមានញាតិលោហិត និង ញាតិពន្ធ ។

ញាតិលោហិត : ញាតិដែលមានឈាមជាមួយគ្នា ។

ញាតិពន្ធ : សាច់ថ្លៃ (បងថ្លៃ ប្អូនថ្លៃ ឪពុក-ម្តាយក្មេក និង កូនប្រសា ជីតា ជីដូនក្មេក និង ចៅប្រសា) ។

សាខាញាតិ : ញាតិដែលចែកចេញជា មែកធាងពីអ្នកបង្កើតរួមដូចជាមីងមា ក្មួយ បងប្អូនបង្កើត បងប្អូនជីដូនមួយ ។

បងប្អូនបង្កើត : កូនដែលកើតពីឪពុក-ម្តាយជាមួយគ្នា គឺរួមឪពុក-ម្តាយ ឬ រួមតែឪពុក គឺឪពុកជាមួយគ្នា ម្តាយទីទៃ ឬ ក៏រួមតែម្តាយ គឺម្តាយជាមួយគ្នា ឪពុកទីទៃ ។

## ជំពូកទី ៥

## អំពីអាពាហ៍ពិពាហ៍នៅបរទេស និង អាពាហ៍ពិពាហ៍ជាមួយបរទេស

### ផ្នែកទី ១

### អំពីអាពាហ៍ពិពាហ៍

**មាត្រា ៧៩.-** អាពាហ៍ពិពាហ៍រវាងពលរដ្ឋកម្ពុជា និង ពលរដ្ឋកម្ពុជា ឬ រវាងពលរដ្ឋកម្ពុជា និង ជនបរទេស ដែលរស់នៅឯបរទេស ត្រូវប្រព្រឹត្តទៅនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន នៃស្ថានទូត ឬ ស្ថានកុង ស៊ុល នៃរដ្ឋកម្ពុជាប្រចាំនៅប្រទេសដែលគូភាគីមានទីលំនៅ ។

ក្នុងករណីដែលអាពាហ៍ពិពាហ៍ រវាងពលរដ្ឋកម្ពុជា និង ពលរដ្ឋកម្ពុជា និង អាពាហ៍ពិពាហ៍ រវាងពលរដ្ឋកម្ពុជា និង ជនបរទេស បានប្រព្រឹត្តទៅត្រឹមត្រូវតាមទំរង់នៃ អាពាហ៍ពិពាហ៍ ដែលមានចែងក្នុងច្បាប់ នៃកន្លែងរៀបអាពាហ៍ពិពាហ៍នោះ ត្រូវបានទទួល ស្គាល់យកជាការបាននៅរដ្ឋកម្ពុជា ប្រសិនបើអាពាហ៍ពិពាហ៍នោះមិនផ្ទុយនឹងបទបញ្ញត្តិច្បាប់ នៃរដ្ឋកម្ពុជា ។

លិខិតបញ្ជាក់អាពាហ៍ពិពាហ៍ ឬ សេចក្តីចម្លងលិខិតអាពាហ៍ពិពាហ៍នេះ ត្រូវយកមកចុះ ក្នុងបញ្ជីអាពាហ៍ពិពាហ៍នៃស្ថានទូត ឬស្ថានកុងស៊ុលនៃរដ្ឋកម្ពុជា ឬគូស្វាមីភរិយាមកតាំងទី លំនៅក្នុងរដ្ឋកម្ពុជា ត្រូវយកមកចុះក្នុងបញ្ជីអាពាហ៍ពិពាហ៍នៅឃុំ ឬ សង្កាត់ ដែលមកតាំង ទីលំនៅនោះ ។

**មាត្រា ៨០.-** អាពាហ៍ពិពាហ៍រវាងពលរដ្ឋកម្ពុជា និង ជនបរទេសនៅរដ្ឋកម្ពុជា ត្រូវប្រព្រឹត្តទៅតាមច្បាប់ នៃរដ្ឋកម្ពុជា ។

## ផ្នែកទី ២
## អំពីការរំលាយអាពាហ៍ពិពាហ៍

**មាត្រា ៨១**៖ ការរំលាយអាពាហ៍ពិពាហ៍ ដែលធ្វើនៅឯបរទេសរវាងពលរដ្ឋកម្ពុជា និង ពលរដ្ឋកម្ពុជា ឬ រវាងពលរដ្ឋកម្ពុជា និង ជនបរទេស ដែលរស់នៅឯបរទេស ត្រូវបានទទួលស្គាល់យកជាការបាននៅរដ្ឋកម្ពុជា ។

- ការរំលាយអាពាហ៍ពិពាហ៍រវាងពលរដ្ឋកម្ពុជា និងជនបរទេស ឬ ការរំលាយអាពាហ៍ពិពាហ៍រវាងជនបរទេស និងជនបរទេសនៅរដ្ឋកម្ពុជាត្រូវធ្វើតាមច្បាប់នៃរដ្ឋកម្ពុជា ។
- តុលាការប្រជាជននៃរដ្ឋកម្ពុជា មានសមត្ថកិច្ចសំរេចលើបណ្តឹងសុំរំលាយអាពាហ៍ពិពាហ៍ របស់សហព័ទ្ធណាមួយដែលចូលមកតាំងទីលំនៅៗរដ្ឋកម្ពុជា ។

## ជំពូកទី ៥
## អំពីគ្រួសារ
## ផ្នែកទី ១
## អំពីកូនមានខាន់ស្លា

**មាត្រា ៨២**៖ កូន នឹងទុកជាកូនមានខាន់ស្លា លុះត្រាតែកូននោះកើតមកពីឪពុកម្តាយ ដែលបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា និង លុះត្រាតែម្តាយនៃកូននោះមានគភ៌ក្នុងរយៈពេល ដែលឪពុកម្តាយនៅជាប់ចំណងអាពាហ៍ពិពាហ៍នឹងគ្នា បានន័យថា កូនដែលកើត ១៨០ ថ្ងៃយ៉ាងតិចក្រោយថ្ងៃរៀបអាពាហ៍ពិពាហ៍ ឬ ក្នុងរយៈពេល ៣០០ ថ្ងៃ គិតពីថ្ងៃដាច់ចំណងអាពាហ៍ពិពាហ៍ ។

**មាត្រា ៨៣**៖ កូនដែលកើតក្នុងរយៈវេលាតិចជាង ១៨០ ថ្ងៃ គិតពីថ្ងៃរៀបអាពាហ៍ពិពាហ៍ និងទុកថា កូនរបស់ប្តីនៃម្តាយបាន កាលបើមានភស្តុតាងច្បាស់ថា ប្តីនេះបានដឹងថា ប្រពន្ធរបស់ខ្លួនមានផ្ទៃពោះតាំងពីមុនរៀបអាពាហ៍ពិពាហ៍មកម្ល៉េះ ឬ ក៏ព្រមទទួលស្គាល់ថា ខ្លួនជាឪពុករបស់កូននោះ ។ បើមិនដូច្នេះទេ ប្តីរបស់ម្តាយនៃកូននោះអាចបដិសេធថា ខ្លួនមិនមែនជាឪពុករបស់កូននោះបាន ដោយមិនចាំបាច់បង្ហាញភស្តុតាងថាខ្លួនមិនមែនជាឪពុក ។

**មាត្រា ៨៤**៖ កូនដែលកើតក្នុងល័ក្ខខ័ណ្ឌ នៃពេលដែលមានចែងក្នុងមាត្រា៨២ ជាភស្តុតាងយ៉ាងមាំ តម្រូវឱ្យសន្មត់ថា ប្តីនៃម្តាយគឺពិតជាឪពុករបស់កូននោះ ។ ប្តីនៃម្តាយអាចមិនទទួលស្គាល់ថា កូននោះជាកូនរបស់ខ្លួនបាន លុះណាតែប្តីនោះប្តឹងបដិសេធបិតុភាព ។

**មាត្រា ៨៥**៖ ការប្តឹងប្រកែកមិនទទួលស្គាល់បិតុភាព ត្រូវប្តីប្តឹងពីម្តាយ និង ពីកូន ចំពោះមុខតុលាការប្រជាជនខាងលំនៅនៃម្តាយក្នុងរយៈពេល ២ ខែ គិតពីថ្ងៃដែលខ្លួនបានដឹងពីកំណើតនៃកូននោះ ។

**មាត្រា ៨៦**- ប្តីត្រូវជូនភស្តុតាងថា កាលប្រពន្ធខ្លួនមានគភ៌ ក្នុងរយៈពេលដែលច្បាប់បានកំណត់នោះ ខ្លួនមានវិបត្តិខាងរូបកាយ មិនអាចរួមដំណេកជាមួយម្តាយនៃកូននោះបានទេ ។ វិបត្តិខាងរូបកាយដែលពុំអាចឱ្យរួមដំណេកបាននោះ អាចកើតមកពីហេតុ ២ យ៉ាង :

១- ប្តីប្រពន្ធរស់នៅដាច់ឆ្ងាយពីគ្នា

២- ប្តីគ្មានពលានុភាពបណ្តាលមកពីកាយវិកលកម្ម ដែលមិនអាចឱ្យបន្តពូជបាន ។

**មាត្រា ៨៧**- ទាយាទខាងប្តី អាចនឹងប្តឹងបដិសេធកូននោះជួសបាន ក្នុងរយៈពេលដែលមានចែងក្នុងមាត្រា ៨៥ ប្រសិនបើប្តីនោះមិនអាចប្តឹងបាន ដោយប្តីនោះស្លាប់បាត់ខ្លួន ឬ ក៏វង្វេងលេលា ។

ទាយាទខាងប្តីអាចនឹងបន្តការប្តឹងបដិសេធកូននោះបាន ប្រសិនបើក្នុងរយៈពេល ដែលមានចែងក្នុងមាត្រា ៨៥ ប្តីនោះបានប្តឹងបដិសេធរួចហើយ ហើយស្លាប់បាត់ខ្លួន ឬ ក៏វង្វេងលេលា ។

**មាត្រា ៨៨**- សាលក្រមដែលសំរេចទទួលបណ្តឹងបដិសេធនោះ ទុកជាត្រឹមត្រូវ ត្រូវបង្គាប់អោយលុបឈ្មោះប្តីនោះ ចេញពីបញ្ជីសំបុត្រកំណើតរបស់កូន ហើយឱ្យដកត្រកូលឪពុកចេញពីកូន ដោយយកត្រកូលម្តាយដាក់ជំនួសវិញ ។

**មាត្រា ៨៩**- ត្រូវបញ្ជូនសេចក្តីសំរេចនៃសាលក្រមទៅឱ្យមន្ត្រីអត្រានុកូលដ្ឋានដែលបានធ្វើសំបុត្រកំណើតរបស់ កូននោះ ដើម្បីឱ្យចម្លងដាក់ក្នុង បញ្ជីសំបុត្រកំណើតហើយចុះនិទ្ទេសនៅរឹមទំព័រ នៃសំបុត្រ កំណើតដែលត្រូវកែនោះ ។

## ផ្នែកទី ២

## អំពីកូនឥតខាន់ស្លា

**មាត្រា ៩០**- ដែលហៅថា កូនឥតខាន់ស្លា គឺកូនដែលកើតពីឪពុកម្តាយគ្មានចំណងដៃអាពាហ៍ពិពាហ៍ ។

**មាត្រា ៩១**- នៅពេលធ្វើសំបុត្រកំណើត បើឪពុកម្តាយ ដែលគ្មានចំណងដៃអាពាហ៍ពិពាហ៍ បានឆ្លើយទទួលស្គាល់ដោយជាក់លាក់នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានថា កូនដែលកើតមកនោះជាកូនរបស់ខ្លួន នោះត្រូវចាត់ទុកឪពុកម្តាយនេះថា ឪពុកម្តាយរបស់កូននោះ ។

**មាត្រា ៩២**- បើមានតែឪពុក ឬ មានតែម្តាយ ឆ្លើយទទួលស្គាល់ម្នាក់ឯងទេ កូននោះត្រូវចាត់ទុកជាកូនរបស់អ្នកដែលបានឆ្លើយទទួលស្គាល់តែម្នាក់ប៉ុណ្ណោះ ។

**មាត្រា ៩៣-** ក្រោយពេលដែលឪពុក ឬ ម្តាយបានប្តឹងចុះកំណើតកូន ឪពុក ឬ ម្តាយណាដែលមិនទាន់ទទួលស្គាល់ឪពុក ឬម្តាយនោះ អាចប្តឹងសុំទទួលស្គាល់កូនជាក្រោយបាន ។

**មាត្រា ៩៤-** កូនឥតខាន់ស្លាដែលឪពុកម្តាយបានទទួលស្គាល់នឹងទៅជាកូនមានខាន់ស្លាបាន បើក្រោយពីកំណើតរបស់កូននោះ ឪពុកម្តាយរបស់កូននោះ បានចុះអាពាហ៍ពិពាហ៍ជាមួយគ្នា ។

ការទទួលស្គាល់កូនអាចធ្វើនៅមុនពេលចុះអាពាហ៍ពិពាហ៍ ធ្វើដំណាលគ្នានឹងពេលចុះអាពាហ៍ពិពាហ៍ ឬ ក្រោយពេលចុះអាពាហ៍ពិពាហ៍ក៏បាន ។

## ផ្នែកទី ៣

## អំពីការស្វែងរកបិតុភាព ឬ មាតុភាព
## នៃកូនឥតខាន់ស្លា

**មាត្រា ៩៥-** បើគ្មានលិខិតធ្វើទទួលស្គាល់ ដោយស្ម័គ្រចិត្តនូវកូនឥតខាន់ស្លាទេ នោះតុលាការប្រជាជនអាចតម្រូវឱ្យឪពុក ឬ ម្តាយទទួលស្គាល់កូននោះបាន ។

**មាត្រា ៩៦-** កូនឥតខាន់ស្លាដែលឪពុក ឬ ម្តាយមិនបានទទួលស្គាល់ មានសិទ្ធិប្តឹងសុំឱ្យតុលាការប្រជាជនរកឪពុក ឬ រកម្តាយឱ្យខ្លួនបាន ។

**មាត្រា ៩៧-** បណ្តឹងសុំឱ្យតុលាការប្រជាជន តម្រូវឱ្យឪពុក ឬ ម្តាយទទួលស្គាល់នោះ អាចធ្វើឡើងក្នុងរយៈពេល ២ ឆ្នាំ គិតពីថ្ងៃដែលកូននោះមាននីតិភាព ។

នីតិភាពត្រូវកំណត់ចាប់ពីអាយុ ១៨ ឆ្នាំឡើងទៅ ។

ក្នុងពេលដែលកូនឥតខាន់ស្លា នៅក្នុងអនីតិភាពនៅឡើយ អ្នកអាណាព្យាបាលរបស់កូននោះមានសិទ្ធិប្តឹងជួស សុំឱ្យតុលាការប្រជាជន រកមាតុភាពឱ្យកូននោះ ។

**មាត្រា ៩៨-** តុលាការប្រជាជន អាចតម្រូវឱ្យនារីជាម្តាយទទួលស្គាល់កូនឥតខាន់ស្លាបាន បើមានភស្តុតាងបញ្ជាក់ថា :

ក- នារីនោះបានបង្កើតកូនប្រាកដមែន

ខ- អត្តសញ្ញាណរបស់កូនដែលនារីនោះបានបង្កើត និង អត្តសញ្ញាណរបស់កូន ដែលប្តឹងទាមទាររកមាតុភាព នោះមិនខុសប្លែកពីគ្នា ។

ភស្តុតាងអាចបង្ហាញបានតាមគ្រប់មធ្យោបាយ ។

**មាត្រា ៩៩-** តុលាការប្រជាជន អាចតំរូវឱ្យបុរសជាឪពុកទទួលស្គាល់កូនឥតខាន់ស្លាបាន :

១-បើបុរសនោះបាននាំពង្រត់ ឬ បានចាប់រំលោភសេពសន្ថវៈនារីជាម្តាយដោយរំលោភ ហើយបើសម័យនាំពង្រត់ ឬ ចាប់រំលោភសេពសន្ថវៈនោះ ត្រូវគ្នានឹងសម័យដែលនារីនោះមានគភ៌ ។

២-បើបុរសនោះបានខ្លួននារី ដោយឧបាយកលបោកបញ្ឆោតដោយការរំលោភអំណាច ឬ ដោយការសន្យាថា នឹងរៀបអាពាហ៍ពិពាហ៍ជាមួយនារីនោះ ។

៣-បើមានភស្តុតាងជាលាយលក្ខណ៍អក្សរពីបុរសនោះ បង្ហាញឱ្យឃើញច្បាស់ថា បុរសនោះពិតជាឪពុករបស់កូននោះ ។

៤- បើបុរស នឹង នារីជាឪពុកម្តាយ និង ជាម្តាយរបស់កូននោះ បានរួមរស់ និងគ្នាជាអនីតិសង្វាសជាក់ស្តែងក្នុងសម័យនីត្យានុកូលដែលនារីនោះមានគភ៌ ។

៥- បើបុរសនោះបានផ្គត់ផ្គង់ ឬ បានចូលរួមក្នុងការបីបាច់រក្សា និង ការអប់រំកូននោះក្នុងឋានៈខ្លួនជាឪពុក ។

**មាត្រា ១០០**- ពាក្យដែលប្តឹងរកបិតុភាពមិនអាចនឹងទទួលបាន :

១- បើមានភស្តុតាងថា នារីជាម្តាយមានទំនាក់ទំនងកាមគុណនឹងប្រុសដទៃទៀត ក្នុងសម័យនីត្យានុកូលដែលនារីនោះមានគភ៌ ។

២- បើក្នុងសម័យនីត្យានុកូលដែលនារី មានគភ៌បុរសដែលត្រូវប្រកាន់ថា ជាឪពុករបស់កូននោះ គ្មានលទ្ធភាពរួមដំណេកជាមួយនារីជាម្តាយនោះ ដោយរស់នៅឆ្ងាយពីគ្នា ឬ ដោយមកពីមានគ្រោះថ្នាក់ ដូចមានចែងក្នុងមាត្រា ៨៦ ។

**មាត្រា ១០១**- ក្នុងពេលដែលកូនឥតខាន់ស្លា នៅក្នុងអនីតិភាពនៅឡើយ ម្តាយ ឬ អ្នកអាណាព្យាបាលនៃកូននោះអាចប្តឹងសុំឱ្យរកបិតុភាពបាន ។

ភស្តុតាងអាចបង្ហាញបានតាមគ្រប់មធ្យោបាយ ។

**មាត្រា ១០២**- សាលក្រមដែលកាត់សេចក្តីឱ្យទទួលស្គាល់កូនឥតខាន់ស្លា មានអានុភាពដូចគ្នានឹងលិខិតដែលទទួលស្គាល់កូនដោយស្ម័គ្រចិត្តដែរ ។

**មាត្រា ១០៣**- កូនឥតខាន់ស្លា ត្រូវយកត្រកូលរបស់ឪពុក ឬ ម្តាយដែលទទួលស្គាល់ខ្លួន ។ ប្រសិនបើឪពុក និង ម្តាយទាំងពីរនាក់ទទួលកូននោះ ត្រូវយកត្រកូលរបស់ឪពុក ។

ប្រសិនបើតុលាការប្រជាជន តម្រូវឱ្យឪពុក ឬ ម្តាយទទួលស្គាល់កូននោះ ត្រូវយកត្រកូលរបស់អ្នក ដែលតុលាការតម្រូវឱ្យទទួលស្គាល់ ។

ប្រសិនបើតុលាការប្រជាជនតម្រូវឱ្យឪពុក និង ម្តាយទាំងពីរនាក់ទទួលស្គាល់ កូននោះត្រូវយកត្រកូលរបស់ឪពុក ។

**មាត្រា ១០៤**- កូនឥតខាន់ស្លា ដែលត្រូវបានទទួលស្គាល់មានករណីយកិច្ច និង មានសិទ្ធិដូចគ្នានឹងកូនមានខាន់ស្លាដែរ ។

មាត្រា ១០៥~ តុលាការប្រជាជន ត្រូវបង្គាប់ឱ្យឪពុក ឬ ម្តាយផ្តល់អាហារកិច្ចឱ្យកូនជាដរាប តាមសមាមាត្រនៃធនធានរបស់ឪពុក ឬ ម្តាយនោះ ។

អាហារកិច្ចនេះ ត្រូវផ្តល់ឱ្យកូនតាមការកំណត់នៃសាលក្រម រហូតដល់កូននោះ មាននីតិភាព ។

ឪពុក ឬ ម្តាយអាចត្រូវឱ្យរួចពីកាតព្វកិច្ចនេះបាន បើខ្លួនព្រមទទួលយកកូននោះទៅចិញ្ចឹមបីបាច់រក្សា ។

មាត្រា ១០៦~ សាលក្រមដែលកាត់សេចក្តីឱ្យទទួលស្គាល់កូនឥតខាន់ស្លា អាចនឹងបង្ខំឱ្យឪពុកសងសោហ៊ុយសំរាលកូន និង ប្រាក់ចំណាយចិញ្ចឹមបីបាច់រក្សាកូនតាំងពីថ្ងៃដែលកូននោះកើតមក ទៅម្តាយនៃកូននោះបាន ។

មាត្រា ១០៧~ កំណត់ដៃមួយច្បាប់នៃសាលក្រមស្ថាពរដែលកាត់សេចក្តីឱ្យទទួលស្គាល់កូនឥតខាន់ស្លា ត្រូវផ្ញើទៅមន្ត្រីអត្រានុកូលដ្ឋាន នៃទីកន្លែងដែលកូននោះកើត ដើម្បីនិទ្ទេសអំពីបុគ្គភាពនេះ នៅរឹមទំព័រនៃសំបុត្រកំណើត ។

## ផ្នែកទី ៤
## អំពីសុំកូន

មាត្រា ១០៨~ សុំកូន គឺជាកិច្ចសន្យា ដែលចងបុគ្គលពីរនាក់ គឺម្នាក់ហៅថា ឪពុកចិញ្ចឹម ឬម្តាយចិញ្ចឹម ហើយម្នាក់ទៀត ហៅថា កូនចិញ្ចឹម ឱ្យមានចំណងនឹងគ្នា ដូចជាបុគ្គភាពមានខាន់ស្លា ។

មាត្រា ១០៩~ ឪពុក ឬ ម្តាយចិញ្ចឹម ត្រូវមានអាយុលើសពី ២៥ ឆ្នាំ ហើយត្រូវមានអាយុច្រើនជាងកូនចិញ្ចឹមយ៉ាងតិច ២០ ឆ្នាំ ។ ឪពុក ឬ ម្តាយចិញ្ចឹមអាចជាពលរដ្ឋកម្ពុជា ឬ ជនបរទេស ។

មាត្រា ១១០~ គេអាចសុំកូនបានត្រឹម ២ នាក់ប៉ុណ្ណោះ ។ ប្រសិនបើកូនដែលសុំមកនោះ មានមួយណាស្លាប់ គេអាចសុំកូនមួយនាក់ទៀតបាន ។

-កូនចិញ្ចឹម ត្រូវមានអាយុតិចជាង ៨ ឆ្នាំ ។

មាត្រា ១១១~ សហព័ទ្ធណាមួយអាចនឹងសុំកូនយកមកចិញ្ចឹមបាន លុះត្រាតែមានការយល់ព្រមពីសហព័ទ្ធរបស់ខ្លួន ។

ក្នុងករណីនេះ កូនចិញ្ចឹមត្រូវទុកជាកូនចិញ្ចឹមរបស់សហព័ទ្ធទាំងពីរនាក់ ។

មាត្រា ១១២~ ដើម្បីឱ្យការសុំកូនសំរេចទៅបានត្រូវមានការព្រមព្រៀងពីឪពុកម្តាយ ឬអ្នកអាណាព្យាបាលនៃកូនដែលសុំនោះ ។

បើជាទារកដែលគេបោះបង់ចោល ត្រូវមានការយល់ព្រមពីរដ្ឋអំណាចឃុំ ឬ សង្កាត់ ។

មាត្រា ១១៣- កិច្ចសន្យាសុំកូន ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយបញ្ជាក់ដោយគណៈកម្មាធិការប្រជាជនឃុំ ឬ សង្កាត់ខាងលំនៅនៃអ្នកសុំ ឬ ខាងលំនៅនៃកូនចិញ្ចឹម ។ សេចក្តីនៃកិច្ចសន្យាសុំកូននោះ ត្រូវចុះក្នុងបញ្ជីអាត្រានុកូលដ្ឋាន ។

តុលាការប្រជាជន អាចបដិសេធកិច្ចសន្យាខាងលើនេះបាន តាមពាក្យប្តឹងសុំរបស់កូនចិញ្ចឹមរបស់ជនទាំងឡាយ ឬ របស់អង្គការផ្សេងៗ ដែលធ្វើឡើងដើម្បីផលប្រយោជន៍របស់កូនចិញ្ចឹមនោះ ។

មាត្រា ១១៤- កូនចិញ្ចឹមត្រូវយកនាមត្រកូលនៃអ្នកសុំហើយមានសិទ្ធិ និង ករណីយកិច្ចដូចគ្នានឹងកូនបង្កើត ។

## ផ្នែកទី ៥

## អំពីទំនាក់ទំនងរវាងឪពុក ម្តាយ និង កូន

មាត្រា ១១៥- ឪពុកម្តាយមានករណីយកិច្ចត្រូវស្រឡាញ់កូន ចិញ្ចឹមបីបាច់រក្សាកូន និង យកចិត្តទុកដាក់អប់រំកូន គឺបណ្តុះគំនិតកូនអោយស្រឡាញ់ការរៀនសូត្រ ស្នេហាមាតុភូមិ មានស្មារតី សាមគ្គីអន្តរជាតិ ស្រឡាញ់ពលកម្ម គោរពទ្រព្យសម្បត្តិរដ្ឋ គោរពសិទ្ធិ និង ទ្រព្យសម្បត្តិ របស់អ្នកដទៃ ។

កូនមានករណីយកិច្ចត្រូវស្រឡាញ់ និង គោរពឪពុកម្តាយ ថែទាំរក្សា ឪពុក ម្តាយ និង ផ្គត់ផ្គង់ សេចក្តីត្រូវការរបស់ឪពុក ម្តាយ ។

មាត្រា ១១៦- ឪពុក ម្តាយ មិនត្រូវធ្វើបាបកូនរបស់ខ្លួន កូនប្រសា កូនចិញ្ចឹម ឬ កូនរបស់ប្តី ឬ របស់ប្រពន្ធមុនឡើយ ។

មាត្រា ១១៧- កូនប្រសា និង កូនស្រីមានសិទ្ធិ និង ករណីយកិច្ចដូចគ្នាក្នុងគ្រួសារ ។

មាត្រា ១១៨- កូនមាននីតិភាព ដែលរស់នៅជាមួយ ឪពុកម្តាយ មានសេរីភាពក្នុងការជ្រើសរើសមុខរបររបស់ខ្លួន មានសេរីភាពក្នុងការចូលរួមសកម្មភាពនយោបាយ និង សកម្មភាពសង្គម មានសេរីភាពក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិផ្ទាល់ខ្លួន ម្យ៉ាងវិញទៀត ក៏ត្រូវមានករណីយកិច្ចត្រូវមើលខុសត្រូវដោះស្រាយជីវភាពរួម របស់គ្រួសារ ។

## ផ្នែកទី ៦

## អំពីការដកហូតអំណាចមេបា

មាត្រា ១១៩- អាចនឹងដកហូតអំណាចមេបា ហើយប្រគល់ទៅអង្គការណាមួយ ឬញាតិលោហិតណាមួយចំពោះ ឪពុក ម្តាយ ដែល មានកំហុសដូចខាងក្រោម :

- ឪពុក ម្តាយ មានការខ្វះខាតក្នុងការអប់រំ
- ឪពុក ម្តាយ ប្រើអំណាចដោយរំលោភទៅលើកូនដោយប្រើឧបាយផ្សេងៗ ដើម្បីបង្ខំកូនឱ្យប្រព្រឹត្តបទល្មើស ឬ អំពើណាមួយប៉ះពាល់ដល់សង្គម ។

- ឪពុក ម្តាយ ប្រព្រឹត្តផ្ទុយពីសីលធម៌បណ្តាលឱ្យមានឥទ្ធិពលអាក្រក់ដល់កូន ។

**មាត្រា ១២០.** តុលាការប្រជាជន អាចនឹងសំរេចដកហូតអំណាចមេបាពីឪពុកម្តាយ ដែលមានកំហុសបាន លុះត្រាតែមានពាក្យប្តឹងសុំរបស់អង្គការរដ្ឋ អង្គការមហាជន រដ្ឋអាជ្ញាអមតុលាការប្រជាជន ឬ ញាតិលោហិតណាមួយនៃឪពុកម្តាយនោះ ។

**មាត្រា ១២១.** ការហូតអំណាចមេបា បណ្តាលឱ្យឪពុកម្តាយ លែងមានសិទ្ធិ ដែលខ្លួនធ្លាប់មានពីមុនចំពោះកូនរបស់ខ្លួន ប៉ុន្តែនៅមានកាតព្វកិច្ចចិញ្ចឹមកូននោះទៀត រហូតដល់កូននេះចូលនីតិភាព ។ ក្នុងករណីនេះ តុលាការប្រជាជនត្រូវកំណត់កំរិតអាហារកិច្ច ដែលឪពុកម្តាយត្រូវផ្តល់ទៅឱ្យអង្គការ ឬ ញាតិលោហិតដែលទទួលបន្ទុកចិញ្ចឹមកូននោះ ។

**មាត្រា ១២២.** ដើម្បីផលប្រយោជន៍របស់កូន ច្បាប់អនុញ្ញាតឱ្យតុលាការប្រជាជនប្រគល់ ទៅឪពុកម្តាយ ដែលត្រូវបានដកហូតអំណាចមេបានូវអំណាចមេបានេះឡើងវិញប្រសិនបើឪពុកម្តាយនោះបានកែប្រែគំនិតមារយាទរបស់ខ្លួនបានល្អឡើងវិញគួរឱ្យទទួលបន្ទុកអប់រំកូនបានលើកលែងតែចំពោះកូនចិញ្ចឹម ។

ច្បាប់នេះ រដ្ឋសភានៃរដ្ឋកម្ពុជាបានអនុម័ត ទៅថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ១៩៨៩ នា សម័យប្រជុំសាមញ្ញលើកទី ១៧ នីតិកាលទី ១ ។

ភ្នំពេញ, ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៨៩

ជ. រដ្ឋសភា

ប្រធាន

ហត្ថលេខា និង ត្រា : **ជា ស៊ីម**